សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

UNIVERSITÉ ROYALE DE DROIT ET DES SCIENCES ÉCONOMIQUES

ROYAL UNIVERSITY OF LAW AND ECONOMICS


## សារណាបញ្ចប់ការសិក្សា

# នីតិវិធីត្រៀម សម្រាប់ការទាញហេតុផល

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ៖ **កញ្ញា ឌី ពេជ្រយ៉ាណែត**

**កញ្ញា ញឿន ស្រីណែត**

ណែនាំដោយ

លោកស្រី **ម៉ួយ ធីតា**



ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# លិខិតថ្លែងអំណរគុណ

នាងខ្ញុំទាំងពីរនាក់មានឈ្មោះ **ឌី ពេជ្រយ៉ាំណែត** និង **ញឿន ស្រីណែត** ជានិស្សិតថ្នាក់បរិញ្ញាបត្រជំនាន់ទី ២៤ ផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនៅក្នុងឆ្នាំសិក្សា២០២៣ និង២០២៤។ នាងខ្ញុំទាំងពីរនាក់បានសរសេរសារណាបញ្ចប់ការសិក្សាដោយជ្រើសរើសប្រធានបទស្តីពី "**នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**"។

**យើងខ្ញុំសូមគោរពលំឱនកាយវាចាចិត្តសម្តែងនូវការរាប់អាន និងព្រមទាំងមហាកតញ្ញូដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតចំពោះ**

**លោកឪពុក យាន ឌី** និង **អ្នកម្តាយ ជិវ គឹមយេង** ព្រមទាំង **លោកឪពុក ញ៉ក់ ញឿន** និង **អ្នកម្តាយ យ៉ាត់ សុខឿន**។ កូនទាំងពីរសុំការអនុញ្ញាតសម្តែងនូវការដឹងគុណចំពោះគុណូបការៈដ៏ធំធេងបំផុតមិនអាចកាត់ថ្លៃបាន របស់លោកឪពុកអ្នកម្តាយ ដែលបានផ្តល់កំណើតដល់រូបកូន ចិញ្ចឹមបីបាច់ថែរក្សាទំនុកបម្រុងដល់កូនៗ ផ្តល់ទីជម្រក អាហារ សម្លៀកបំពាក់ សម្ភារៈចាំបាច់ផ្សេងៗ ដល់កូនៗទាំងពីរតាំងពីពេលនៅក្នុងពោះរហូតដល់កូនបានធំដឹងក្តីពេញរូបពេញរាង។ រយៈពេលជាង ២០ ឆ្នាំដែលកូនៗបានរស់នៅជាគ្រួសារតែមួយជាមួយលោកឪពុកអ្នកម្តាយ លោកទាំងទ្វេតែងតែយកចិត្តទុកដាក់អត់ធ្មត់នៅក្នុងការទូន្មានប្រៀនប្រដៅផ្តល់ដំបូន្មានល្អៗ ជំរុញ និងលើកទឹកចិត្តថ្នាក់ថ្នមមើលថែរក្សាការពារកូនៗ អស់ពីកម្លាំងកាយកម្លាំងចិត្ត ដើម្បីឱ្យកូនក្លាយទៅជាមនុស្សប្រកបដោយគុណធម៌ សីលធម៌ កិត្តិគុណដ៏ល្អប្រពៃថ្លៃថ្លាបំផុត។ មិនតែប៉ុណ្ណោះលោកឪពុកអ្នកម្តាយបានខិតខំប្រឹងប្រែងតស៊ូពុះពារគ្រប់ការលំបាក គ្រប់ឧបសគ្គទាំងអស់មិនថាយប់មិនថាថ្ងៃឡើយ ដោយកម្លាំងញើសឈាម ដើម្បីជាផ្លូវ ជាស្ពានសម្រាប់ឱ្យកូនៗអាចឆ្លងទៅខាងមុខ និងសម្រាប់ផ្គត់ផ្គង់បំពេញរាល់តម្រូវការខ្វះខាតរបស់កូនៗទាំងគ្រឿងបរិភោគ និងសម្ភារៈប្រើប្រាស់សព្វបែបយ៉ាងព្រោះតែចង់ឱ្យកូនរស់នៅបានសុខស្រួលមិនលំបាក និងមានអ្វីៗដែលកូនៗត្រូវការ។ តំណក់ញើសដែលលោកឪពុកអ្នកម្តាយបានតស៊ូយ៉ាងសស្រាក់សស្រាំដោយមិនរអ៊ូ មិនត្អូញត្អែរមួយម៉ាត់នេះ បាននាំឱ្យកូនរៀនរហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ ហើយកូនៗពិតជាមិនអាចបំភ្លេចបាននូវគុណតម្លៃដ៏មហាធំធេងមហាថ្លៃថ្លារបស់លោកឪពុកអ្នកម្តាយដែលបានដក់ជាប់ក្នុងបេះដូងរបស់កូនៗជារៀងរហូតលុះដល់ក្ស័យសង្ខារ។ ដូចនេះកូនទាំងពីរសូមលើកហត្ថាទាំងទ្វេលំឱនកាយក្រាបសំពះដល់បាតជើង ដើម្បីសម្តែងនូវកតញ្ញូចំពោះគុណូបការៈដ៏ធំធេងមួយនេះដែលមិនអាចកាត់ថ្លៃបានឡើយ ព្រមទាំងបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក សូមជួយតាមថែរក្សាលោកឪពុកអ្នកម្តាយ ប្រកបតែសេចក្តីសុខ សេចក្តីចម្រើន ភាពសុខដុមរមនា សុខភាពមាំមួន និងភាពចុំថ្កើងរុងរឿងជារៀងដរាបតទៅ។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង **លោកជំទាវបណ្ឌិត ពេជ ចន្ទមុនី ហ៊ុន ម៉ាណែត** រួមជាមួយសេនាធិការរបស់រាជរដ្ឋាភិបាលកម្ពុជាគ្រប់ជាន់ថ្នាក់ដែលបានដឹកនាំ និងជាចង្កូតសម្រាប់សង្គម ព្រមទាំងបង្កឱ្យមានកាលានុវត្តភាពដ៏ល្អគាប់ប្រសើរ និងជម្រុញឱ្យសង្គមជាតិមានការអភិវឌ្ឍន៍ ជឿនលឿនលូតលាស់លើគ្រប់វិស័យទាំងអស់និយាយជារួម និងសម្រាប់វិស័យអប់រំ និងការសិក្សាស្រាវជ្រាវនិយាយដោយឡែក។ តាមរយៈការដឹកនាំដ៏ពូកែឈ្លាសវៃ និងខិតខំប្តូរផ្តាច់បង្រួបបង្រួមជាតិរបស់សម្តេចបានធ្វើឱ្យប្រទេសកម្ពុជាសព្វថ្ងៃនេះទទួលបានសុខសន្តិភាព ស្ថេរភាព ហើយធ្វើឱ្យនិស្សិតគ្រប់រូបបានសិក្សារៀនសូត្រ សិក្សាស្វែងយល់ស្រាវជ្រាវ និងក្រេបជញ្ជក់ចំណេះដឹងរហូតទទួលបានការអប់រំខ្ពង់ខ្ពស់គ្រប់ៗគ្នា ជាប្រយោជន៍សម្រាប់ការអភិវឌ្ឍន៍សង្គមកម្ពុជាឱ្យមានភាពទាន់សម័យ លូតលាស់ជឿនលឿន និងប្រកបដោយវឌ្ឍនភាពថែមទៀត។

**ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត លុយ ចណ្ណា** ជាសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច រួមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោក លោកស្រី សាស្ត្រាចារ្យទាំងអស់ដែលបានខិតខំប្រឹងប្រែងអស់ពីសមត្ថភាព ព្រមទាំងកម្លាំងកាយ កម្លាំងចិត្ត ចំណាយពេលវេលាដ៏មានតម្លៃនៅក្នុងការដឹកនាំ និងបង្រៀនណែនាំនូវផ្លូវល្អៗជ្រោមជ្រែង ត្រួសត្រាយផ្លូវសម្រាប់និស្សិតទាំងអស់ ព្រមទាំងពង្រឹងគុណភាពកម្មវិធីសិក្សាដល់និស្សិតគ្រប់ជំនាញប្រកបដោយប្រសិទ្ធភាពការងារខ្ពស់ ជាពិសេសលើកទឹកចិត្តជាមួយនឹងការជម្រុញរួមទាំងជួយតម្រង់ទិសយើងខ្ញុំដើម្បីឱ្យទទួលបានពុទ្ធិច្បាស់លាស់ដើម្បីក្លាយជាសសរទ្រូងដ៏រឹងមាំរបស់ជាតិ អាចបម្រើ និងសងគុណចំពោះសង្គមជាតិបានផងដែរ។

**លោកស្រី ម៉ិយ ធីតា** ដែលជាអ្នកគ្រូណែនាំក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះព្រោះថាប្រសិនបើគ្មានការចំណាយពេលវេលាដ៏មានតម្លៃ ការយកចិត្តទុកដាក់ និងកម្លាំងកាយចិត្តក្នុងការជួយជ្រោមជ្រែងផ្តល់ជាយោបល់ គំនិតល្អៗ ត្រួសត្រាយ និងផ្តល់ជាវិធីសាស្ត្រល្អៗដល់យើងខ្ញុំទេនោះ សមិទ្ធផលនេះនឹងមិនអាចកើតមានឡើយ ព្រោះថាគ្មានសមិទ្ធផលណាកើតឡើងដោយឯកឯងនោះទេ។ ការជួយណែនាំ ការនាំផ្លូវការបំភ្លឺផ្លូវ និងបានផ្តល់ជាបទពិសោធន៍ដ៏មានគុណតម្លៃរបស់លោកគ្រូអ្នកគ្រូកន្លងមកបានបង្រៀនឱ្យយើងខ្ញុំយល់ច្បាស់ពីប្រធានបទមួយនេះ និងស្គាល់ពីសង្គមនេះបានច្បាស់ច្រើនជាងមុន ទើបធ្វើឱ្យយើងខ្ញុំសម្រេចបាននូវការតាក់តែងសារណាបញ្ចប់ការសិក្សាប្រកបដោយគុណភាព។

**និស្សិតរៀមច្បង និងមិត្តនិស្សិតដទៃទៀត** ដែលបានលើកទឹកចិត្តគាំទ្រ ផ្តល់ជាអនុសាសន៍ផ្តល់ជាបទពិសោធន៍គំនិតយោបល់ល្អៗ ដែលបានជម្រុញឱ្យយើងខ្ញុំកាន់តែមានទឹកចិត្តក្នុងការសម្រេចនូវសារណានេះដោយមិនរាថយដើម្បីទុកជាវិភាគទានក្នុងការសិក្សាស្រាវជ្រាវផ្សេងៗ ក៏ដូចជាទុកសម្រាប់មិត្តៗនិស្សិតអ្នកអាន និងប្អូនៗជំនាន់ក្រោយៗបានសិក្សាបន្ថែមឱ្យកាន់តែស៊ីជម្រៅទៅលើប្រធានបទនេះ។

មុននឹងធ្វើការបញ្ចប់ នាងខ្ញុំទាំងពីរនាក់សូមការអនុញ្ញាតដើម្បីបានគោរពបន្ទន់កាយ លើកហត្ថាទាំងទ្វេប្រណម្យបួងសួង និងលំឱនកាយវាចាចិត្តថ្លែងអំណរអរគុណ និងសម្តែងនូវសេចក្តីដឹងគុណដល់អ្នកទាំងអស់គ្នាដែលបានរៀបរាប់នូវខាងលើឱ្យជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើន សុខភាពមាំមួនសុវត្ថិភាពមិនថាទីជិតមិនថាទីឆ្ងាយ ភាពសុខដុមរមនា មានសុខភាពល្អពេញបរិបូរណ៌ព្រមទាំងប្រកបការងារអ្វីៗឱ្យបានជោគជ័យប្រកបដោយឧត្តមភាព និងភាពចុំថ្កើងជានិរន្តរ៍។

# អារម្ភកថា

បន្ទាប់ពីយើងខ្ញុំបានសិក្សាថ្នាក់បរិញ្ញាបត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេល ៤ ឆ្នាំកន្លងមកនេះ យើងខ្ញុំទាំងពីរនាក់បានក្រេបជញ្ជក់នូវចំណេះដឹងដ៏មានតម្លៃជាច្រើននិងទទួលបាននូវពុទ្ធិ បទពិសោធន៍ជាច្រើនដែលបានបង្កប់នូវសារៈសំខាន់ទាំងឡាយទាក់ទងនឹងវិស័យច្បាប់ ព្រមទាំងចំណេះដឹងទូទៅផ្សេងៗមួយចំនួនផងដែរ។ ទន្ទឹមនឹងនេះ យើងខ្ញុំបានចាត់ទុកសាលាជាភូមិកំណើតបង្កើតគំនិតព្រោះដោយសារតែសាលាមិនត្រឹមតែផ្តល់នូវចំណេះដឹងដល់យើងខ្ញុំប៉ុណ្ណោះទេ ប៉ុន្តែបានផ្តល់នូវគុណធម៌ និងសីលធម៌ដល់រូបយើងខ្ញុំឱ្យស្គាល់អ្វីល្អ អ្វីអាក្រក់ អ្វីគួរធ្វើ អ្វីមិនគួរធ្វើ និងបានបង្ហាញផ្លូវល្អដល់កូនសិស្សទាំងឡាយ ទើបធ្វើឱ្យយើងខ្ញុំប្រកាន់ខ្ជាប់នូវវិន័យជាប់ប្រាណជានិច្ច។

នាពេលបច្ចុប្បន្នយើងនេះ នៅក្នុងតថភាពសង្គមជាក់ស្តែងមានការកើតឡើងនូវវិវាទជាច្រើនពាក់ព័ន្ធនឹងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋខ្មែរ។ ដោយមានវិវាទមួយចំនួនគូភាគីអាចផ្សះផ្សាគ្នានៅក្រៅប្រព័ន្ធតុលាការបាន ប៉ុន្តែក្នុងនោះផងដែរក៏មានវិវាទជាច្រើនដែលគូភាគីនៃវិវាទមិនអាចផ្សះផ្សាគ្នាបានរហូតឈានដល់មានការដាក់ពាក្យបណ្តឹងទៅតុលាការដើម្បីឱ្យតុលាការវិនិច្ឆ័យរកការពិត។ ចំពោះរឿងក្តីដែលកើតឡើងជាឯកជនបែបនេះ សម្រាប់ព្រះរាជាណាចក្រកម្ពុជាគឺមានក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ជាច្បាប់សារធាតុសម្រាប់ជានិយាមវាស់ស្ទង់នូវសិទ្ធិ និងករណីកិច្ចរបស់គូភាគីដែលយើងហៅថាអង្គច្បាប់។ ក្នុងករណីមានវិវាទ ដើម្បីអាចដោះស្រាយបាន យើងមានក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ ជាអ្នកដំណើរការនូវរឿងក្តីទាំងនោះ។ នៅក្នុងនោះនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលជានីតិវិធីមួយក្នុងចំណោមដំណើរការនៃនីតិវិធីរដ្ឋប្បវេណីទាំង ៣ ដោយនីតិវិធីនេះមានភាពចាំបាច់ណាស់ក្នុងនីតិវិធីរឿងក្តីរដ្ឋប្បវេណី។ ហេតុនេះហើយទើបយើងខ្ញុំសម្រេចចិត្តយកប្រធានបទសារណាស្តីពី "**នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**"។

ម្យ៉ាងវិញទៀត មូលហេតុដែលយើងខ្ញុំជ្រើសរើសយកប្រធានបទនេះទៀតសោត ដោយសារតែនៅក្នុងសង្គមបច្ចុប្បន្ននេះមានវិវាទឯកជនកើតឡើងជាញឹកញាប់នៅក្នុងការដោះស្រាយរឿងក្តីដែលពាក់ព័ន្ធនឹងបញ្ហាឯកជនភាពរបស់ប្រជាពលរដ្ឋក៏កើតមានឡើងជាញឹកញាប់ ហើយនាងខ្ញុំទាំងពីរនាក់មានការចាប់អារម្មណ៍ទៅលើប្រធានបទនេះយ៉ាងខ្លាំង ព្រោះនាងខ្ញុំទាំងពីរនាក់មើលឃើញថានីតិវិធីមួយនេះ ពិតជាជួយសម្រួលដល់នីតិវិធីរដ្ឋប្បវេណីទាំងស្រុងឱ្យមានភាពឆាប់រហ័ស ល្អិតល្អន់ និងយុត្តិធម៌។ ក្នុងនាមនាងខ្ញុំទាំងពីរនាក់ព្រមទាំងសិស្សប្អូនដែលជាទំពាំស្នងឬស្សីពួកយើងគួរយល់ដឹងឱ្យបានច្បាស់ពីនីតិវិធីមួយនេះ ដើម្បីជួយដល់ប្រព័ន្ធច្បាប់នៃព្រះរាជាណាចក្រកម្ពុជាឱ្យមានភាពរឹងមាំ និងផ្តល់ជាទំនុកចិត្តដល់ប្រជាពលរដ្ឋដែលមានវិវាទ។

នាងខ្ញុំទាំងពីរនាក់មានសេចក្តីសោមនស្សឥតគណនា ដែលទទួលបាននូវការណែនាំជាមួយនឹងការដឹកនាំពីសំណាក់ លោកស្រី **ម៉ិច ធីតា** ក្នុងការស្រាវជ្រាវសារណាលើប្រធានបទដ៏មានសារៈសំខាន់មួយនេះ។

ដើម្បីឆ្លើយតបនឹងទឹកចិត្តដ៏ល្អប្រពៃពីសំណាក់លោកគ្រូ អ្នកគ្រូ នាងខ្ញុំទាំងពីរនាក់សូមថ្លែងអំណរគុណដល់លោកគ្រូ អ្នកគ្រូ ដែលបានចំណាយពេលវេលាដ៏មានតម្លៃបំផុតព្រមទាំងកម្លាំងកាយកម្លាំងចិត្តមិនខ្លាចនឿយហត់ក្នុងការចែករំលែកចំណេះដឹងគួបផ្សំ និងបទពិសោធន៍ដែលយើងខ្ញុំមិនធ្លាប់បានជួបប្រទះមក និងការយកចិត្តទុកដាក់ខិតខំប្រឹងប្រែងក្នុងការបណ្តុះបណ្តាល សម្របសម្រួល ជាហេតុធ្វើឱ្យយើងខ្ញុំទទួលបាននូវសមិទ្ធផលដ៏វិសេសវិសាលបំផុតមួយនេះ។

ទោះជាយ៉ាងណាក៏ដោយ ថ្វីបើការសិក្សាស្រាវជ្រាវនេះកើតចេញពីការខិតខំប្រឹងប្រែងអស់ពីសមត្ថភាពរបស់ពួកនាងខ្ញុំទាំងពីរនាក់ក៏ពិតមែន ប៉ុន្តែយើងខ្ញុំជឿថាការស្រាវជ្រាវនេះនៅមិនទាន់គ្រប់គ្រាន់ឥតខ្ចោះនៅឡើយទេ ដោយសារតែកើតមាននូវផលវិបាកមួយចំនួនក្នុងការស្វែងរកឯកសារមកបំពេញអត្ថន័យខ្លឹមសារបន្ថែម។ អាស្រ័យហេតុនេះហើយសូមលោក លោកស្រី សាស្ត្រាចារ្យ មិត្តនិស្សិតដទៃទៀត និងមិត្តអ្នកអានទាំងឡាយមេត្តាខន្តីអភ័យទោសនូវរាល់កំហុសខុសឆ្គងដោយអចេតនា ហើយយើងខ្ញុំទាំងពីរនាក់រង់ចាំស្វាគមន៍ជានិច្ចចំពោះការចូលរួមវាយតម្លៃ ការរិះគន់ក្នុងន័យស្ថាបនាទៅលើអត្ថបទសារណាមួយនេះ។

ក្នុងនាមយើងខ្ញុំជាអ្នកសិក្សាស្រាវជ្រាវលើប្រធានបទមួយនេះ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថាសៀវភៅមួយក្បាលដែលអ្នកអានកំពុងកាន់នេះ និងក្លាយជាឯកសារដ៏មានតម្លៃមួយក្នុងការផ្តល់ចំណេះដឹងដល់មិត្តអ្នកអានទាំងអស់គ្នា និងជួយលើកតម្កើងវិស័យអប់រំឆ្ពោះទៅរកភាពរីកចម្រើន លូតលាស់ និងវឌ្ឍនភាពផងដែរ។

ថ្ងៃសុក្រ ១២ កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ពុទ្ធសករាជ ២៥៦៨
រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤

**ឌី ពេជ្រយ៉ាណែត** **ញៀន ស្រីណែត**

# មាតិកា

ទំព័រ

**លិខិតថ្លែងអំណរគុណ**

**អារម្ភកថា**

**មាតិកា** ........................................ I

**សេចក្តីផ្តើម** ........................................ ១

**ជំពូកទី ១**

**សញ្ញាណទូទៅនៃវិវាទរដ្ឋប្បវេណី**

១.១. និយមន័យ ........................................ ៤

១.២. ប្រភេទនៃវិវាទរដ្ឋប្បវេណី ........................................ ៤

១.៣. ភាគី ........................................ ៧

១.៣.១. សមត្ថភាពភាគី ........................................ ៧

១.៣.២. សមត្ថភាពក្នុងការធ្វើបណ្តឹង ........................................ ៨

១.៣.៣. ករណីខ្វះសមត្ថភាពក្នុងការធ្វើបណ្តឹង ........................................ ១០

១.៤. អ្នកតំណាងតាមផ្លូវបណ្តឹង ........................................ ១១

១.៤.១. អ្នកតំណាងតាមច្បាប់កំណត់ ........................................ ១១

១.៤.២. អ្នកតំណាងដោយអាណត្តិ ........................................ ១២

១.៥. សមត្ថកិច្ចរបស់តុលាការ ........................................ ១២

១.៥.១. ការកំណត់សមត្ថកិច្ចរបស់តុលាការ ........................................ ១៣

១.៥.១.១. សមត្ថកិច្ចសាលាជម្រះក្តីតាមលំនៅដ្ឋាន ........................................ ១៣

១.៥.១.២. សមត្ថកិច្ចសាលាជម្រះក្តីតាមទ្រព្យសម្បត្តិ ........................................ ១៤

១.៥.១.៣. សមត្ថកិច្ចសាលាជម្រះក្តីចំពោះរឿងលែងលះ និងបុគ្គភាព ........................................ ១៥

១.៥.១.៤. សមត្ថកិច្ចសាលាជម្រះក្តីចំពោះការទាមទារច្រើនចំណុចដោយរួមបញ្ចូលជាមួយគ្នា ........................................ ១៥

១.៥.១.៥. សមត្ថកិច្ចសាលាជម្រះក្តីដែលកំណត់ដោយតុលាការកំពូល ........................................ ១៥

១.៥.១.៦. សមត្ថកិច្ចសាលាជម្រះក្តីដោយការព្រមព្រៀង ........................................ ១៥

១.៥.២. ការផ្ទេរសមត្ថកិច្ចរបស់តុលាការ ........ ១៦
១.៦. នីតិវិធីនៃបណ្តឹង ........ ១៦
១.៦.១. ការដាក់ពាក្យបណ្តឹង ........ ១៦
១.៦.២. ការទទួលពាក្យបណ្តឹង ........ ១៨
១.៦.៣. ការពិនិត្យពាក្យបណ្តឹង ........ ១៩
១.៦.៤. ការកំណត់កាលបរិច្ឆេទត្រៀមសម្រាប់ការទាញហេតុផល ........ ១៩
១.៧. សារៈប្រយោជន៍ ........ ១៩
១.៨. ភាពចាំបាច់ ........ ២០
១.៩. គោលបំណង ........ ២០

## ជំពូកទី ២

## ដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

២.១. កាលបរិច្ឆេទ ........ ២៣
២.១.១. ការកំណត់កាលបរិច្ឆេទដោយតុលាការ ........ ២៣
២.១.២. ការកំណត់កាលបរិច្ឆេទជាថ្មី ........ ២៤
២.២. ការកោះហៅគូភាគី ........ ២៦
២.៣. ការសាកល្បងផ្សះផ្សា ........ ២៨
២.៣.១. ករណីផ្សះផ្សាបាន ........ ២៩
២.៣.២. ករណីមិនគួរផ្សះផ្សា ........ ២៩
២.៤. សកម្មភាពក្នុងដំណាក់កាលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ........ ២៩
២.៤.១. ការដាក់សំណូមពរ និងការឆ្លើយតប ........ ៣០
២.៤.២. ការដាក់ឯកសារត្រៀម ........ ៣០
២.៤.៣. ការដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន ........ ៣១
២.៤.៤. ពេលវេលាដែលត្រូវដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន ........ ៣២
២.៤.៥. ការលើកចោលមធ្យោបាយតទល់ ឬ ការពារខ្លួនដែលបានដាក់យឺតយ៉ាវមិនត្រូវនឹងពេលសមរម្យ ........ ៣៣
២.៤.៦. ការកំណត់ចំណុចវិវាទ និងការរៀបចំភស្តុតាង ........ ៣៤

២.៤.៧. សកម្មភាពបណ្តឹងនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ............................. ៣៥
២.៤.៧.១. ការបន្ថែម ឬ ការផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹង ............................................. ៣៥
២.៤.៧.២. បណ្តឹងតប ........................................................................................ ៣៨
២.៤.៧.៣. បណ្តឹងទាមទារការបញ្ជាក់ ក្នុងដំណើរការពាក់កណ្តាលទី ......................... ៤០
២.៤.៨. ការបំបែក និងការរួមបញ្ចូលរឿងក្តី.......................................................................... ៤១

## ជំពូកទី ៣

## ការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

៣.១. ពេលវេលាដែលត្រូវបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល........................................... ៤២
៣.១.១. គោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវបានបំពេញ........................ ៤២
៣.១.២. គោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលមិនទាន់បំពេញ ....................... ៤២
៣.១.២.១. ករណីអវត្តមានភាគីដើមចោទ .......................................................... ៤៣
៣.១.២.២. ករណីអវត្តមានភាគីចុងចម្លើយ.......................................................... ៤៣
៣.១.២.៣. ករណីអវត្តមានភាគីទាំងសងខាង........................................................ ៤៣
៣.២. សកម្មភាពដែលត្រូវបំពេញនៅពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល..................... ៤៤
៣.២.១. ការបញ្ជាក់អំពីអង្គហេតុដែលត្រូវធ្វើការបំភ្លឺ ............................................................ ៤៤
៣.២.២. ការកំណត់កាលបរិច្ឆេទធ្វើការទាញហេតុផលដោយផ្ទាល់មាត់លើកទី១........................ ៤៤
៣.២.៣. កំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល........................................... ៤៥
៣.២.៣.១. ចំណុចជារូបមន្តនៃកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល.. ៤៥
៣.២.៣.២. ចំណុចសារធាតុនៃកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល . ៤៥
៣.២.៣.៣. ការប្តឹងតវ៉ាចំពោះសេចក្តីកត់ត្រានៃកំណត់ហេតុស្តីពី នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល............................................................................................... ៤៦
៣.៣. អានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ................................................. ៤៦
**សេចក្តីសន្និដ្ឋាន**.................................................................................................................. ៤៨
**អនុសាសន៍**.......................................................................................................................... ៥០
**ឯកសារយោង**
**បញ្ជីឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ជាទូទៅក្នុងរឿងរដ្ឋប្បវេណីនៅពេលមានវិវាទកើតឡើងភាគីអាចធ្វើការផ្សះផ្សាគ្នាបាន គឺតុលាការគ្មានសិទ្ធិជ្រៀតជ្រែកក្នុងរឿងឯកជននោះទេ ប៉ុន្តែតុលាការអាចធ្វើការដោះស្រាយទៅលើវិវាទនោះនៅពេលដែលភាគីបានធ្វើការដាក់ពាក្យបណ្តឹងទៅតុលាការ ទើបតុលាការអាចជ្រៀតជ្រែកក្នុងវិវាទនោះបាន។ បន្ទាប់ពីទទួលបានពាក្យបណ្តឹង តុលាការនឹងធ្វើការពិនិត្យពាក្យបណ្តឹងរួចកំណត់កាលបរិច្ឆេទធ្វើការជំនុំជម្រះដោយឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីធានាឱ្យបាននូវការជម្រះក្តីប្រកបដោយសុចរិត និងយុត្តិធម៌ជូនភាគី។ ការជំនុំជម្រះនេះក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ បានបញ្ញត្តថាមុនពេលឈានដល់ការទាញហេតុផលដោយផ្ទាល់មាត់តុលាការត្រូវរៀបចំនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលជាមុនសិន។

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ជាការស្វែងរកចំណុចដែលភាគីមានវិវាទនឹងគ្នាដោយការរៀបចំជាមុននូវការអះអាងរបស់ភាគី និងធ្វើការរៀបចំភស្តុតាងពាក់ព័ន្ធនឹងចំណុចវិវាទដែលនឹងត្រូវធ្វើការពិនិត្យ និងវិនិច្ឆ័យនៅក្នុងដំណាក់កាលនៃការទាញហេតុផលដោយផ្ទាល់មាត់ឱ្យមានភាពឆាប់រហ័ស ច្បាស់លាស់ គ្មានភាពស្មុគស្មាញ ល្អិតល្អន់ និងមានភាពយុត្តិធម៌។ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវមានការចូលរួមពីតុលាការដែលជាអ្នកដឹកនាំចាត់ចែងនីតិវិធី។ ក្នុងករណីដែលរឿងក្តីត្រូវជំនុំជម្រះដោយក្រុមប្រឹក្សា គឺប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវដឹកនាំនីតិវិធី។ ប៉ុន្តែប្រសិនបើរឿងក្តីជំនុំជម្រះដោយចៅក្រមទោល គឺចៅក្រមនោះជាអ្នកដឹកនាំនីតិវិធី។

ទន្ទឹមនឹងនោះ ភាគីដើមចោទ និងភាគីចុងចម្លើយក៏ជាតួអង្គដ៏សំខាន់ផងដែរនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដែលត្រូវធ្វើសកម្មភាពចាំបាច់មួយចំនួនដើម្បីឱ្យតុលាការអាចធ្វើការកំណត់អំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តរបស់ខ្លួននៅក្នុងរឿងក្តី។ នៅក្នុងនីតិវិធីនេះទៀតសោត ទាំងតុលាការនិងភាគីត្រូវគោរពនូវគោលការណ៍សំខាន់ៗដូចជា គោលការណ៍ចំពោះមុខ គោលការណ៍យុត្តិធម៌ និងឆាប់រហ័ស គោលការណ៍អសាធារណៈ គោលការណ៍សិទ្ធិចាត់ចែងរបស់ភាគី និងគោលការណ៍នៃការប្រើប្រាស់សិទ្ធិបំភ្លឺជាដើម។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ការស្រាវជ្រាវទៅលើប្រធានបទ "**នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**" គឺផ្តោតទៅលើចំណោទបញ្ហាសំខាន់ៗមួយចំនួនមានដូចជា៖

- តើអ្វីទៅជាវិវាទរដ្ឋប្បវេណី ?

- នៅពេលដែលមានវិវាទរដ្ឋប្បវេណីកើតឡើង តើគូវិវាទអាចដោះស្រាយដោយវិធីណាខ្លះ ?
- តើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលសំដៅទៅលើអ្វី ?
- តើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវប្រព្រឹត្តទៅយ៉ាងដូចម្តេចខ្លះ ?
- នៅពេលដែលបានបញ្ចប់នូវនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តើមានអានុភាពអ្វីខ្លះ ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការសិក្សាស្រាវជ្រាវទៅលើប្រធានបទមួយនេះ គឺដើម្បីរំលេចចេញនូវនីតិវិធីដែលមានផលប្រយោជន៍ចំពោះការអនុវត្តរបស់តុលាការចំពោះវិវាទរឿងឯកជន។ ដោយសារតែនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ មានភាពចាំបាច់នៅក្នុងការដោះស្រាយវិវាទនៅក្នុងរឿងក្តីរដ្ឋប្បវេណីដែលខានពុំបាននេះហើយបានជានាងខ្ញុំទាំងពីរនាក់សម្រេចចិត្តជ្រើសរើសយកប្រធានបទមួយនេះមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងទុកជាឯកសារសម្រាប់លោក លោកស្រី អ្នកអាន និងជាពិសេសមិត្តនិស្សិតច្បាប់គ្រប់ជំនាន់អាចធ្វើជាមូលដ្ឋានក្នុងការសិក្សាស្រាវជ្រាវ ព្រមទាំងជាការយល់ដឹងពីបច្ចុប្បន្នភាពនៃការវិវត្តន៍នៃវិស័យច្បាប់របស់កម្ពុជា។

## ៤. សារៈប្រយោជន៍

លទ្ធផលនៃសារណានីមួយៗ និងគ្រប់ជំនាញទាំងអស់ប្រាកដណាស់តែងផ្តល់នូវសារៈប្រយោជន៍ជានិច្ចជូនសិស្សនិស្សិត និងអ្នកអានគ្រប់រូប។ សម្រាប់សិស្សនិស្សិតនៃសាកលវិទ្យាល័យច្បាប់ សារណានេះអាចជាអត្ថបទដែលជម្រុញឱ្យកាន់តែយល់បានស៊ីជម្រៅអំពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងអាចជាមូលដ្ឋានសម្រាប់បណ្តុះគំនិតទាក់ទងនឹងការអនុវត្តជាក់ស្តែងបានផងដែរ។ ចំណែកឯ សាធារណៈជនក៏អាចទទួលចំណេះដឹងពាក់ព័ន្ធនឹងវិវាទរដ្ឋប្បវេណី ជាពិសេសការដោះស្រាយវិវាទរដ្ឋប្បវេណីទាំងនេះក្រៅប្រព័ន្ធតុលាការ។ បន្ថែមពីនេះ នីតិវិធីនៃការដាក់ពាក្យបណ្តឹងក្នុងករណីដែលមិនអាចដោះស្រាយវិវាទនោះក្រៅប្រព័ន្ធតុលាការបាន។ ម៉្យាងទៀត រឹតតែទទួលបានការយល់ដឹងពីដំណាក់កាលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដែលជាដំណាក់កាលដ៏សំខាន់មួយនៅក្នុងនីតិវិធីរដ្ឋប្បវេណី។

## ៥. វិធីសាស្ត្រស្រាវជ្រាវ

- ប្រភពឯកសារសំខាន់ៗមានៈ
  - បណ្ណាល័យនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
  - សៀវភៅមេរៀនរបស់លោកគ្រូ អ្នកគ្រូ
- វិធីសាស្ត្រប្រមូលទិន្នន័យៈ
  - ការអានឯកសារជាតិ និងបរទេស ជាសៀវភៅ និងរបាយការណ៍
  - ការអានឯកសារស្រាវជ្រាវផ្សេងៗរបស់លោកគ្រូ អ្នកគ្រូ

- ប្រព័ន្ធឯកសារអេឡិចត្រូនិច

## ៦. ទំហំវិសាលភាព និងដែនកំណត់

សារណានេះនឹងធ្វើការបង្ហាញអំពីវិវាទរដ្ឋប្បវេណីដែលទាក់ទងទៅនឹងសង្គមជាក់ស្តែង ព្រមទាំងការដោះស្រាយវិវាទទាំងនោះនៅក្រៅប្រព័ន្ធតុលាការ។ បន្ថែមពីនេះនឹងមានការរៀបរាប់ពីនីតិវិធីបណ្តឹងក្នុងករណីដែលវិវាទទាំងនោះមិនអាចដោះស្រាយដោយឆន្ទៈរបស់ភាគី រហូតត្រឹមតែនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនៅតុលាការជាន់ទាបប៉ុណ្ណោះ ដោយមិនធ្វើការបកស្រាយទៅដល់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនៅតុលាការជាន់ខ្ពស់នោះទេ ឬ ឈានដល់នីតិវិធីបន្ទាប់ឡើយ។

## ៧. រចនាសម្ព័ន្ធ

ការស្រាវជ្រាវស្តីពី នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ នាងខ្ញុំទាំងពីររូបបានចងក្រងឡើងដោយបែកចែកជាប្លង់ដែលមាន ៣ (បី) ជំពូកធំៗដូចខាងក្រោម ៖

**ជំពូកទី១ ៖ សញ្ញាណទូទៅនៃវិវាទរដ្ឋប្បវេណី**
**ជំពូកទី២ ៖ ដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**
**ជំពូកទី៣ ៖ ការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

# ជំពូកទី ១
# សញ្ញាណទូទៅនៃវិវាទរដ្ឋប្បវេណី

# ជំពូកទី ១
# សញ្ញាណទូទៅនៃវិវាទរដ្ឋប្បវេណី

ក្នុងសង្គមសេដ្ឋកិច្ចទីផ្សារ បុគ្គលឯកជនម្នាក់ៗដែលជាសមាជិកនៃសង្គមនោះរមែងធ្វើសេដ្ឋកិច្ចសម្រាប់ទ្រទ្រង់ជីវភាពរបស់ខ្លួនតាមរយៈការដោះដូរវត្ថុ ឬ សេវាទៅវិញទៅមក ដែលនេះគឺជាកិច្ចសន្យារវាងបុគ្គលឯកជន និងបុគ្គលឯកជន។ ករណីភាគច្រើន ភាគីដែលបានបង្កើតកិច្ចសន្យាជាមួយគ្នា បានរក្សាការសន្យារបស់ខ្លួន និងបានគោរពសិទ្ធិរបស់ភាគីម្ខាងទៀត ហើយបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនដោយទៀងទាត់។ ក៏ប៉ុន្តែជួនកាលអាចមានបញ្ហាដែលបណ្តាលឱ្យមានវិវាទរដ្ឋប្បវេណីកើតឡើង(១.១)។ តើវិវាទរដ្ឋប្បវេណីទាំងនោះគ្របដណ្តប់ទៅលើអ្វីខ្លះ (១.២) ? ភាគីនៅក្នុងវិវាទដែលមានការបញ្ញត្តច្បាស់លាស់ដោយច្បាប់ប៉ុណ្ណោះ ដែលមានសមត្ថភាពធ្វើបណ្តឹងបាន (១.៣) ដោយឡែកនៅក្នុងករណីខ្លះ ច្បាប់ក៏បានបញ្ញត្តអំពីអ្នកដែលអាចធ្វើជាអ្នកតំណាងទៅលើសកម្មភាពបណ្តឹងរបស់ភាគីដែលខ្វះសមត្ថភាពក្នុងការធ្វើបណ្តឹងបានដែរ (១.៤)។ បន្ថែមពីនេះ មានតែតុលាការដែលមានសមត្ថកិច្ចទៅលើរឿងក្តីរដ្ឋប្បវេណីណាមួយនោះទេ ទើបអាចជម្រះរឿងក្តីនោះបាន (១.៥)។ ការដាក់ពាក្យបណ្តឹងទៅតុលាការនោះទៀតសោត តម្រូវឱ្យធ្វើទៅតាមនីតិវិធីនៃបណ្តឹង ហើយសកម្មភាពទាំងនេះត្រូវតែឆ្លងកាត់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះអ្វីទៅដែលហៅថានីតិវិធីត្រៀមសម្រាប់ការទាញហេតុផល (១.៦) ? ម្យ៉ាងទៀតនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលមានសារៈប្រយោជន៍ (១.៧) ភាពចាំបាច់ (១.៨) និងគោលបំណងអ្វីខ្លះ (១.៩) ?

## ១.១. និយមន័យ

វិវាទរដ្ឋប្បវេណី សំដៅទៅលើវិវាទដែលកើតចេញអំពីទំនាក់ទំនងគតិយុត្តរវាងបុគ្គលឯកជនដែលមានភាពស្មើភាពនៅក្នុងសង្គម ពាក់ព័ន្ធនឹងបញ្ហាមួយចំនួនដូចជា កម្មសិទ្ធ និងកិច្ចសន្យា (ទំនាក់ទំនងទ្រព្យសម្បត្តិ) អាពាហ៍ពិពាហ៍ និងសន្តតិកម្ម (ទំនាក់ទំនងញាតិ)។[1]

## ១.២. ប្រភេទនៃវិវាទរដ្ឋប្បវេណី

ជាទូទៅច្បាប់ទាំងឡាយអាចត្រូវបានបែងចែកជាពីរប្រភេទធំៗ គឺនីតិសាធារណៈ និងនីតិឯកជនដែលទស្សនៈភាគច្រើនយល់ឃើញថា នីតិទាំងពីរនេះគួរត្រូវបានបែងចែកទៅតាមលក្ខណៈនៃទំនាក់ទំនងគតិយុត្ត។ បានន័យថា នីតិសាធារណៈ គឺជាច្បាប់ដែលបញ្ញត្តអំពីទំនាក់ទំនងរវាងភាគីដែលគ្មានភាពស្មើគ្នា (រដ្ឋ និងពលរដ្ឋ) រីឯនីតិឯកជន គឺជាច្បាប់ដែលបញ្ញត្តអំពីទំនាក់ទំនងគតិយុត្តរវាងភាគីដែលមានភាពស្មើគ្នា (ពលរដ្ឋ និង

[1] ជួប បិតបេប្បទ្ធិ, អត្ថបទនៃវិវាទរដ្ឋប្បវេណី, ទំព័រទី ១, ឆ្នាំ២០១៦។

ពលរដ្ឋ ជាលក្ខណៈឯកជន) ដូចជា ក្រមរដ្ឋប្បវេណី ក្រមពាណិជ្ជកម្ម ច្បាប់ស្តីពីសហគ្រាស ច្បាប់ស្តីពីរូបិយាណត្តិ និងប័ណ្ណសងតាមការបញ្ជា ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ច្បាប់កិច្ចសន្យា និងច្បាប់ពិសេសមួយចំនួន ដូចជា ច្បាប់ការងារ ច្បាប់ភូមិបាល។ ដោយមូលហេតុថា ក្រមរដ្ឋប្បវេណីមានលក្ខណៈផ្សារភ្ជាប់ទៅនឹងជីវិតឯកជនរបស់ពលរដ្ឋ រវាងពលរដ្ឋ និងពលរដ្ឋ ជាពិសេសពាក់ព័ន្ធជាមួយទំនាក់ទំនងទ្រព្យសម្បត្តិ និងទំនាក់ទំនងញាតិ ដូច្នេះហើយទើបគេហៅក្រមរដ្ឋប្បវេណីថាជា "នីតិឯកជន"។

ដូចនេះ វិវាទរដ្ឋប្បវេណី គ្របដណ្តប់ទៅលើវិវាទទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងទំនាក់ទំនងទ្រព្យសម្បត្តិ (កម្មសិទ្ធ និងកិច្ចសន្យា) និងទំនាក់ទំនងញាតិ (អាពាហពិពាហ៍ និងសន្តតិកម្ម) ព្រមទាំងវិវាទដែលបានកំណត់នៅក្នុងច្បាប់ពិសេសមួយចំនួនទៀតដូចជា វិវាទពាណិជ្ជកម្ម វិវាទការងារ និងវិវាទដីធ្លីជាដើម។

ជាគោលការណ៍ ច្បាប់ទទួលស្គាល់នូវសិទ្ធិសេរីភាពនៃឆន្ទៈរបស់បុគ្គល ក្នុងការកំណត់អ្វីៗដែលពាក់ព័ន្ធនឹងជីវភាពសេដ្ឋកិច្ចរបស់ខ្លួន ដូចជាការដោះដូរវត្ថុ ឬ សេវាជាអាទិ៍។ ហេតុនេះនៅពេលដែលជីវភាពសេដ្ឋកិច្ចរបស់បុគ្គលឯកជនកើតចេញជាវិវាទ ក្រមរដ្ឋប្បវេណីមិនត្រឹមតែបានកំណត់ពីគោលបំណងនៃបណ្តឹងរដ្ឋប្បវេណីក្នុងការការពារសិទ្ធិស្របច្បាប់របស់បុគ្គលឯកជន តាមរយៈការដោះស្រាយវិវាទដោយបង្ខំ តែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានអនុញ្ញាតយ៉ាងជាក់លាក់ឱ្យមានការប្រើប្រាស់យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។[2]

គួរកត់សម្គាល់ផងដែរ កម្ពុជាបានអនុម័តច្បាប់ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការជាដំបូងរបស់ខ្លួន ដោយការបង្កើតឡើងនូវក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅឆ្នាំ ២០០១។ បន្ទាប់មក នៅឆ្នាំ ២០០៦ កម្ពុជាបានអនុម័តច្បាប់ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការជាលើកទី ២ ហៅថាច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ ក្រៅពីនេះនៅមានច្បាប់ពិសេសមួយចំនួនទៀត ដែលផ្តល់លទ្ធភាពតាមផ្លូវច្បាប់ និងលើកទឹកចិត្តឱ្យមានការប្រើប្រាស់យន្តការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មុននឹងប្តឹងទៅតុលាការ តាមមធ្យោបាយនៃ ការចរចា សន្ធានកម្ម និងមជ្ឈត្តការ ដូចជា ច្បាប់ស្តីពីការងារ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ព្រះរាជក្រឹត្យស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី[3] អនុក្រឹត្យលេខ ៤៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មការសុរិយោដី[4]។

[2] មាត្រា ៩៧ និងមាត្រា ១០៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[3] សូមមើលមាត្រា ៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ចុះថ្ងៃទី ២៩ ខែកុម្ភៈ ឆ្នាំ២០០៦។

[4] សូមមើលមាត្រា ៧ ដល់មាត្រា ១១ នៃអនុក្រឹត្យលេខ ៤៧ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០០២។

ដោយផ្អែកទៅតាមបទដ្ឋានគតិយុត្តខាងលើនេះ គេអាចកំណត់បានយ៉ាងច្បាស់លាស់ថា នៅពេលមានវិវាទរដ្ឋប្បវេណី ភាគីវិវាទអាចដោះស្រាយវិវាទតាមវិធាននៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការបាន មុនពេលឈានដល់ការដាក់ពាក្យបណ្ដឹងទៅតុលាការមានសមត្ថកិច្ច។

**វិធាននៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ**

ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រមូលផ្ដុំទៅដោយទម្រង់ជាច្រើននៃនីតិវិធីដោះស្រាយវិវាទ ក្នុងនោះមានការ ការចរចា សន្ធានកម្ម និងមជ្ឈត្តការ ដែលជាទម្រង់ទូទៅបំផុតនៃដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។

**- ការចរចា**

ការចរចា គឺជាដំណើរការនៃការឆ្លើយឆ្លងគ្នាទៅវិញទៅមក ដែលតាមរយៈនេះភាគីទាំងអស់ដាក់ជូន ឬពិចារណាលើសំណើផ្សេងរហូតដល់សំណើណាមួយត្រូវបានធ្វើឡើង ហើយត្រូវបានគេទទួលយក។[5] ការចរចាអាចធ្វើឡើងតាមវិធីជាច្រើនដូចជា ដោយផ្ទាល់មាត់ ឬ ជាលាយលក្ខណ៍អក្សរ និងដោយផ្ទាល់រវាងភាគីវិវាទ ឬតាមរយៈតំណាងរបស់ភាគីទាំងនោះ។ បន្ថែមពីនេះការចរចាផ្ដល់នូវការសន្សំសំចៃ រក្សាភាពឯកជន បង្កើនភាពបត់បែន និងរក្សាទំនាក់ទំនងជាបន្តបានល្អ ជាជាងការដោះស្រាយវិវាទតាមរយៈសន្ធានកម្ម មជ្ឈត្តការ និងជាពិសេសគឺតុលាការ។

**- សន្ធានកម្ម**

សន្ធានកម្ម (ការសម្រុះសម្រួល) គឺជាដំណើរការដោះស្រាយវិវាទដែលមានការជួយសម្របសម្រួលពីសន្ធានការី[6] ឬ ភាគីទី ៣ ហើយមានលក្ខណៈខុសគ្នាពីការចរចាត្រង់ថា ការចរចា គឺធ្វើឡើងរវាងភាគីនៃវិវាទ ឬមេធាវីតំណាងឱ្យភាគីតែប៉ុណ្ណោះ។[7]

ជាក់ស្ដែង ក្របខ័ណ្ឌគតិយុត្តមួយចំនួនរបស់កម្ពុជាបានអនុញ្ញាតជាផ្លូវការឱ្យមានការជ្រើសរើសសន្ធានកម្មក្នុងការដោះស្រាយវិវាទ។ ចំពោះវិវាទតូចតាចមួយចំនួនដូចជាបញ្ហាបំណុល កិច្ចសន្យា ព្រំប្រទល់ដី កសិដ្ឋាន ការបរិហាកេរ្តិ៍ និងអំពើហិង្សាដែលមិនបង្ករបួសស្នាម អាចត្រូវបានសម្រុះសម្រួលជាផ្លូវការនៅត្រឹមកម្រិតក្រុមប្រឹក្សាឃុំ/សង្កាត់នៅក្នុងមូលដ្ឋានតាមរយៈកម្មវិធីមជ្ឈមណ្ឌលសេវាយុត្តិធម៌។[8]

**- មជ្ឈត្តការ**

[5] ជួប បិតបេប្ញទ្ធិ, អត្ថបទ នៃវិវាទរដ្ឋប្បវេណី, ទំព័រទី ៣, ឆ្នាំ២០១៦។

[6] សន្ធានការី គឺជាបុគ្គលដែលមានអព្យាក្រឹតភាព និងមិនមានទំនាក់ទំនងផលប្រយោជន៍ជាមួយភាគីនៃវិវាទឡើយ។

[7] freshnewsasia.com, បានចូលមើលនៅម៉ោង ១៤:៥៤ នាទីថ្ងៃ, ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៤។

[8] ប្រការ ៣ និងប្រការ ៤ នៃប្រកាសអន្តរក្រសួងរបស់ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃលេខ ៨៥ ឆ្នាំ២០០៦។

មជ្ឈត្តការ គឺជាការផ្សះផ្សាវិវាទដោយប្រើប្រាស់វេទិកាមជ្ឈត្តកម្ម[9] ហើយអាចស្ថិតនៅក្នុង ឬ នៅក្រៅក្របខ័ណ្ឌនៃការគ្រប់គ្រងរបស់ស្ថាប័នផ្សះផ្សាអចិន្ត្រៃយ៍។[10] ដោយទ្បែកការចំណាយខ្ពស់ដែលកើតឡើងដោយដំណើរការនីតិវិធីនៅមជ្ឈមណ្ឌលអន្តរជាតិ ឬ មជ្ឈមណ្ឌលក្នុងតំបន់ទាំងនោះ ពេលខ្លះមិនសមាមាត្រទៅនឹងទំហំនៃជម្លោះមួយចំនួនឡើយ។[11] មជ្ឈត្តករពិចារណាអំពីភស្តុតាងដែលភាគីវិវាទបានដាក់ជូន និងចេញសេចក្តីសម្រេចមួយហៅថា "មជ្ឈត្តវិនិច្ឆ័យ"។ ជាទូទៅ មជ្ឈត្តវិនិច្ឆ័យមានភ្ជាប់កាតព្វកិច្ចចំពោះគូភាគីទាំងអស់ ប៉ុន្តែក្នុងករណីខ្លះមជ្ឈត្តវិនិច្ឆ័យក៏អាចមិនភ្ជាប់កាតព្វកិច្ចចំពោះគូភាគីដែរ។

### ១.៣. ភាគី

ភាគី គឺជាបុគ្គលដែលស្នើសុំឱ្យតុលាការដោះស្រាយវិវាទរបស់ខ្លួននឹងបុគ្គលម្ខាងទៀតដែលមានការពាក់ព័ន្ធ។[12] ឧទាហរណ៍៖ នៅសាលាដំបូង ភាគីជាដើមចោទ ឬ ចុងចម្លើយ។ នៅសាលាឧទ្ធរណ៍ ភាគីជាដើមបណ្តឹងឧទ្ធរណ៍ ឬ ចុងបណ្តឹងឧទ្ធរណ៍។ នៅតុលាការកំពូល ភាគីជាដើមបណ្តឹងសាទុក្ខ ឬ ចុងបណ្តឹងសាទុក្ខ។ នៅក្នុងរឿងក្តីនៃការអនុវត្តដោយបង្ខំ ភាគីជាម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្ត។

#### ១.៣.១. សមត្ថភាពភាគី

សមត្ថភាពភាគី គឺជាលក្ខណៈសម្បត្តិទូទៅដែលអាចធ្វើជាភាគីនៃរឿងក្តីរដ្ឋប្បវេណី។[13] បន្ថែមពីនេះ បុគ្គលដែលអាចមានសិទ្ធិ និងករណីកិច្ចតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី និងច្បាប់ផ្សេងទៀត អាចជាដើមចោទ ឬ ចុងចម្លើយនៅក្នុងបណ្តឹងរដ្ឋប្បវេណី។[14] ហេតុនេះហើយ រូបវន្តបុគ្គល និងនីតិបុគ្គលមានសមត្ថភាពជាភាគីនៅក្នុងបណ្តឹងរដ្ឋប្បវេណី។[15] នៅក្នុងករណីពិសេសទារកក្នុងគភ៌ក៏មានសមត្ថភាពទទួលសិទ្ធិស្តីពីបណ្តឹងទាមទារសំណងនៃការខូចខាតដោយផ្អែកលើអំពើអនីត្យានុកូល ឬ ស្តីពីបណ្តឹងពាក់ព័ន្ធនឹងសន្តតិកម្ម និងអច្ច័យទានដែរ។[16]

[9] វេទិកាមជ្ឈត្តកម្ម គឺជាមជ្ឈត្តករម្នាក់ ឬ មួយក្រុម។
[10] មាត្រា ២ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦។
[11] ncac.org.kh, បានចូលមើលនៅម៉ោង ១:២៦ នាទីព្រឹក, ថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៤។
[12] គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់, សន្ទានុក្រមនីតិវិធីរដ្ឋប្បវេណី ដកស្រង់ពីសន្ទានុក្រមច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែកនីតិរដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី, បោះពុម្ពលើកទី ១ ឆ្នាំ២០០៧។
[13] សេចក្តីពន្យល់ចំណុចសំខាន់ៗ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ទំព័រទី ១៩, ឆ្នាំ២០០៦។
[14] មាត្រា ៣២ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[15] មាត្រា ៦ និងមាត្រា ៤៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
[16] មាត្រា ៩ និងមាត្រា ១១៤៩ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ចំពោះនីតិបុគ្គលមានសមត្ថភាពទទួលសិទ្ធិក្នុងបណ្តឹងដែលមានគោលបំណងជម្រះបញ្ជី ទោះបីជានីតិបុគ្គលនោះបានរំលាយហើយក៏ដោយ ដូចនេះនីតិបុគ្គលដែលបានរំលាយក៏មានសមត្ថភាពជាភាគីដែរ។[17]

### ១.៣.២. សមត្ថភាពក្នុងការធ្វើបណ្តឹង

សមត្ថភាពក្នុងការធ្វើបណ្តឹង គឺជាលក្ខណៈសម្បត្តិដែលភាគី ឬ បុគ្គលផ្សេងដែលពាក់ព័ន្ធក្នុងនីតិវិធីបណ្តឹងអាចធ្វើសកម្មភាពបណ្តឹងដោយខ្លួនឯងបានឱ្យមានអានុភាព ឬ អាចទទួលនូវសកម្មភាពបណ្តឹងរបស់តុលាការ និងភាគីម្ខាងទៀត។[18] ហេតុដូចនេះហើយ ដើម្បីការពារជនដែលពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអះអាង និងការពារផលប្រយោជន៍របស់ខ្លួនតាមផ្លូវបណ្តឹងបាន ច្បាប់បានបង្កើតនូវរបបនៃសមត្ថភាពក្នុងការធ្វើបណ្តឹងដោយចាត់ទុកថាជននោះពុំមានលក្ខណៈសម្បត្តិធ្វើសកម្មភាពក្នុងការធ្វើបណ្តឹង ហើយឱ្យអ្នកតំណាងដែលច្បាប់បានកំណត់ធ្វើសកម្មភាពបណ្តឹងជំនួសជននោះវិញ។

ជនដែលត្រូវកម្រិតសមត្ថភាពសំដៅទៅលើ **អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ** និង **ជននៅក្រោមហិតូបត្ថម្ភ**។[19]

#### - សកម្មភាពបណ្តឹងរបស់អនីតិជន

អនីតិជនសំដៅទៅលើជនដែលមានអាយុក្រោម ១៨ ឆ្នាំ ឬ ជនដែលមិនទាន់គ្រប់អាយុតាមច្បាប់កំណត់ ហើយអនីតិជនត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព។[20]

ជាគោលការណ៍ អនីតិជនពុំមានសមត្ថភាពក្នុងការធ្វើបណ្តឹងទេ ហើយអនីតិជនមិនអាចធ្វើសកម្មភាពបណ្តឹងសុពលបានទេ លុះត្រាតែត្រូវបានធ្វើតាមអ្នកតំណាងដែលច្បាប់បានកំណត់។[21] សកម្មភាពបណ្តឹងដែលអនីតិជនបានធ្វើដោយមិនបានទទួលការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនអាចលុបចោលបាន។ ប៉ុន្តែប្រសិនបើ អ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនបានផ្តល់សច្ចានុមតិនៅពេលក្រោយ ឬ សកម្មភាពដែលទាក់ទងនឹងជីវភាពប្រចាំថ្ងៃរបស់អនីតិជននោះ អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនមិនអាចលុបចោលនូវសកម្មភាពដែលអនីតិជនធ្វើបានឡើយ។[22]

---

[17] មាត្រា ៦៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧។

[18] ហេង បូរ៉ា មេធាវី, សៀវភៅមេរៀន នីតិវិធីរដ្ឋប្បវេណី, ឆ្នាំសិក្សា២០២៣-២០២៤។

[19] មាត្រា ១៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[20] មាត្រា ១៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[21] មាត្រា ៣២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[22] មាត្រា ១៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ទោះបីជាអនីតិជនក៏ដោយ ប្រសិនបើ អនីតិជនបានរៀបអាពាហ៍ពិពាហ៍ អនីតិជននោះ ត្រូវបានចាត់ទុកថា បានដល់នីតិភាពដោយអាពាហ៍ពិពាហ៍នោះ។ [23] ម៉្យាងទៀត ក្នុងករណីដែលអនីតិជនត្រូវបានអនុញ្ញាតឱ្យចាត់ចែង ចំពោះទ្រព្យសម្បត្តិជាក់លាក់ពិសេស ឬ អនីតិជនដែលបានទទួលការអនុញ្ញាតឱ្យប្រកបអាជីវកម្មមួយប្រភេទ ឬ ច្រើនប្រភេទពីអ្នកមានអំណាច ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវមានសមត្ថភាពដូចនីតិជន ចំពោះមុខជំនួញនោះ។

ប្រសិនបើ បានដឹងច្បាស់ថាអនីតិជននោះមិនអាចបំពេញកិច្ចការអាជីវកម្មនោះបាន អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនអាចលុបចោល ឬ កម្រិតនូវការអនុញ្ញាតនៃការប្រកបអាជីវកម្មនោះបាន។[24]

**- សកម្មភាពបណ្តឹងរបស់ជនក្រោមអាណាព្យាបាលទូទៅ**

ជននៅក្រោមអាណាព្យាបាលទូទៅ គឺជានីតិជនដែលស្ថិតនៅក្នុងស្ថានភាពខ្វះសមត្ថភាពតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនជានិរន្តរ៍ ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី (វិកលចរិក) ហើយត្រូវបានប្រកាសដាក់ឱ្យស្ថិតនៅក្រោមអាណាព្យាបាលទូទៅ។[25]

សកម្មភាពដែលធ្វើឡើងដោយជននៅក្រោមអាណាព្យាបាលទូទៅ ត្រូវបានកម្រិតដោយការយល់ព្រមរបស់អ្នកអាណាព្យាបាលទូទៅ។ ក្រៅពីការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព ជននៅក្រោមអាណាព្យាបាលក៏ត្រូវកម្រិតសកម្មភាពក្នុងការធ្វើសកម្មភាពបណ្តឹងដោយខ្លួនឯង ឬ ទទួលសកម្មភាពបណ្តឹងរបស់តុលាការនិងភាគីម្ខាងទៀត ដូចជាអនីតិជនដែរ។ មានន័យថា ជននៅក្រោមអាណាព្យាបាលទូទៅអាចធ្វើសកម្មភាពបណ្តឹងសុពលបាន លុះត្រាតែត្រូវបានធ្វើឡើងដោយអ្នកតំណាងដែលច្បាប់បានកំណត់ ពោលគឺអ្នកអាណាព្យាបាលទូទៅ។[26]

**- សកម្មភាពបណ្តឹងរបស់ជននៅក្រោមហិតូបត្ថម្ភ**

ជននៅក្រោមហិតូបត្ថម្ភ គឺជាជនដែលមានសមត្ថភាពតិចតួចក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ហើយត្រូវបានតុលាការដាក់ឱ្យស្ថិតនៅក្រោមការថែទាំដោយហិតូបត្ថម្ភកៈ។[27]

[23] មាត្រា ៩៦៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[24] មាត្រា ១៩២០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[25] មាត្រា ២៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[26] មាត្រា ៣២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[27] មាត្រា ២៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ដើម្បីធ្វើសកម្មភាពបណ្ដឹង ឬ ធ្វើបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់របស់ជននៅក្រោមហិតូបត្ថម្ភគឺត្រូវទាមទារឱ្យមានការយល់ព្រមពីហិតូបត្ថម្ភកៈ ហើយការយល់ព្រមនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ។[28] ក៏ប៉ុន្តែ ការធ្វើសកម្មភាពចំពោះបណ្ដឹង ឬ បណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ដែលត្រូវបានធ្វើឡើងដោយភាគីម្ខាងទៀត មិនចាំបាច់មានការយល់ព្រមពីហិតូបត្ថម្ភកៈទេ។[29]

ប្រសិនបើចាំបាច់ឱ្យមានការយល់ព្រមពីហិតូបម្ភកៈ ហើយពុំបានទទួលការយល់ព្រមនោះ នោះភាគីម្ខាងទៀតពុំអាចដាក់ពាក្យបណ្ដឹង ឬ ធ្វើការប្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បានទេ។ ក៏ប៉ុន្តែ ចំពោះសកម្មភាពដកពាក្យបណ្ដឹង ឬ ដកបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ដើម្បីធ្វើការផ្សះផ្សា ការលះបង់ការទាមទារ ការទទួលស្គាល់ជាដើម ដែលជាសកម្មភាពបញ្ចប់បណ្ដឹងដោយមិនឆ្លងកាត់តាម សាលក្រម ឬ សាលដីកា ជននៅក្រោមហិតូបត្ថម្ភចាំបាច់ត្រូវមានការយល់ព្រមពិសេសជានិច្ច។[30]

គួរកត់សម្គាល់ផងដែរ ចំពោះជនបរទេសជាគោលការណ៍ក្នុងករណីដែលជនបរទេសណាម្នាក់មានសមត្ថភាពក្នុងការធ្វើបណ្ដឹងដោយយោងតាមបញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ទោះបីជាជននោះពុំមានសមត្ថភាពក្នុងការធ្វើបណ្ដឹងដោយយោងតាមច្បាប់នៃប្រទេសរបស់ជននោះក៏ដោយ ក៏ត្រូវចាត់ទុកថាមានសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្ដឹងនៅប្រទេសកម្ពុជាផងដែរ។[31]

### **១.៣.៣. ករណីខ្វះសមត្ថភាពក្នុងការធ្វើបណ្ដឹង**

សកម្មភាពបណ្ដឹងណាដែលត្រូវបានធ្វើឡើងដោយបុគ្គលដែលខ្វះសមត្ថភាពក្នុងការធ្វើបណ្ដឹង ឬ ខ្វះសិទ្ធិតំណាងដែលច្បាប់បានកំណត់ ឬ ខ្វះការប្រគល់សិទ្ធិចាំបាច់សម្រាប់ធ្វើសកម្មភាពបណ្ដឹងត្រូវមានអានុភាពប្រតិសកម្មតាំងពីពេលដែលសកម្មភាពនោះបានធ្វើឡើង បើមានការទទួលស្គាល់នៅពេលក្រោយដោយភាគីដែលបានទទួលសមត្ថភាពក្នុងការធ្វើបណ្ដឹង ឬ ដោយអ្នកតំណាងដែលបានទទួលសិទ្ធិតំណាងដែលច្បាប់បានកំណត់ ឬ ការប្រគល់សិទ្ធិ។[32]

ក្នុងករណីដែលតុលាការរកឃើញថាភាគីខ្វះសមត្ថភាពក្នុងការធ្វើបណ្ដឹង ឬ ខ្វះសិទ្ធិតំណាងដែលច្បាប់បានកំណត់ ឬ ខ្វះការប្រគល់សិទ្ធិចាំបាច់សម្រាប់ធ្វើសកម្មភាពបណ្ដឹង តុលាការមិនត្រូវច្រានចោលភ្លាមៗនោះទេ ត្រូវមានការបង្គាប់ឱ្យកែតម្រូវនូវចំណុចខ្វះខាតនោះដោយកំណត់អំឡុងពេល ព្រោះថាអាចមានការ

[28] មាត្រា ៣៥ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[29] មាត្រា ៣៣ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[30] មាត្រា ៣៣ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[31] មាត្រា ៣៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[32] មាត្រា ៣៥ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

ផ្តល់នូវសច្ចានុមតិ។[33] នៅពេលដែលតុលាការបានបង្គាប់ឱ្យកែតម្រូវ ត្រូវបង្អាកនូវនីតិវិធីរហូតដល់ពេលសម្រាប់ធ្វើការកែត្រូវនោះបានកន្លងផុតទៅ។ ប៉ុន្តែប្រសិនបើមានការខូចខាតណាមួយអាចកើតឡើងដោយសារការយឺតយ៉ាវ តុលាការអាចឱ្យបុគ្គលដែលមានការខ្វះសមត្ថភាពក្នុងការធ្វើបណ្តឹងនោះធ្វើសកម្មភាពបណ្តឹងជាបណ្តោះអាសន្នបាន។[34]

ម្យ៉ាងទៀតក្នុងករណីដែលកង្វះខាតនូវសកម្មភាពក្នុងការធ្វើបណ្តឹងកើតមានឡើង ក្រោយពេលបានចាត់ការបណ្តឹងនោះ ត្រូវផ្អាកនីតិវិធីបណ្តឹងនោះ ហើយអ្នកតំណាងដោយអាណត្តិត្រូវទទួលបន្ត។[35]

បន្ថែមពីនេះបើក្នុងករណីដែលតុលាការបានចេញសាលក្រមនៃការជម្រះក្តីលើកទី ១ ដោយមូលហេតុថាមិនបានដឹងអំពីកង្វះសមត្ថភាពក្នុងការធ្វើបណ្តឹងរបស់ភាគី ភាគីខាងណាក៏អាចទាមទារឱ្យលុបចោលសាលក្រម ឬ សាលដីកានោះបានដែរ តាមរយៈបណ្តឹងឧទ្ធរណ៍ ឬ បណ្តឹងសាទុក្ខ។[36] ម្យ៉ាងទៀត ទោះជាសាលក្រម ឬ សាលដីកាបានចូលជាស្ថាពរក៏ដោយ ក៏នៅតែអាចទាមទារឱ្យលុបចោលតាមរយៈបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបានដែរ។[37]

## ១.៤. អ្នកតំណាងតាមផ្លូវបណ្តឹង

អ្នកតំណាងតាមផ្លូវបណ្តឹងគឺជាអ្នកធ្វើសកម្មភាពបណ្តឹង ឬ ទទួលនូវសកម្មភាពបណ្តឹងរបស់តុលាការ ឬ ភាគីម្ខាងទៀតដោយផ្អែកលើឆន្ទៈរបស់ខ្លួនក្នុងនាមភាគី ឬ ជំនួសភាគី ហើយអានុភាពនៃការធ្វើសកម្មភាពបណ្តឹង ឬ ទទួលនូវសកម្មភាពបណ្តឹងនោះនឹងមានទៅភាគី។ អ្នកតំណាងតាមផ្លូវបណ្តឹងនេះត្រូវបានបែងចែកជា ២ គឺ អ្នកតំណាងតាមច្បាប់កំណត់ និងអ្នកតំណាងដោយអាណត្តិ។

### ១.៤.១. អ្នកតំណាងតាមច្បាប់កំណត់

អ្នកតំណាងតាមច្បាប់កំណត់ គឺជាអ្នកតំណាងដែលបានទទួលសិទ្ធិនោះដោយយោងតាមបញ្ញត្តិនៃច្បាប់ ឬ តាមរយៈសេចក្តីសម្រេចរបស់តុលាការជាអាទិ៍ មិនមែនបានទទួលសិទ្ធិនោះដោយផ្អែកលើឆន្ទៈរបស់សាមីភាគីទេ។ អ្នកតំណាងតាមច្បាប់កំណត់ ជាទូទៅនឹងធ្វើសកម្មភាពបណ្តឹងជំនួសភាគីដែលគ្មានសមត្ថភាពក្នុងការធ្វើបណ្តឹងដើម្បីផលប្រយោជន៍របស់ភាគីនោះ។ ប៉ុន្តែក្នុងករណីដែលពុំមានអ្នកតំណាងដែលច្បាប់បានកំណត់ទេនោះ ហើយដោយមូលហេតុថាភាគីម្ខាងទៀតចាំបាច់ត្រូវធ្វើបណ្តឹងជាបន្ទាន់ នោះតុលាការត្រូវធ្វើការជ្រើសតាំងអ្នកតំណាងពិសេសសម្រាប់តែករណីពិសេសនេះ ដើម្បីការពារផលប្រយោជន៍ភាគីម្ខាងទៀតទៅ

[33] មាត្រា ៣៥ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[34] មាត្រា ៣៥ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[35] មាត្រា ១៧៣ កថាខណ្ឌទី ១ ចំណុចទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[36] សេចក្តីពន្យល់ចំណុចសំខាន់ៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី, ទំព័រទី ២៣, ឆ្នាំ២០០៦។
[37] មាត្រា ៣០៧ កថាខណ្ឌទី ១ ចំណុចទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

វិញ[38]ហើយនេះក៏ជាតំណាងដែលច្បាប់បានកំណត់មួយប្រភេទដែរ។ ក្នុងករណីដែលអ្នកតំណាងដែលច្បាប់បានកំណត់មានការពាក់ព័ន្ធក្នុងនីតិវិធីបណ្តឹង ជាបឋមភាគីជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ ហេតុនេះហើយជនដែលត្រូវបានផ្តល់សិទ្ធិតំណាងដែលច្បាប់កំណត់តាមផ្លូវសារធាតុ (អ្នកតំណាងតាមផ្លូវច្បាប់សារធាតុ) ដូចជាអ្នកមានសិទ្ធិអំណាចមេបាលើអនីតិជននោះ ឬ ជននៅក្រោមអាណាព្យាបាលទូទៅផងដែរ។ មួយវិញទៀតអ្នកតំណាងដែលច្បាប់បានកំណត់ គឺជាអ្នកតំណាងមិនមែនសាមីភាគីទេ ដូច្នេះមិនអាចក្លាយជាអ្នកដែលមានឈ្មោះនៅក្នុងសាលក្រម ឬ សាលដីកាបាននោះឡើយ។[39]

### ១.៤.២. អ្នកតំណាងដោយអាណត្តិ

អ្នកតំណាងដោយអាណត្តិ គឺជាអ្នកតំណាងដែលបានទទួលសិទ្ធិតំណាងនោះ ដោយផ្អែកលើឆន្ទៈរបស់សាមីភាគី។ ទោះជាភាគីដែលមានសមត្ថភាពក្នុងការធ្វើបណ្តឹងក៏ដោយ ប៉ុន្តែតាមធម្មតាច្រើនតែពុំមានចំណេះដឹងស្តីពី ច្បាប់ដែលចាំបាច់ដើម្បីធ្វើសកម្មភាពបណ្តឹងឱ្យមានប្រសិទ្ធិភាព និងឱ្យបានសមស្របទេ ដូច្នេះហើយអ្នកតំណាងដោយអាណត្តិគឺជាអ្នកទទួលនូវសិទ្ធិដោយការអាណត្តិពីភាគី ចំពោះរឿងក្តីនីមួយៗ ហើយធ្វើសកម្មភាពបណ្តឹងនោះ។ ក្រៅពីនេះក្នុងករណីដែលស្ថាប័នរដ្ឋ ដូចជារដ្ឋ ឬ ក្រសួងជាដើម ជាភាគីវិញគេចាត់តាំងឱ្យមន្ត្រីស្ថាប័ននោះធ្វើសកម្មភាពបណ្តឹងហើយនេះក៏ជាអ្នកតំណាងដោយអាណត្តិដែរ។ [40] ជាគោលការណ៍ជនដែលអាចក្លាយជាអ្នកតំណាងដោយអាណត្តិមានតែមេធាវីទេ [41] នេះគឺដើម្បីការពារផលប្រយោជន៍សាមីភាគីដែលពឹងពាក់។ ហេតុនេះហើយ ក្នុងករណីដែលជនក្រៅពីមេធាវីបានធ្វើសកម្មភាពបណ្តឹងក្នុងនាមជាអ្នកតំណាងដោយអាណត្តិ ជាគោលការណ៍គឺខុសនឹងច្បាប់ ហើយតុលាការត្រូវបំបាត់ចោលនូវការពាក់ព័ន្ធរបស់អ្នកនោះក្នុងបណ្តឹង។ សកម្មភាពដែលបុគ្គលនោះបានធ្វើ ពុំមានសុពលភាពទេ ក៏ប៉ុន្តែប្រសិនបើភាគីបានផ្តល់សច្ចានុម័តសកម្មភាពនោះនឹងមានសុពលភាព។

## ១.៥. សមត្ថកិច្ចរបស់តុលាការ

ជាគោលការណ៍ទូទៅ នីតិវិធីរដ្ឋប្បវេណី តុលាការត្រូវបំពេញតួនាទីរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមការកំណត់ដោយច្បាប់ ពោលគឺមុននឹងតុលាការទទួលយករឿងក្តីរដ្ឋប្បវេណីណាមួយមកពិនិត្យ និងធ្វើចំណាត់ការតុលាការត្រូវធ្វើការត្រួតពិនិត្យឱ្យបានច្បាស់លាស់អំពីសមត្ថកិច្ចរបស់ខ្លួនជាមុនសិន។ ការសម្រេចសេចក្តីដោយខុសសមត្ថកិច្ចជាហេតុនាំឱ្យមានមោឃភាពនៃនីតិវិធី។

[38] មាត្រា ៣៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[39] មាត្រា ១៩៨ ចំណុចទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[40] សាន់ ជួយ សាស្ត្រាចារ្យនីតិសាស្ត្រ, កម្រងមេរៀងស្តីពី នីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០១៥។
[41] មាត្រា ៥៣ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

តុលាការមានសមត្ថកិច្ច គឺជាតុលាការដែលអាចទទួលបានស្របច្បាប់នូវពាក្យបណ្តឹងវិនិច្ឆ័យលើរឿងក្តី ហើយចេញសាលក្រម ឬ សាលដីកាបាន។[42]

### ១.៥.១. ការកំណត់សមត្ថកិច្ចរបស់តុលាការ

ក្រមនីតិវិធីរដ្ឋប្បវេណី មានតួនាទីយ៉ាងសំខាន់ក្នុងការកំណត់អំពីសាលាជម្រះក្តី។ ជាទូទៅសមត្ថកិច្ចរបស់សាលាជម្រះក្តីត្រូវកំណត់នៅពេលដាក់ពាក្យបណ្តឹង។ ដើម្បីងាយស្រួលដល់ការអនុវត្ត ក្រមនីតិវិធីរដ្ឋប្បវេណីបានធ្វើការកំណត់អំពីសមត្ថកិច្ចរបស់សាលាជម្រះក្តីតាមប្រភេទនៃរឿងក្តីដែលមានដូចជា សមត្ថកិច្ចសាលាជម្រះក្តីតាមលំនៅដ្ឋាន (១.៥.១.១) សមត្ថកិច្ចសាលាជម្រះក្តីតាមទ្រព្យសម្បត្តិ (១.៥.១.២) សមត្ថកិច្ចសាលាជម្រះក្តីចំពោះរឿងលែងលះ និងបុត្តភាព (១.៥.១.៣) សមត្ថកិច្ចសាលាជម្រះក្តីចំពោះការទាមទារច្រើនចំណុចដោយរួមបញ្ចូលជាមួយគ្នា (១.៥.១.៤) សមត្ថកិច្ចសាលាជម្រះក្តីដែលកំណត់ដោយតុលាការកំពូល (១.៥.១.៥) និងសមត្ថកិច្ចសាលាជម្រះក្តីដោយការព្រមព្រៀង (១.៥.១.៦)។

#### ១.៥.១.១. សមត្ថកិច្ចសាលាជម្រះក្តីតាមលំនៅដ្ឋាន

**ក. បណ្តឹងចំពោះរូបវន្តបុគ្គល**

- លំនៅដ្ឋានរបស់ចុងចម្លើយ
- ទីសំណាក់ បើពុំមានលំនៅដ្ឋាន ឬ មានលំនៅដ្ឋានមិនពិតប្រាកដនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- លំនៅដ្ឋានចុងក្រោយបើពុំមានទីសំណាក់ ឬ មានទីសំណាក់មិនពិតប្រាកដ។

**ខ. បណ្តឹងចំពោះនីតិបុគ្គលក្នុងប្រទេស**

- ទីតាំងនៃទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មចម្បង។
- លំនៅដ្ឋានរបស់អ្នកតំណាង ឬ របស់អ្នកទទួលខុសត្រូវចាត់ចែងការងារចម្បង បើគ្មានទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មចម្បងទេ។

**គ. បណ្តឹងចំពោះនីតិបុគ្គលបរទេស**

- ទីតាំងនៃទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មចម្បងក្នុងព្រះរាជាណាចក្រកម្ពុជា។

[42] មាត្រា ៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

- លំនៅដ្ឋានរបស់អ្នកតំណាងប្រចាំព្រះរាជាណាចក្រកម្ពុជា ឬ របស់អ្នកទទួលខុសត្រូវភារកិច្ចចាត់ចែងការងារជាចម្បង បើគ្មានទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មក្នុងព្រះរាជាណាចក្រកម្ពុជាទេ។[43]

**១.៥.១.២. សមត្ថកិច្ចសាលាដម្រះក្ដីតាមទ្រព្យសម្បត្តិ**

- បណ្ដឹងទាមទារឱ្យអនុវត្តតាមកិច្ចសន្យា តុលាការមានសមត្ថកិច្ច គឺនៅទីតាំងអនុវត្តកាតព្វកិច្ច។

- បណ្ដឹងទាមទារឱ្យបង់ប្រាក់ដោយរូបិយាណត្តិ ឬ មូលប្បទានប័ត្រ តុលាការមានសមត្ថកិច្ច គឺទីតាំងបង់រូបិយាណត្តិ ឬ មូលប្បទានប័ត្រ។

- បណ្ដឹងទាមទារឱ្យអនុវត្តកាតព្វកិច្ច ចំពោះបុគ្គលដែលពុំមានលំនៅឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ លំនៅឋានមិនពិតប្រាកដ តុលាការមានសមត្ថកិច្ច គឺទីកន្លែងដែលកម្មវត្ថុនៃការទាមទារ ឬ កម្មវត្ថុនៃប្រាតិភោគលើការទាមទារនោះ ឬ ទ្រព្យសម្បត្តិរបស់ចុងចម្លើយដែលអាចរឹបអូសបានស្ថិតនៅ។

- បណ្ដឹងទាមទារឱ្យអនុវត្តកាតព្វកិច្ច ចំពោះនីតិបុគ្គលដែលពុំមានទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ឬ ទីស្នាក់ ឬ ទីកន្លែងអាជីវកម្មមិនពិតប្រាកដ តុលាការមានសមត្ថកិច្ច គឺទីកន្លែងដែលកម្មវត្ថុនៃការទាមទារ ឬ កម្មវត្ថុនៃប្រាតិភោគលើការទាមទារនោះ ឬ ទ្រព្យរបស់ចុងចម្លើយដែលអាចរឹបអូសបានស្ថិតនៅ។

- បណ្ដឹងចំពោះនីតិបុគ្គលដែលមានទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មដែលទាក់ទងនឹងសកម្មភាពការងារ នោះទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មនោះ ជាទីតាំងនៃតុលាការមានសមត្ថកិច្ច។

- បណ្ដឹងទាក់ទងនឹងអចលនវត្ថុ គឺកន្លែងដែលអចលនវត្ថុនោះស្ថិតនៅ។

- បណ្ដឹងទាក់ទងនឹងការចុះបញ្ជី គឺកន្លែងដែលត្រូវចុះបញ្ជី។

- បណ្ដឹងទាក់ទងនឹងមត៌កលំនៅឋានរបស់មតកជន នៅពេលសន្តតិកម្មត្រូវចាប់ផ្ដើម ឬ ទីសំណាក់ បើមតជនពុំមានលំនៅឋានក្នុងព្រះរាជាណាចក្រកម្ពុជា ឬ មានលំនៅឋានមិនពិតប្រាកដ ឬ លំនៅឋានចុងក្រោយ បើមតកជននោះពុំមានទីសំណាក់ក្នុងព្រះរាជាណាចក្រកម្ពុជា ឬ មានទីសំណាក់មិនពិតប្រាកដ។[44]

[43] មាត្រា ៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[44] មាត្រា ៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

**១.៥.១.៣. សមត្ថកិច្ចសាលាជម្រះក្តីចំពោះរឿងលែងលះ និងបុគ្គលភាព**

បណ្តឹងលែងលះ ឬ បណ្តឹងទាមទារបញ្ជាក់អត្ថិភាព ឬ នត្ថិភាពនៃបុគ្គភាពត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខរបស់សាលាដំបូង ដែលមានសមត្ថកិច្ចនៅលំនៅឋានរបស់ភាគី នៃទំនាក់ទំនងឋានៈបុគ្គលដែលពាក់ព័ន្ធនឹងបណ្តឹងនោះ ឬ លំនៅឋានរបស់ភាគីទទួលមរណភាពនោះ។

ក្នុងករណីលំនៅដ្ឋានរបស់ភាគី នៃទំនាក់ទំនងឋានៈបុគ្គលដែលពាក់ព័ន្ធពុំស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ លំនៅឋានក្នុងព្រះរាជាណាចក្រកម្ពុជាមិនពិតប្រាកដ សមត្ថកិច្ចសាលាជម្រះក្តីត្រូវកំណត់តាមលំនៅឋានចុងក្រោយ។[45]

**១.៥.១.៤. សមត្ថកិច្ចសាលាជម្រះក្តីចំពោះការទាមទារច្រើនចំណុចដោយរួមបញ្ចូលជាមួយគ្នា**

ចំពោះបណ្តឹងមួយដែលមានការទាមទារច្រើនចំណុច ហើយស្ថិតនៅក្រោមសមត្ថកិច្ចផ្សេងគ្នាអាចប្តឹងទៅតុលាការដែលមានសមត្ថកិច្ចលើការទាមទារណាមួយក៏បាន ដោយបញ្ចូលការទាមទារផ្សេងទៀតជាមួយគ្នា។[46]

**១.៥.១.៥. សមត្ថកិច្ចសាលាជម្រះក្តីដែលកំណត់ដោយតុលាការកំពូល**

ក្នុងករណីដែលតុលាការមានសមត្ថកិច្ចមិនអាចអនុវត្តនូវសិទ្ធិជម្រះក្តីបានដោយសារច្បាប់ ឬ ហេតុការណ៍ពិត ឬ ករណីដែលសមត្ថកិច្ចនៃតុលាការមិនពិតប្រាកដសម្រេចតាមពាក្យសុំ។ តុលាការកំពូលត្រូវកំណត់តុលាការដែលមានសមត្ថកិច្ចដោយដីកាសម្រេចតាមពាក្យសុំ។[47]

**១.៥.១.៦. សមត្ថកិច្ចសាលាជម្រះក្តីដោយការព្រមព្រៀង**

គូភាគីអាចធ្វើការព្រមព្រៀងកំណត់តុលាការដែលមានសមត្ថកិច្ចជំនុំជម្រះក្តីបាន ប៉ុន្តែការព្រមព្រៀងនេះបាន ចំពោះតែការព្រមព្រៀងរវាងពាណិជ្ជករ និងពាណិជ្ជករ ឬ នីតិបុគ្គល និងនីតិបុគ្គល ឬ នីតិបុគ្គល និងពាណិជ្ជករ ហើយចំពោះតែការជំនុំជម្រះក្តីលើកទី ១ តែប៉ុណ្ណោះ។ ការព្រមព្រៀងនេះ នឹងមានអានុភាពអនុវត្តលុះត្រាតែត្រូវបានធ្វើជាលាយលក្ខណ៍អក្សរ។

ដោយឡែកក្នុងករណីដែលចុងចម្លើយបានធ្វើសេចក្តីដោះសារអំពីអង្គសេចក្តីនៅក្នុង នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ បានឆ្លើយទាញហេតុផលអំពីអង្គសេចក្តីនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់រួច

[45] មាត្រា ១០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[46] មាត្រា ១១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[47] មាត្រា ១២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

ហើយនៅតុលាការនៃការជំនុំជម្រះក្តីលើកទី ១ ដោយគ្មានការតវ៉ាអំពីកំហុសនៃសមត្ថកិច្ចសាលាជម្រះក្តី តុលាការនោះត្រូវមានសមត្ថកិច្ចជម្រះក្តី។

### ១.៥.២. ការផ្ទេរសមត្ថកិច្ចរបស់តុលាការ

ការផ្ទេរសមត្ថកិច្ចរបស់តុលាការអាចធ្វើទៅបានក្រោមហេតុផលចំនួន ២ គឺការចាត់ចែងបណ្តឹងខុសសមត្ថកិច្ច[48] និងការផ្ទេរសមត្ថកិច្ចដើម្បីជៀសវាងការយឺតយ៉ាវ។

ប្រសិនបើតុលាការយល់ឃើញថា បណ្តឹងទាំងមូល ឬ មួយផ្នែកមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនទេ តុលាការនោះត្រូវធ្វើការផ្ទេរសមត្ថកិច្ចតាមពាក្យសុំ ឬ ដោយអំណាចឆន្ទានុសិទ្ធិ។ ទោះបីជាបណ្តឹងមួយស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនក៏ដោយ ប្រសិនបើតុលាការជំនុំជម្រះលើកទី ១ យល់ឃើញថាចាំបាច់ដើម្បីជៀសវាងពីការយឺតយ៉ាវហួសហេតុនៃនីតិវិធី ឬ ដើម្បីឱ្យមានសមធម៌រវាងគូភាគីដោយពិចារណាអំពីលំនៅឋានរបស់គូភាគី និងសាក្សីដែលត្រូវសាកសួរ ទីតាំងនៃវត្ថុដែលនឹងត្រូវត្រួតពិនិត្យ និងកាលៈទេសៈផ្សេងៗ តុលាការនោះអាចផ្ទេរបណ្តឹងទាំងមូល ឬ ផ្នែកណាមួយទៅតុលាការផ្សេងទៀតដែលមានសមត្ថកិច្ច តាមពាក្យសុំរបស់ភាគី ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន។

## ១.៦. នីតិវិធីនៃបណ្តឹង

នីតិវិធីនៃបណ្តឹង គឺជាដំណើរការនៃការពាំនាំនូវរឿងវិវាទទៅតុលាការដែលមានសមត្ថកិច្ច ដើម្បីស្វែករកយុត្តិធម៌ដល់បុគ្គលដែលមានវិវាទ។ នៅក្នុងនីតិវិធីនៃបណ្តឹងនេះមាន ៤ ចំណុចសំខាន់ៗដូចជា ការដាក់ពាក្យបណ្តឹង (១.៦.១) ការទទួលពាក្យបណ្តឹង (១.៦.២) ការពិនិត្យពាក្យបណ្តឹង (១.៦.៣) និងការរៀបចំនូវការកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល (១.៦.៤)។

### ១.៦.១. ការដាក់ពាក្យបណ្តឹង

នីតិវិធីរដ្ឋប្បវេណីនៅតុលាការ ត្រូវចាប់ផ្តើមនៅពេលដាក់ពាក្យបណ្តឹង។ ពាក្យបណ្តឹងដាក់ជាលាយលក្ខណ៍អក្សរទៅតុលាការ[49] លើកលែងរឿងក្តីមានចំនួនទឹកប្រាក់តិច។[50]

ពាក្យបណ្តឹងចាត់ទុកថាបានដាក់ នៅពេលក្រឡាបញ្ជីបោះត្រាចូលថាបានទទួល។ ក្នុងនោះចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹងមានដូចជា[51]៖

[48] មាត្រា ១៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[49] មាត្រា ៧៥ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[50] មាត្រា ២២៥ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[51] មាត្រា ៧៥ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

**ក. ភាគី អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកតំណាងនៃនីតិបុគ្គល**

- សរសេរឈ្មោះ នាមករណ៍ និងអាសយដ្ឋានរបស់ភាគី ឬ អ្នកតំណាងច្បាប់បានកំណត់។[52]

- ករណីភាគីជានីតិបុគ្គល ត្រូវសរសេរពីអ្នកតំណាងនីតិបុគ្គលនោះ។[53]

**ខ. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និងអង្គហេតុចំបាច់ដើម្បីបញ្ជាក់ការទាមទារ**[54]

ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ គឺជាអត្ថន័យនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការសម្រេចសេចក្តី ដូចក្នុងពាក្យបណ្តឹងខ្លួន។

ឧទាហរណ៍៖

១. បណ្តឹងទាមទារឱ្យផ្តល់តាវកាលិក

២. បណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត

៣. បណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ និងទំនាក់ទំនងគតិយុត្ត។

មាត្រា ៧៥ កថា.២.ខ បានចែងថា អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ គឺជាអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារតាមផ្លូវបណ្តឹង ហើយក៏កុំឱ្យមានការភាន់ច្រឡំ ឬ មានការបែងចែកមិនច្បាស់លាស់នូវការទាមទារ ដែលជាកម្មវត្ថុនៃការជំនុំជម្រះ និងសម្រេចសេចក្តីទៅនឹងការទាមទារផ្សេងទៀត និងកុំឱ្យមានការភាន់ច្រឡំរវាងសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលអះអាងដោយដើមចោទ និងសិទ្ធិ ទំនាក់ទំនងគតិយុត្តដទៃទៀត។

ឧទាហរណ៍៖ ការអះអាងសិទ្ធិលើបំណុលផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ។

ក្នុងនោះ មាត្រា៧៥ កថា.៣ បានចែងពីចំណុចគប្បីសរសេរក្នុងពាក្យបណ្តឹងមានដូចជា៖

- អង្គហេតុដែលជាមូលហេតុនៃការទាមទារ គឺជាអង្គហេតុបង្កើតនូវសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដែលជាសិទ្ធិទាមទារតាមផ្លូវបណ្តឹង។
- អង្គហេតុបង្កើតសិទ្ធិ កិច្ចសន្យាខ្ចីប្រាក់ ៥,០០០ (ប្រាំពាន់) ដុល្លារអាមេរិក
- អង្គហេតុបង្កើតឧបសគ្គនៃការកកើតសិទ្ធិ កិច្ចសន្យាមានវិការៈ

[52] មាត្រា ៧៥ កថាខណ្ឌទី ២ ចំណុចទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[53] មាត្រា ៣៨ និងមាត្រា ៧៥ កថាខណ្ឌទី ២ ចំណុចទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[54] មាត្រា ៧៥ កថាខណ្ឌទី ២ ចំណុចទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

- អង្គហេតុរំលត់សិទ្ធិ ចុងចម្លើយបានសងប្រាក់ ៥,០០០ (ប្រាំពាន់) ដុល្លារអាមេរិក រួចហើយ
- អង្គហេតុបង្កើតការរារាំងការអនុវត្តសិទ្ធិ កាលកំណត់សងមិនទាន់មកដល់
- អង្គហេតុតវ៉ារបស់ចុងចម្លើយ

អង្គហេតុសំខាន់ៗក្នុងចំណោមអង្គហេតុទាំងមូលដែលទាក់ទងនឹងអង្គហេតុដែលជាមូលហេតុ នៃការទាមទារ និងភស្តុតាងអង្គហេតុប្រយោលជាច្រើនអាចបង្កើតជាអង្គហេតុផ្ទាល់តាមភស្តុតាង។[55]

### ១.៦.២. ការទទួលពាក្យបណ្តឹង

នីតិវិធីនៃការទទួលពាក្យបណ្តឹង ដោយក្រឡាបញ្ជីត្រូវ៖

- វាយត្រាលើពាក្យបណ្តឹង និងចុះកាលបរិច្ឆេទនៃការទទួល
- ចុះលេខរឿងនៅក្នុងសៀវភៅពាក្យបណ្តឹង
- យកពាក្យបណ្តឹង និងឯកសារពាក់ព័ន្ធមកដាក់បញ្ចូលក្នុងក្រុមសំណុំរឿង
- បញ្ជូនសំណុំរឿងក្តីនោះទៅចៅក្រមទទួលបន្ទុក ទៅតាមដីកាសម្រេចប្រចាំឆ្នាំ
- មុនពេលបញ្ជូន ក្រឡាបញ្ជី គួរពិនិត្យមើលពាក្យបណ្តឹងមួយត្រួសសិន ទាក់ទងនឹងការសរសេរពាក្យបណ្តឹង[56] និងអំពីសមត្ថកិច្ចជម្រះក្តី[57] និងលិខិតបញ្ជាក់សិទ្ធិតំណាងជាដើម។ ក្នុងករណីបើមានចំនុចខ្វះខាត ក្រឡាបញ្ជីគួរ (មិនមែនជាកាតព្វកិច្ចទេ) ប្រាក់ដើមចោទឱ្យកែតម្រូវ តែពុំមានសិទ្ធិមិនទទួលពាក្យបណ្តឹង ឬ លើកចោលពាក្យបណ្តឹងទេមានតែចៅក្រមទេដែលមានសិទ្ធិសម្រេច។

• ឯកសារភ្ជាប់ជាមួយពាក្យបណ្តឹង

- លិខិតចម្លងនៃពាក្យបណ្តឹង
- លិខិតចម្លងនៃឯកសារភស្តុតាង
- ឯកសារ បញ្ជាក់សិទ្ធិតំណាង

• ពន្ធដាក់ពាក្យសុំ និងប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ

- ពន្ធដាក់ពាក្យសុំកំណត់ទៅតាមទំហំកម្មវត្ថុនៃពាក្យបណ្តឹង[58]

[55] មាត្រា ៧៥ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[56] មាត្រា ៧៥ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[57] មាត្រា ៨ និងមាត្រា ៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[58] មាត្រា ៦១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

- ការជួយសង្គ្រោះពន្ធលើពាក្យបណ្តឹង[59]
- ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ[60] សម្រាប់ពិនិត្យភស្តុតាង បញ្ជូនឯកសារ និងសោហ៊ុយធ្វើដំណើរ

### ១.៦.៣. ការពិនិត្យពាក្យបណ្តឹង

ការពិនិត្យពាក្យបណ្តឹងជាការពិនិត្យលើចំណុចដែលត្រូវសរសេរតាម មាត្រា ៧៥ កថា.២ ចំណុច ក និង ខ និងពន្ធដាក់ពាក្យសុំបង់ហើយ ឬ នៅ។[61] ការពិនិត្យនេះ គឺដើម្បីចេញដីកាបង្គាប់ឱ្យកែតម្រូវ និងដីកាសម្រេចលើកពាក្យបណ្តឹងចោល។[62] ការពិនិត្យពាក្យបណ្តឹងដើម្បីដឹកនាំរឿងក្តីឱ្យបានឆាប់រហ័ស។

### ១.៦.៤. ការកំណត់កាលបរិច្ឆេទត្រៀមសម្រាប់ការទាញហេតុផល

ក្រោយពីពិនិត្យពាក្យបណ្តឹង បើយល់ឃើញថាពាក្យបណ្តឹងស្របច្បាប់ តុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងចេញដីកាកោះហៅភាគីទាំងសងខាងឱ្យបង្ហាញខ្លួននៅតុលាការតាមកាលបរិច្ឆេទដែលបានកំណត់។ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជានីតិវិធីនៃការត្រៀមរៀបចំសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ដើម្បីធានាបាននូវយុត្តិធម៌ និងសម្រួលដល់ការជម្រះក្តីនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់។[63] **ម៉្យាងទៀតនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជាដំណាក់កាលដើមមួយនៃនីតិវិធីរដ្ឋប្បវេណីដែលធ្វើឡើងដើម្បីផ្តល់ឱកាសដល់តុលាការ ក្នុងការរៀបចំនូវសេចក្តីអះអាងរបស់គូភាគី បំភ្លឺនូវចំណុចវិវាទនៃរឿងក្តីដែលគូភាគីមិនយល់ស្របគ្នា និងរៀបចំនូវភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនៃរឿងក្តីនោះ ដើម្បីធ្វើការវិនិច្ឆ័យរឿងក្តីនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ឱ្យបានល្អិតល្អន់។** ក្នុងន័យនេះគឺធ្វើឡើងដើម្បីរៀបចំនូវចំណុចវិវាទនៃរឿងក្តី ភស្តុតាង និងដើម្បីរៀបចំនូវចំណុចវិវាទ ឬកុំឱ្យមានភាពស្មុគស្មាញលើចំណុចវិវាទ។[64]

### ១.៧. សារៈប្រយោជន៍

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺផ្តល់នូវសារៈប្រយោជន៍ជាច្រើនសម្រាប់នីតិវិធីនៃដំណើរការរឿងក្តីរដ្ឋប្បវេណី។ នីតិវិធីនេះគឺផ្តល់សមភាព និងភាពយុត្តិធម៌ដល់ភាគីនៃវិវាទ តាមរយៈការជួបគ្នា

[59] មាត្រា ៦៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[60] មាត្រា ៦២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[61] មាត្រា ៦១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[62] មាត្រា ៧៨ កថាខណ្ឌទី ១ និងកថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[63] ក្រសួងយុត្តិធម៌,សេចក្តីពន្យល់នៃក្រមនីតិវិធីរដ្ឋប្បវេណី, ឆ្នាំ២០០៧។
[64] ប៉ោ ហ៊ុយ មេធាវី, ព្រឹត្តិបត្រមេធាវីលេខ ២០, ខែមករា ឆ្នាំ២០១៩។

ផ្ទាល់ក្នុងពេលវេលាតែមួយ និងទីកន្លែងតែមួយ ដើម្បីអះអាងអំពីអង្គហេតុ និងដាក់ភស្តុតាងជូនតុលាការ។ មួយវិញទៀត នីតិវិធីនេះអាចធ្វើឱ្យការជម្រះក្តីនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់មិនមានភាពស្មុគស្មាញ ពីព្រោះតុលាការអាចស្នើឱ្យភាគីដកការអះអាង អំពីអង្គហេតុណាដែលមិនមានសារៈប្រយោជន៍ចំពោះការសម្រេចសេចក្តី និងអាចលើកចោលនូវអង្គហេតុណាដែលភាគីធ្វើការអះអាងដូចគ្នា ដោយចាត់ទុកថាជាអង្គហេតុដែលពុំមានវិវាទ។ ការដែលនាំឱ្យមានភាពស្មុគស្មាញគឺថានៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ភាគីនីមួយៗ តែងតែលើកឡើងនូវអង្គហេតុផ្សេងៗដែលខ្លួនយល់ឃើញថាមានសារៈប្រយោជន៍សម្រាប់ខ្លួនឯង ដោយពុំបានគិតថាអង្គហេតុទាំងនោះមាន ឬ គ្មានសារៈសំខាន់ចំពោះរឿងក្តីនោះទេ។ ស្របពេលជាមួយគ្នានេះផងដែរ ភាគីនីមួយៗតែងតែតវ៉ាចំពោះការលើកឡើងនូវអង្គហេតុទាំងអស់របស់ភាគីម្ខាងទៀត ហើយព្យាយាមដាក់ភស្តុតាងទាំងឡាយណាដែលខ្លួនគិតថាមានប្រយោជន៍សម្រាប់ខ្លួនឯង។ ក៏ប៉ុន្តែការធ្វើបែបនេះនឹងនាំឱ្យមានភាពស្មុគស្មាញ និងអូសបន្លាយពេលវេលាដោយឥតប្រយោជន៍ និងធ្វើឱ្យមានការលំបាកក្នុងការស្វែងរកការពិត។

## ១.៨. ភាពចាំបាច់

នៅក្នុងនីតិវិធីរដ្ឋប្បវេណី មិនអាចដំណើរការបានដោយមិនមាននីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះទេ លុះត្រាតែមានបញ្ញត្តិពិសេសពីព្រោះនីតិវិធីមួយនេះពិតជាសំខាន់ និងមានភាពចាំបាច់ក្នុងការជួយសម្រួលដល់កិច្ចនីតិវិធីឱ្យមានភាពច្បាស់លាស់ និងបានល្អិតល្អន់មុននឹងឈានដល់នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់។ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលជានីតិវិធីដែលគូភាគីនៃវិវាទបានជួបនិយាយគ្នាដោយផ្ទាល់ និងបានលើកយកបញ្ហា ព្រមទាំងដាក់នូវភស្តុតាងនៅចំពោះមុខចៅក្រម និងអមដោយក្រឡាបញ្ជីដើម្បីបានស្វែងយល់ពីចំណុចវិវាទពិតប្រាដក និងខ្លឹមសារសាលក្រមដែលដើមចោទទាមទារឱ្យតុលាការសម្រេច និងការបដិសេធរបស់ចុងចម្លើយចំពោះការទាមទាររបស់ដើមចោទមកកាន់ខ្លួន។ ប៉ុន្តែចំពោះរឿងក្តីចំនួនទឹកប្រាក់តិចដែលមានគោលបំណងដោះស្រាយវិវាទឱ្យបានឆាប់រហ័សតាមនីតិវិធីសង្ខេប ដោយតុលាការត្រូវកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ភ្លាម បន្ទាប់ពីទទួលបានពាក្យបណ្តឹងដោយមិនចាំបាច់ឆ្លងកាត់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះទេ។[65]

## ១.៩. គោលបំណង

នៅពេលចាប់ផ្តើមធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការមានគោលបំណងដើម្បីអាចពិនិត្យឃើញថាអង្គហេតុដែលបានសរសេរនៅក្នុងពាក្យបណ្តឹងក៏ដូចជានៅក្នុងឯកសារត្រៀមមានភាពមិនច្បាស់លាស់ តុលាការអាចសាកសួរភាគី ឬ ឱ្យភាគីអះអាង ឬ បញ្ជាក់នូវភស្តុតាងចំពោះចំណុចនោះនៅកាលបរិច្ឆេទនៃនីតិ

[65] មាត្រា ២២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦។

វិធីត្រៀមសម្រាប់ការទាញហេតុផលបាន។ ភាពច្បាស់លាស់នៃអង្គហេតុ និងអង្គច្បាប់ដែលទាក់ទងនឹងបណ្តឹងគឺជាចំណុចសំខាន់ណាស់ពីព្រោះថាការអះអាង អំពីអង្គហេតុនោះនឹងក្លាយជាមូលដ្ឋានសម្រាប់តុលាការចេញសាលក្រម ម៉្យាងទៀតនេះគឺជាកាតព្វកិច្ចរបស់គូភាគីដែលត្រូវធ្វើការអះអាង។[66] ដើម្បីឱ្យភាគីអាចបំពេញនូវកាតព្វកិច្ចរបស់ខ្លួនបាននោះ តុលាការអាចសួរអំពីចំណុចមិនច្បាស់លាស់នៃអង្គហេតុដែលភាគីបានអះអាងនេះជាសិទ្ធិរបស់តុលាការ។[67]

ហេតុដូច្នេះហើយមុននឹងចាប់ផ្តើមធ្វើការទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវជួបជាមួយភាគីទាំងសងខាង ដើម្បីរៀបចំសេចក្តីអះអាងរបស់ភាគី និងត្រូវបំភ្លឺនូវចំណុចវិវាទ តាមវិធីសាស្ត្រដូចតទៅ ៖ (១) ស្នើឱ្យភាគីដកការអះអាងអំពីអង្គហេតុដែលមិនមានប្រយោជន៍ចំពោះការសម្រេចអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិដែលជាកម្មវត្ថុនៃបណ្តឹង និងលើកចោលនូវអង្គហេតុទាំងឡាយណាដែលភាគីធ្វើការអះអាងដូចគ្នាចំពោះចំណុចជាសារវ័ន្តនៃការពិនិត្យភស្តុតាងដោយចាត់ទុកថាជាអង្គហេតុដែលពុំមានវិវាទ (២) ជាងនេះទៅទៀតចំពោះភស្តុតាងដែលត្រូវពិនិត្យទាក់ទងនឹងចំណុចវិវាទ តុលាការត្រូវធានាឱ្យបាននូវការពិនិត្យដោយសម្ហវិធីដោយត្រូវយកចិត្តទុកដាក់តែទៅលើភស្តុតាងដែលសំខាន់ និងមានតម្លៃតែប៉ុណ្ណោះ។[68]

យោងតាមគោលការណ៍នៃក្រមនីតិវិធីរដ្ឋប្បវេណី នីតិវិធីស៊ើបសួរដែលធ្លាប់បានអនុវត្តពីមុនអាចខុសនឹងគោលការណ៍ជាមូលដ្ឋាននៃបណ្តឹងទាំងនេះ។ ហេតុនេះហើយបានជាក្រមនីតិវិធីរដ្ឋប្បវេណីចែងថា នីតិវិធីស៊ើបសួរដែលបានអនុវត្តពីមុនត្រូវលុបចោល។[69] នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជានីតិវិធីដែលត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចមានវត្តមានបាន។[70]ចំណែកឯនៅក្នុងនីតិវិធីស៊ើបសួរ តុលាការធ្វើការសាកសួរភាគី និងសាក្សីដោយឆន្ទានុសិទ្ធិរបស់ខ្លួន ដោយមិនបើកចំហជាសាធារណៈទេ ហើយតាមរយៈការធ្វើបែបនេះ តុលាការអាចក្តាប់បានច្បាស់នូវទំនាក់ទំនងអង្គហេតុនៅក្នុងរឿងក្តីនោះ។ អាស្រ័យហេតុនេះចំពោះនីតិវិធីស៊ើបសួរនៅពេលតុលាការធ្វើការសាកសួរភាគីម្ខាងមិនចាំបាច់មានវត្តមានរបស់ភាគីម្ខាងទៀតទេហើយនៅពេលសាកសួរសាក្សី ក៏មិនចាំបាច់មានវត្តមានរបស់ភាគីណាមួយដែរ។[71] ដូច្នេះនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលមានលក្ខណៈខុសគ្នាពីនីតិវិធីស៊ើបសួរត្រង់គោលបំណង និងខ្លឹមសារនៃនីតិវិធីនោះដែល

[66] មាត្រា ៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[67] មាត្រា ៩០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[68] មាត្រា ១២៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[69] សេចក្តីពន្យល់ក្រមនៃនីតិវិធីរដ្ឋប្បវេណី, ទំព័រទី ៧៦ ឆ្នាំ២០០៦។

[70] មាត្រា ១០៥ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[71] សេចក្តីពន្យល់ក្រមនៃនីតិវិធីរដ្ឋប្បវេណី, ទំព័រទី ៧៥, ឆ្នាំ២០០៦។

មិនត្រូវផ្ទុយនឹងគោលការណ៍នៃការជម្រះក្ដីជាសាធារណៈ ការធានាសិទ្ធិរបស់ភាគីក្នុងការទាមទារឱ្យសាកសួរ និងជាពិសេសគឺគោលការណ៍ចំពោះមុខ។

# ជំពូកទី ២
# ដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

# ជំពូកទី ២
# ដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ជាគោលការណ៍ សិទ្ធិអំណាចក្នុងការដឹកនាំនីតិវិធីនៃបណ្ដឹង គឺជាសិទ្ធិអំណាចរបស់តុលាការ ហើយត្រូវអនុវត្តដោយតុលាការ។ ដើម្បីឱ្យនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលអាចអនុវត្តបាន តុលាការត្រូវរៀបចំកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលជាមុនសិន (២.១) ហើយត្រូវធ្វើការកោះហៅគូភាគី (២.២) បន្ទាប់មកទៀតត្រូវធ្វើការសាកល្បងផ្សះផ្សា (២.៣) និងត្រូវប្រព្រឹត្តទៅដោយមានសកម្មភាពច្បាស់លាស់ (២.៤)។

## ២.១. កាលបរិច្ឆេទ

ការកំណត់ពេលវេលានៃដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មានភាពចាំបាច់ណាស់ ព្រោះដើម្បីឱ្យតុលាការមានពេលវេលាជាក់លាក់ និងគ្រប់គ្រាន់ក្នុងការចាប់ផ្ដើមនីតិវិធីបន្ទាប់ពីបានទទួលពាក្យបណ្ដឹងរបស់ដើមចោទ ព្រមទាំងកំណត់យកពេលវេលាមួយដែលគូភាគីនៃវិវាទអាចចូលរួមបានទាំងសងខាង។ ដោយហេតុថា នៅក្នុងកិច្ចនីតិវិធីនេះគឺផ្ដោតសំខាន់ទៅលើគោលការណ៍ចំពោះមុខ ដូចនេះពេលវេលានៃការសាកសួរគូភាគីវិវាទ គឺត្រូវប្រាដកថាជាពេលវេលាមួយដែលគូភាគីវិវាទទាំងសងខាងអាចចូលរួមបាន។

### ២.១.១. ការកំណត់កាលបរិច្ឆេទដោយតុលាការ

តុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូងក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីថ្ងៃដែលពាក្យបណ្ដឹងត្រូវបានដាក់។[72]

ការកំណត់បែបនេះ គឺដើម្បីឱ្យចុងចម្លើយមានពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំការការពារខ្លួន និងជៀសវាងការចាប់ផ្ដើមនីតិវិធីមានការយឺតយ៉ាវ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ តុលាការអាចធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន ទោះបីជាភាគីម្ខាងមិនមានវត្តមានក៏ដោយ ក្នុងករណីដែលតុលាការបានបញ្ជូនដីកាកោះ និងបានផ្ដល់ឱកាសឱ្យភាគីនោះបង្ហាញខ្លួនជាច្រើនដង តែភាគីនោះមិនបានបង្ហាញខ្លួនតាមពេលវេលាកំណត់របស់តុលាការ ដោយមិនមានមូលហេតុសមរម្យ នោះតុលាការអាចដំណើរការនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ ដោយមិនមានវត្តមានរបស់ភាគីម្ខាងទៀតនោះបាន ដើម្បីការពារនូវផលប្រយោជន៍របស់ភាគីម្ខាងទៀតដែលមកបង្ហាញខ្លួន និងដើម្បីទប់ស្កាត់នូវការអូសបន្លាយពេលវេលានៃកិច្ចនីតិវិធី។

[72] មាត្រា ៨០ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលមិនចាំបាច់បើកជាសាធារណៈទេ។ [73] នេះគឺដោយសារតែនៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការគ្រាន់តែធ្វើការកំណត់នូវចំណុចវិវាទតាមរយៈការរៀបចំការអះអាងរបស់ភាគី និង រៀបចំនូវភស្តុតាងដែលត្រូវពិនិត្យតែប៉ុណ្ណោះ។ លើសពីនេះទៅទៀត នៅក្នុងករណីជាច្រើនការធ្វើនីតិវិធីនេះ នៅក្រៅសាលសវនាការត្រូវបានចាត់ទុកថាជាការសមស្របដូចជាធ្វើនៅក្នុងបន្ទប់របស់ចៅក្រមជាដើម។

ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយតុលាការអាចអនុញ្ញាតឱ្យជនដែលខ្លួនយល់ឃើញថាសមរម្យ ដូចជាសមាជិកគ្រួសាររបស់ភាគី ឬ ជនដែលមានផលប្រយោជន៍ពាក់ព័ន្ធដទៃទៀតចូលស្តាប់ជាអ្នកសង្កេតការណ៍បាន។[74] ម្យ៉ាងទៀតលទ្ធផលដែលបានធ្វើនៅក្នុងដំណាក់កាលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ ភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ និងត្រូវបំភ្លឺអំពីបញ្ហាទាំងអស់នេះនៅក្នុងសវនាការជាសាធារណៈ។[75] ចំពោះការអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យអ្នកសង្កេតការណ៍ចូលស្តាប់ គឺជាឆន្ទានុសិទ្ធិរបស់តុលាការ។ នៅពេលធ្វើការសម្រេចអំពីការអនុញ្ញាត ឬ មិនអនុញ្ញាតនេះតុលាការត្រូវពិចារណាអំពីមូលហេតុនៃការស្នើសុំចូលស្តាប់ ព្រមទាំងមតិរបស់ភាគីផងដែរ។ ក្នុងករណីដែលការស្នើសុំចូលស្តាប់ត្រូវបានធ្វើឡើងដោយបុគ្គលដែលមានការពាក់ព័ន្ធទៅនឹងរឿងក្តី ជាគោលការណ៍តុលាការអាចផ្តល់ការអនុញ្ញាតចំពោះការស្នើសុំនោះបាន ប្រសិនបើការចូលស្តាប់នោះមិនទំនងជានឹងបង្កបញ្ហាដល់ការជម្រះក្តីទេ។ ប៉ុន្តែក្នុងករណីដែលយល់ឃើញថា ភាគីណាម្ខាងអាចរងការប៉ះពាល់ផ្លូវចិត្តដោយសារតែវត្តមានរបស់បុគ្គលដែលពាក់ព័ន្ធនោះតុលាការមិនត្រូវអនុញ្ញាតឱ្យបុគ្គលនោះចូលស្តាប់ទេ។ តុលាការត្រូវបង្គាប់ឱ្យក្រឡាបញ្ជីធ្វើកំណត់ហេតុនៅរាល់កាលបរិច្ឆេទនីមួយៗនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ( កំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល )។[76]

### ២.១.២. ការកំណត់កាលបរិច្ឆេទជាថ្មី

ការប្តូរកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលមិនត្រូវបានអនុញ្ញាតទេ លើកលែងតែមានមូលហេតុពិសេសមិនអាចជៀសវាងបានដូចជា ភាគីមានជំងឺមិនអាចចូលរួមបានជាដើម។ [77] ប៉ុន្តែប្រសិនបើមានការព្រមព្រៀងពីសំណាក់គូភាគី ការប្តូរកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

[73] មាត្រា ១០៥ កថាខណ្ឌទី ២ វាក្យខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[74] មាត្រា ១០៥ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[75] មាត្រា ១១៦ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[76] មាត្រា ១០៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[77] មាត្រា ២៤១ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

លើកដំបូងអាចអនុញ្ញាតប្តូរបាន។[78] ដោយសារតែនៅពេលដែលដើមចោទបានដាក់ពាក្យបណ្តឹងទៅតុលាការ ហើយតុលាការបានកំណត់កាលបរិច្ឆេទលើកដំបូងនេះ បន្ទាប់ពីពិនិត្យពាក្យបណ្តឹងរួច ដោយមិនបានទាក់ទងទៅចុងចម្លើយជាមុន ហេតុនេះហើយដើម្បីការពារផលប្រយោជន៍ចុងចម្លើយតុលាការត្រូវទុករយៈពេលសមរម្យមួយ ដើម្បីឱ្យចុងចម្លើយអាចត្រៀមខ្លួនបាន។[79] នៅពេលផ្លាស់ប្តូរ កាលបរិច្ឆេទ តុលាការត្រូវបញ្ជាក់ប្រាប់ទៅគូភាគីហើយត្រូវកំណត់នូវកាលបរិច្ឆេទថ្មីមួយទៀតដែលគូភាគីអាចចូលរួមបាន។ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះមិនសំដៅទៅលើន័យថាតុលាការត្រូវធ្វើការស៊ើបសួរដោយសកម្មទៅលើបណ្តឹងនោះទេ គឺមានន័យថាត្រឹមតែឱ្យគូភាគីបំភ្លឺចំណុចវិវាទរបស់ខ្លួនដែលបានលើកឡើងមិនស្របគ្នាប៉ុណ្ណោះ និងធ្វើកិច្ចការត្រៀមមួយចំនួនដូចជា ការដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន។

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលពុំអនុញ្ញាតឱ្យមានការសាកសួរទៅលើសាក្សី និងទៅលើភាគីទេ ប៉ុន្តែតុលាការអាចចេញដីកាសម្រេចដែលទាក់ទងនឹងការស្នើសុំឱ្យពិនិត្យភស្តុតាង និងអាចពិនិត្យភស្តុតាងជាឯកសារបាន។ ចំណុចនេះមិនមែនមានន័យថាតុលាការអាចធ្វើការសាកសួរទៅលើភស្តុតាងជាបុគ្គលផ្ទាល់ខ្លួននោះបានទេតែមានន័យដូចជា ការអានឯកសារភស្តុតាងនោះដោយចៅក្រមជាដើម ព្រោះថាដើម្បីរៀបចំនូវចំណុចវិវាទនៃរឿងក្តីឱ្យបានត្រឹមត្រូវភាគច្រើនតុលាការត្រូវរកភស្តុតាងជាឯកសារ ដូចនេះហើយបានជា ច្បាប់អនុញ្ញាតឱ្យតុលាការពិនិត្យភស្តុតាងជាឯកសារក្នុងកម្រិតចាំបាច់ដើម្បីរៀបចំនូវចំណុចវិវាទនៃរឿងក្តីប៉ុណ្ណោះ។[80]

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល អាចផ្តល់ឱ្យតុលាការទទួលបាននូវព័ត៌មានទាក់ទងនឹងចំណុចវិវាទដូចតទៅ :

(ក) ការអះអាង និងការទាមទាររបស់ភាគី។

(ខ) ភាគីទទួលស្គាល់ចំណុចណាខ្លះ និងចំណុចណាខ្លះដែលមិនទទួលស្គាល់។

(គ) ចំណុចដែលមានវិវាទត្រូវបញ្ជាក់ដោយភស្តុតាងណាខ្លះ។

ដើម្បីរៀបចំ និងគ្រប់គ្រងការអះអាងរបស់ភាគី និងបំភ្លឺនូវចំណុចវិវាទនៃរឿងក្តីដែលគូភាគីមិនយល់ស្របគ្នានោះជាកត្តាចាំបាច់ និងសំខាន់ដែលត្រូវស្តាប់នូវការអះអាងរបស់ភាគីទាំងពីរដោយផ្ទាល់។ អ្វីដែលភាគីទាំងពីរបាននិយាយក្នុងដំណាក់កាលនេះគឺជាការអះអាងវាមិនមែនជាភស្តុតាងនៃរឿងក្តីទេ។[81] តុលាការក៏អាច

[78] មាត្រា ២៤១ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[79] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ទំព័រទី២២១, ឆ្នាំ២០០៧។

[80] មាត្រា ១០៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[81] មាត្រា ១០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

ពន្យារកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន ប្រសិនបើយល់ឃើញថា អំឡុងពេលនៃការកោះហៅមានរយៈពេលខ្លីពេក ឬ យល់ឃើញថាភាគីមិនអាចមកបង្ហាញខ្លួនបានដោយគ្មានកំហុស។

## ២.២. ការកោះហៅគូភាគី

មុននឹងធ្វើការកោះហៅគូភាគី តុលាការនឹងបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្ដីជាមុនសិន ដើម្បីធ្វើជាសោហ៊ុយក្នុងការកោះហៅគូភាគី។ នៅក្នុងការកោះហៅតុលាការត្រូវបង្គាប់ឱ្យដើមចោទបង់ប្រាក់ជាមុនសិនសម្រាប់ធ្វើការកោះហៅ និងត្រូវអនុវត្តវិធីកោះហៅឱ្យបានត្រឹមត្រូវ។ ដោយសារតែវិវាទរដ្ឋប្បវេណីនេះ គឺជាវិវាទរវាងបុគ្គលឯកជន និងបុគ្គលឯកជន ហេតុនេះនៅក្នុងនីតិវិធីបណ្ដឹងទើបភាគីដើមចោទដែលដាក់ពាក្យបណ្ដឹងត្រូវបង់ប្រាក់ប្រដាប់ក្ដីសម្រាប់ធ្វើការកោះហៅ។ [82] ក្នុងករណីតុលាការបានបង្គាប់ឱ្យដើមចោទបង់ប្រាក់ជាមុនដែលចាំបាច់សម្រាប់ការកោះហៅដោយកំណត់អំឡុងពេលសមរម្យតែប្រសិនបើដើមចោទមិនបានបង់ប្រាក់ជាមុនទេ នោះតុលាការអាចលើកបណ្ដឹងចោលដោយដីកាសម្រេចបាន ប៉ុន្តែបើមានការតវ៉ាពីចុងចម្លើយតុលាការមិនអាចលើកបណ្ដឹងចោលបានឡើយ។ ដោយហេតុថា ការលើកបណ្ដឹងនេះចោលធ្វើឱ្យប៉ះពាល់ផលប្រយោជន៍របស់ភាគីចុងចម្លើយ ដូចជាចុងចម្លើយចង់បានសាលក្រមបញ្ជាក់ពីអង្គហេតុជាដើម។ ដោយចុងចម្លើយត្រូវបង់ប្រាក់ប្រដាប់ក្ដីឱ្យតុលាការសម្រាប់ធ្វើការកោះហៅភាគីជំនួសដើមចោទវិញ។ ចំពោះដីកាសម្រេចលើកបណ្ដឹងចោលភាគីអាចប្ដឹងជំទាស់បាន។ [83] ប្រសិនបើដើមចោទបានបង់ប្រាក់ប្រដាប់ក្ដីតាមការបង្គាប់របស់តុលាការរួចហើយ តុលាការនឹងរៀបចំកោះហៅភាគី។

ការកោះហៅតាមកាលបរិច្ឆេទត្រូវធ្វើដោយការបញ្ជូនដីកាកោះ ឬ ដោយការជូនដំណឹងអំពីកាលបរិច្ឆេទទៅអ្នកដែលបានបង្ហាញខ្លួននៅតុលាការចំពោះបណ្ដឹងដែលពាក់ព័ន្ធ។ [84] ហេតុដូចនេះវិធីកោះហៅអាចធ្វើតាម៖

- ការជូនដំណឹងអំពីកាលបរិច្ឆេទ

ការជូនដំណឹង គឺជាវិធីដែលមានលក្ខណៈទូលាយ និងងាយស្រួលជាងវិធីនៃការបញ្ជូនដោយអ្នកប្រតិបត្តិការបញ្ជូនអាចប្រើប្រាស់គ្រប់មធ្យោបាយបាន។ ចំពោះការជូនដំណឹងអំពីកាលបរិច្ឆេទទៅអ្នកដែលបានបង្ហាញខ្លួននៅតុលាការចំពោះបណ្ដឹងដែលពាក់ព័ន្ធគឺ តុលាការត្រូវប្រាប់ដោយផ្ទាល់មាត់អំពីកាលបរិច្ឆេទនោះ។ ក្រៅពីនេះមាននីតិវិធីផ្សេងទៀតដែលងាយស្រួលដូចជាធ្វើការប្រកាសតាមទូរស័ព្ទ អ៊ីមែល ប្រៃសណីយ៍ តាម

[82] មាត្រា ៦២ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[83] មាត្រា ៨២ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[84] មាត្រា ២៤២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

សំបុត្រធម្មតា តាមរយៈបុគ្គលិកនៃការិយាល័យមេធាវីជាដើម ដើម្បីឱ្យអ្នកត្រូវទទួលការបញ្ជូនបានដឹងហើយ ក្នុងនោះនីតិវិធីនៃការបញ្ជូនក៏ជាមធ្យោបាយមួយនៃការជូនដំណឹងដែរ។

- ការបញ្ជូន

ការបញ្ជូន គឺជាការជូនដំណឹងដែលធ្វើឡើងតាមនីតិវិធីដែលច្បាប់បានកំណត់ដើម្បីជូនដំណឹងអំពីខ្លឹមសារនៃឯកសារតាមផ្លូវបណ្តឹងចំពោះភាគី និងអ្នកដទៃទៀតដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍។ ប៉ុន្តែនីតិវិធីនេះត្រូវធ្វើឡើងតាមច្បាប់កំណត់ដោយត្រូវតែមានរបាយការណ៍ស្តីពីការបញ្ជូន។ កិច្ចការបញ្ជូនត្រូវធ្វើឡើងដោយក្រឡាបញ្ជី។ ក្រឡាបញ្ជី ជាមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនហើយចាត់ចែងការបញ្ជូនដោយប្រគល់អំណាចនៃការបញ្ជូនឯកសារទៅឱ្យមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន។ មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនរួមមាន៖

- បុគ្គលិកប្រៃសណីយ៍
- អាជ្ញាសាលា
- និងក្រឡាបញ្ជីខ្លួនឯង។[85]

នៅពេលធ្វើការបញ្ជូនដីកាកោះរួចហើយ មន្ត្រីប្រតិបត្តិការបញ្ជូនត្រូវធ្វើរបាយការណ៍ស្តីពីការបញ្ជូនដីកាកោះនោះជូនទៅតុលាការ។[86]

នៅក្នុងរបាយការណ៍ដែលត្រូវជូនទៅតុលាការនេះ ត្រូវមានការបញ្ជាក់អំពីចំណុចដូចតទៅ៖

- សញ្ញាណនៃរឿងក្តី និងឯកសារដែលបានបញ្ជូន។
- ជនដែលត្រូវទទួលការបញ្ជូន។
- ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងដែលបានធ្វើការបញ្ជូន។
- វិធីបញ្ជូន។
- ក្នុងករណីដែលអ្នកទទួលការបញ្ជូនមិនចេះអក្សរ មន្ត្រីទទួលបន្ទុកការបញ្ជូន គប្បីពន្យល់នូវខ្លឹមសារនៃឯកសារនោះនៅពេលប្រគល់ឯកសារ។
- ហត្ថលេខា ឬ ស្នាមមេដៃរបស់អ្នកដែលបានទទួលឯកសារ។
- ហេតុការណ៍ដែលមិនព្រមទទួលការបញ្ជូន នៅក្នុងករណីជនដែលត្រូវទទួលការបញ្ជូន ឬអ្នកដែលត្រូវទទួលការប្រគល់ឯកសារមិននៅទីតាំងដែលត្រូវបញ្ជូនទេ មន្ត្រីទទួលបន្ទុកការបញ្ជូនអាចប្រគល់

[85] មាត្រា ២៤៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[86] មាត្រា ២៥៤ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

ឯកសារទៅឱ្យអ្នកបម្រើ ឬ អ្នកផ្សេងទៀតដែលធ្វើការនៅទីនោះ ឬ អ្នកនៅជាមួយដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារនោះបាន បានប្រកែកមិនព្រមទទួល។

- ហេតុការណ៍ដែលមានការប្រគល់ឯកសារទៅឱ្យអ្នកបម្រើ ឬ អ្នកផ្សេងដែលធ្វើការនៅទីនោះ ឬ អ្នកនៅជាមួយ ដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារនោះបាន ដោយសារជនដែលត្រូវទទួលការបញ្ជូនមិននៅកន្លែងដែលត្រូវបញ្ជូន ព្រមទាំងក្នុងករណីដែលអ្នកទាំងអស់គ្នាដែលរៀបរាប់នេះមិនព្រមទទួលការបញ្ជូនដោយគ្មានមូលហេតុត្រឹមត្រូវ គឺឯកសារនោះអាចទុកនៅកន្លែងដែលត្រូវបញ្ជូននោះបាន។

- ហត្ថលេខារបស់អ្នកដែលបានប្រតិបត្តិការបញ្ជូន។[87]

ក្នុងករណីដែលបានព្យាយាមបញ្ជូន តែមិនអាចសម្រេចបាន មន្ត្រីទទួលបន្ទុកការបញ្ជូនត្រូវធ្វើរបាយការណ៍អំពីហេតុការណ៍នោះ និងត្រូវបញ្ជាក់អំពីចំណុចមួយចំនួនដូចតទៅ៖

- សញ្ញាណនៃរឿងក្តី និងឯកសារដែលបានបញ្ជូន។
- ជនដែលត្រូវទទួលការបញ្ជូន។
- ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងដែលបានធ្វើការបញ្ជូន។
- វិធីបញ្ជូន។
- ហត្ថលេខារបស់អ្នកដែលបានប្រតិបត្តិការបញ្ជូន។[88]

### ២.៣. ការសាកល្បងផ្សះផ្សា

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវសាងល្បងធ្វើការផ្សះផ្សាជាដំបូងសិនលើកលែងតែក្នុងករណីដែលយល់ឃើញថាមិនសមរម្យ។ [89] ដោយសារតែនីតិវិធីរដ្ឋប្បវេណីមានគោលបំណងធ្វើការកំណត់អំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ និងកាតព្វកិច្ចតាមច្បាប់សារធាតុដែលអាចចាត់ចែងបានដោយផ្អែកលើការព្រមព្រៀងរវាងភាគី ដូច្នេះទោះបីជានៅពេលដែលនីតិវិធីបណ្តឹងត្រូវបានចាប់ផ្តើមហើយក៏ដោយ ប្រសិនបើភាគីបានកំណត់ថាសិទ្ធិ ឬ កាតព្វកិច្ចនោះមានអត្ថិភាព ឬ នត្ថិភាពតាមរយៈការសះជា ហើយភាគីសម្រេចចិត្តបញ្ចប់វិវាទនោះ គេអាចនិយាយបានថាវាគឺជាលទ្ធផលដែលគួរឱ្យចង់បាន។ ហេតុនេះហើយបានជា

[87] មាត្រា ២៥៤ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[88] មាត្រា ២៥៤ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[89] មាត្រា ១០៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

ក្រមនីតិវិធីរដ្ឋប្បវេណីចែងថា នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដែលជាសកម្មភាពដំបូងបំផុតនៃការជម្រះក្តីតុលាការអាចណែនាំឱ្យភាគីទាំងសងខាងសះជានឹងគ្នា។

### ២.៣.១. ករណីផ្សះផ្សាបាន

តាមរយៈការវិនិច្ឆ័យអំពីស្ថានភាពនៃបណ្តឹង តុលាការយល់ឃើញថាវិវាទនោះអាចដោះស្រាយដោយការផ្សះផ្សាបានតុលាការអាចសាកល្បងធ្វើការផ្សះផ្សា នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់តែម្តងក៏បាន គឺអាចសាកល្បងផ្សះផ្សាបានគ្រប់ដំណាក់កាលណាក៏បាន។[90] នៅពេលណែនាំឱ្យភាគីសះជាគ្នាតុលាការអាចប្រើវិធីមួយដោយឱ្យភាគីម្ខាងចេញពីបន្ទប់ហើយតុលាការស្តាប់ការអះអាងរបស់ភាគីម្ខាងទៀត និងធ្វើដូច្នេះម្តងទៀតចំពោះភាគីម្ខាងទៀត គេហៅថា "ការសួរឆ្លាស់គ្នា"។ ក៏ប៉ុន្តែបើប្រើវិធីនេះភាគីម្ខាងមិនអាចដឹងថាតើតុលាការ និងភាគីម្ខាងទៀតបានពិគ្រោះគ្នាពីរឿងអ្វីខ្លះនោះទេ ហើយគោលការណ៍នេះនឹងធ្វើឱ្យនីតិវិធីនៃការផ្សះផ្សាមានភាពមិនច្បាស់លាស់។ ហេតុដូច្នេះវិធីសាស្ត្រនេះអាចប្រើបានតែក្នុងករណីដែលមានការព្រមព្រៀងច្បាស់លាស់រវាងភាគី ក្នុងការធ្វើបែបនេះតែប៉ុណ្ណោះ។[91]

### ២.៣.២. ករណីមិនគួរផ្សះផ្សា

ក្នុងករណីដែលតុលាការយល់ឃើញថាការព្យាយាមសាកល្បងផ្សះផ្សាមិនសមរម្យទេ ដូចជាក្នុងករណីដែលសិទ្ធិ ឬ កាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹងគឺជា ប្រភេទនៃសិទ្ធិ ឬ កាតព្វកិច្ច ដែលមិនអាចចាត់ចែងបានដោយគ្រាន់តែផ្អែកលើការព្រមព្រៀងរបស់ភាគីប៉ុណ្ណោះទេ ឬ ក្នុងករណីដែលអាកប្បកិរិយារបស់ភាគីបង្ហាញយ៉ាងច្បាស់ថាពួកគេគ្មានឆន្ទៈធ្វើការផ្សះផ្សាទេ នោះតុលាការមិនចាំបាច់ណែនាំឱ្យភាគីសះជានឹងគ្នាឡើយ។[92]

## ២.៤. សកម្មភាពក្នុងដំណាក់កាលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ក្រមនីតិវិធីរដ្ឋប្បវេណីពុំបានកំណត់ថា នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះអាចធ្វើឡើងប៉ុន្មានដងនោះទេ ដូច្នេះអាចធ្វើឡើងច្រើនដងបាន គឺអាស្រ័យទៅតាមរឿងក្តី បើរឿងក្តីនោះស្មុគស្មាញ តុលាការអាចធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះច្រើនដង។ ផ្ទុយទៅវិញ ប្រសិនបើរឿងក្តីដែលមានលក្ខណៈងាយស្រួលនោះ នីតិវិធីត្រៀមសម្រាប់ទាញហេតុផល អាចធ្វើឡើងតែម្តងហើយបញ្ចប់។ ក្នុងន័យនេះគឺឱ្យតែតុលាការអាចកំណត់ចំណុចវិវាទនៃរឿងក្តីបាន។[93]

---

[90] មាត្រា ៩៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[91] សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី, មាត្រា ១០៤ ទំព័រទី ១០៣, ឆ្នាំ ២០០៧។

[92] មាត្រា ១០៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[93] យឹម សារី សៀវភៅស្តីពី "ការវិភាគក្រមនីតិវិធីរដ្ឋប្បវេណីក្នុងនីតិវិធីបណ្តឹង"ទំព័រទី ១៨ ឆ្នាំសិក្សា២០២២-២០២៣។

សកម្មភាពដែលត្រូវធ្វើនៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលមានដូចតទៅ៖

### ២.៤.១. ការដាក់សំណូមពរ និងការឆ្លើយតប

ជាទូទៅអ្វីដែលជាសំណូមពរ (ការទាមទារ) របស់ដើមចោទត្រូវបានបង្ហាញឱ្យឃើញនូវក្នុងពាក្យបណ្តឹងដែលបានសរសេរនូវចំណុចខ្លឹមសារនៃសាលក្រម ដែលដើមចោទទាមទារឱ្យតុលាការចេញ។ ផ្តើមពីចំណុចនេះ តុលាការអាចកំណត់បានអំពីសកម្មភាពដែលត្រូវធ្វើនៅក្នុងកាលបរិច្ឆេទដូចជាការផ្សះផ្សា ឬការថ្លែងការណ៍របស់ដើមចោទចំពោះការទាមទាររបស់ខ្លួន។ ដោយអាចដឹងបានអំពីបញ្ហានៅក្នុងពាក្យបណ្តឹង នោះតុលាការពុំចាំបាច់ឱ្យដើមចោទថ្លែងការណ៍អំពីពាក្យបណ្តឹងម្តងទៀតទេ។ ប្រសិនបើចុងចម្លើយ បានដាក់ឯកសារចម្លើយ ឆ្លើយតបចំពោះការទាមទាររបស់ដើមចោទ ដូចជាការស្នើសុំឱ្យតុលាការចេញសាលក្រមលើកចោលនូវការទាមទាររបស់ដើមចោទ ដោយអះអាងអំពីកង្វះលក្ខខណ្ឌនៃបណ្តឹង ឬ ការទាមទារគ្មានមូលហេតុត្រឹមត្រូវ នោះឯកសារនេះគឺជាការឆ្លើយតប ចំពោះសំណូមពររបស់ដើមចោទ។

### ២.៤.២. ការដាក់ឯកសារត្រៀម

ឯកសារត្រៀម គឺជាឯកសារដែលសរសេរអំពីមធ្យោបាយតទល់ ឬ ការពារខ្លួនដែលភាគីនឹងយកទៅអះអាងចំពោះមុខតុលាការ។ ម្យ៉ាងវិញទៀតឯកសារត្រៀមជាឯកសារផ្ទុកនូវចំណុចជាក់លាក់សម្រាប់ការពារការទាមទារ ឬ តទល់រវាងភាគី។ ឯកសារត្រៀម មានសារៈសំខាន់សម្រាប់ដំណើរការដោះស្រាយបណ្តឹងឱ្យឆាប់រហ័ស ដោយហេតុថាតុលាការពឹងផ្អែកទៅលើឯកសារទាំងនោះ ដើម្បីរៀបចំនូវចំណុចវិវាទនៃរឿងក្តី អង្គហេតុដែលមាន ឬ គ្មានវិវាទដើម្បីឈានទៅដំណាក់កាលបន្ទាប់នៃនីតិវិធី។[94]

នៅពេលធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងការទាញហេតុផលដោយផ្ទាល់មាត់ តុលាការអាចបង្គាប់ឱ្យភាគីដាក់ឯកសារត្រៀមបាន។[95] ក្នុងន័យនេះ ការដាក់ឯកសារត្រៀមមិនមែនដាច់ខាតត្រូវតែដាក់នោះទេ ចំពោះឯកសារឆ្លើយតបក៏ដូចគ្នាដែរ។ ឧទាហរណ៍៖ ភាគីពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើឯកសារត្រៀម នោះមានតែឱ្យភាគីធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់នៅកាលបរិច្ឆេទ។ ប៉ុន្តែដើម្បីឱ្យភាគីតតាំងគ្នាបានរលូននៅក្នុងកាលបរិច្ឆេទ ហើយការជំនុំជម្រះមានប្រសិទ្ធភាពល្អ ភាគីដែលមានសមត្ថភាពធ្វើឯកសារត្រៀម គួរតែបង្គាប់ឱ្យភាគីនោះដាក់ឯកសារត្រៀមមុនកាលបរិច្ឆេទ។ នៅក្នុងឯកសារត្រៀមត្រូវមានសរសេរអំពី

[94] ក្រសួងយុត្តិធម៌ សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី, មាត្រា ១០១, ទំព័រទី ១០០, ឆ្នាំ២០០៧។

[95] មាត្រា ១០១ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

មធ្យោបាយតទល់ ឬ ការពារខ្លួន និងសេចក្តីថ្លែងការណ៍ចំពោះមធ្យោបាយតទល់ ឬ ការពារខ្លួនរបស់ភាគីម្ខាងទៀត។[96]

ចំពោះឯកសារត្រៀមដែលចុងចម្លើយដាក់ទៅតុលាការលើកដំបូងត្រូវហៅថា "ឯកសារចម្លើយ"។[97] នៅក្នុងឯកសារត្រៀមដែលចុងចម្លើយដាក់ទៅតុលាការលើកដំបូងនេះ ត្រូវមានសរសេរអំពីការឆ្លើយតប ចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទបានសរសេរទាមទារនៅក្នុងពាក្យបណ្តឹង និងការទទួលស្គាល់ ឬមិនទទួលស្គាល់នូវអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្តឹង និងអង្គហេតុដើម្បីតវ៉ាចំពោះអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្តឹងជាអាទិ៍។[98]

ការកំណត់នូវពេលវេលាដែលត្រូវដាក់ឯកសារត្រៀមមានសារៈសំខាន់ណាស់ ដើម្បីធ្វើឱ្យបណ្តឹងដំណើរការឆាប់រហ័ស និងបានផលយ៉ាងល្អ។ ដូចនេះពេលវេលាដែលត្រូវដាក់ឯកសារត្រៀម ជាអាទិ៍ គឺតុលាការអាចកំណត់អំឡុងពេលដែលត្រូវដាក់ឯកសារត្រៀមលើកដំបូងរបស់ចុងចម្លើយ ឬ ឯកសារត្រៀមដែលមានសរសេរអំពីការអះអាងចំពោះចំណុចជាក់លាក់ណាមួយ ឬ ត្រូវធ្វើការស្នើសុំឱ្យពិនិត្យភស្តុតាងដែលទាក់ទងនឹងចំណុចជាក់លាក់ណាមួយ។[99]

លើសពីនេះទៅទៀត ចំពោះបណ្តឹងដែលមានសរសេរអំពីមធ្យោបាយតទល់ ឬ ការពារខ្លួនត្រូវចាត់ទុកថាជាឯកសារត្រៀម។[100]

### ២.៤.៣. ការដាក់មធ្យោបាយតទល់ ឬការពារខ្លួន

មធ្យោបាយតទល់ គឺជាការលើកឡើងអំពីអង្គហេតុ ឬអង្គច្បាប់ និងការដាក់ភស្តុតាងដោយដើមចោទដើម្បីជាសំអាងដល់ការទាមទាររបស់ខ្លួន។[101] សេចក្តីថ្លែងការណ៍របស់ដើមចោទ ហៅថា "មធ្យោបាយតទល់"។ ចំណែកឯមធ្យោបាយការពារខ្លួន គឺជាការលើកឡើងអំពីអង្គហេតុ ឬ អង្គច្បាប់ និងការដាក់ភស្តុតាងដោយចុងចម្លើយ ដើម្បីជាសំអាងដល់ការការពារខ្លួន។[102] សេចក្តីថ្លែងការណ៍របស់ចុងចម្លើយ ហៅថា "មធ្យោបាយ

[96] មាត្រា ១០១ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[97] ក្រសួងយុត្តិធម៌, សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧។
[98] មាត្រា ១០១ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[99] មាត្រា ១០២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[100] មាត្រា ៧៥ កថាខណ្ឌទី ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[101] ហេង ប៊ូរ៉ា មេធាវី, សៀវភៅមេរៀន "នីតិវិធីរដ្ឋប្បវេណី" ឆ្នាំសិក្សា២០២៣-២០២៤។
[102] ហេង ប៊ូរ៉ា មេធាវី, សៀវភៅមេរៀន "នីតិវិធីរដ្ឋប្បវេណី" ឆ្នាំសិក្សា២០២៣-២០២៤។

ការពារខ្លួន"។ ក្នុងន័យនេះ ដើមចោទនឹងធ្វើសេចក្តីថ្លែងការណ៍គាំទ្រនូវពាក្យបណ្តឹងរបស់ខ្លួន ហើយចុងចម្លើយក៏នឹងធ្វើសេចក្តីថ្លែងការណ៍គាំទ្រនូវពាក្យសុំរបស់ខ្លួនដែរ។

មធ្យោបាយតទល់របស់ដើមចោទ ជាដំបូងដើមចោទត្រូវធ្វើសេចក្តីថ្លែងការណ៍នូវការអះអាងអំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលជាការទាមទារតាមផ្លូវបណ្តឹង។ ក៏ប៉ុន្តែដោយសារថាអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិជាក់លាក់ណាមួយមិនអាចធ្វើការទទួលស្គាល់ដោយផ្ទាល់មាត់បានទេ ហេតុដូចនេះដើម្បីធ្វើការវិនិច្ឆ័យអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិនោះ តុលាការត្រូវប្រើប្រាស់នូវវិធីសេចក្តីសន្និដ្ឋានតាមភាពសមហេតុផល ដើម្បីធ្វើការកំណត់នូវអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិនោះ។ ហេតុនេះហើយដើម្បីឱ្យតុលាការសម្រេចថាសិទ្ធិដែលជាខ្លឹមសារនៃការទាមទាររបស់ខ្លួនមានអត្ថិភាព ដើមចោទត្រូវធ្វើការអះអាងអំពីអង្គហេតុមួយឆ្លើយតបទៅនឹងលក្ខខណ្ឌគតិយុត្ត ដើម្បីឱ្យសិទ្ធិនោះមានអានុភាពគតិយុត្តត្រឹមត្រូវ។

ចំពោះមធ្យោបាយការពារខ្លួនរបស់ចុងចម្លើយ គឺចុងចម្លើយត្រូវធ្វើសេចក្តីថ្លែងការណ៍ដែលអះអាងតបចំពោះមូលហេតុនៃការទាមទាររបស់ដើមចោទ។ ក្នុងករណីខ្លះ ទោះបីជាអង្គហេតុដែលបានលើកឡើងដោយដើមចោទមានពិតប្រាកដមែនក៏ដោយ ប៉ុន្តែបើមានអង្គហេតុដែលនាំឱ្យរលត់សិទ្ធិ (នត្ថិភាពនៃសិទ្ធិ) ដូចជាការសង ការទូទាត់ ឬ អាជ្ញាយុកាលនៃការរលត់សិទ្ធិត្រូវបានសម្រេចជាអាទិ៍ មកអះអាងបាន។ ការអះអាងរបស់ចុងចម្លើយនេះ គឺជាមធ្យោបាយការពារខ្លួនរបស់ចុងចម្លើយ ដែលអាចហៅថា ជាការតវ៉ា។ ការតវ៉ា ជាអង្គហេតុដែលអះអាងដោយចុងចម្លើយ ដើម្បីបង្កើតជាឧបសគ្គនៃការកកើតសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ឬ ការរំលត់សិទ្ធិដែលកើតឡើងម្តងរួចហើយ ឬការរារាំងនូវការអនុវត្តសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដែលអះអាងដោយដើមចោទ។ ការតវ៉ានេះ អាចគិតថាជាការអះអាងចម្បងរបស់ចុងចម្លើយ។ ដើមចោទអាចធ្វើសេចក្តីថ្លែងការណ៍ដោយអះអាងនូវអង្គហេតុដែលអាចលុបចោលនូវអានុភាព នៃការតវ៉ារបស់ចុងចម្លើយ ឬ ក្នុងករណីដែលដើមចោទបានបដិសេធនូវអង្គហេតុនៃការតវ៉ា នោះចុងចម្លើយត្រូវដាក់ភស្តុតាង ដើម្បីស្នើសុំឱ្យតុលាការពិនិត្យ ក្នុងគោលបំណងបញ្ជាក់អំពីអង្គហេតុតវ៉ាដែលខ្លួនបានលើកឡើង។[103]

## ២.៤.៤. ពេលវេលាដែលត្រូវដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន

ជាគោលការណ៍ភាគីត្រូវអនុវត្តបណ្តឹងដោយសុចរិត និងស្មោះត្រង់ នោះភាគីគឺត្រូវដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនទៅតុលាការ នៅពេលណាមួយដែលសមរម្យទៅតាមដំណើរការនៃបណ្តឹង។[104] ពេលសមរម្យ គឺជាឱកាស ឬ ដំណាក់កាលនីតិវិធីដែលគួរដាក់ឯកសារមធ្យោបាយនោះ ដើម្បីដោះស្រាយវិវាទឱ្យបានឆាប់រហ័ស

[103] ហ៊ី សោភា សាស្ត្រាចារ្យនីតិសាស្ត្រ, សៀវភៅ "នីតិវិធីរដ្ឋប្បវេណី" ទំព័រទី ៦៣-៦៤, ឆ្នាំ២០១៦។

[104] មាត្រា ៩៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

និងយុត្តិធម៌។ ដោយហេតុថានីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជានីតិវិធីដែលត្រូវបានធ្វើឡើង ដើម្បីបំភ្លឺជាមុននូវចំណុចវិវាទ ដោយត្រូវរៀបចំការអះអាងរបស់ភាគី និងរៀបចំភស្តុតាងពាក់ព័ន្ធនឹងចំណុចវិវាទនោះដែលត្រូវពិនិត្យនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីរៀបចំការជម្រះក្តីឱ្យមានប្រសិទ្ធភាព និងដោយសមូហវិធី នៅក្នុងការទាញហេតុផលដោយផ្ទាល់។ ដូចនេះហើយភាគីត្រូវដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនទាំងអស់នៅក្នុងដំណាក់កាលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ លើកលែងតែក្នុងកាលៈទេសៈដែលមិនទាន់អាចដាក់បាននៅពេលនេះ។

ដើម្បីធ្វើការអះអាង និងបញ្ជាក់ឱ្យបានគ្រប់គ្រាន់ច្បាស់លាស់ក្នុងពាក្យបណ្តឹង ភាគីត្រូវធ្វើការស្រាវជ្រាវជាមុនឱ្យបានហ្មត់ចត់ អំពីទំនាក់ទំនងនៃអង្គហេតុចំពោះសាក្សី ឬ ភស្តុតាងដទៃទៀត។[105]

ហេតុនេះហើយក្រោយពីបានបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ជាគោលការណ៍ភាគីមិនអាចដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនថ្មីទៀតនៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់បានឡើយ។[106] ក្នុងន័យនេះ គឺនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលភាគីត្រូវលើកឡើងនូវការអះអាងរបស់ខ្លួនឱ្យបានទាន់ពេលវេលា ត្រូវឆ្លើយតបទៅនឹងការអះអាងរបស់ភាគីម្ខាងទៀត ហើយធ្វើការស្នើសុំឱ្យពិនិត្យភស្តុតាង ចំពោះអង្គហេតុដែលមានវិវាទ។

### ២.៤.៥. ការលើកចោលមធ្យោបាយតទល់ ឬ ការពារខ្លួនដែលបានដាក់យឺតយ៉ាវមិនត្រូវនឹងពេលសមរម្យ

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចំពោះមធ្យោបាយតទល់ ឬ ការពារខ្លួន ដែលត្រូវបានដាក់ទៅតុលាការយឺតយ៉ាវមិនត្រូវនឹងពេលសមរម្យដោយចេតនា ឬ ដោយកំហុសធ្ងន់ធ្ងររបស់ភាគីតុលាការអាចចេញដីកាសម្រេចលើកចោលមធ្យោបាយតទល់ ឬ ការពារខ្លួននោះបានតាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ប្រសិនបើតុលាការយល់ឃើញថា ការដាក់មធ្យោបាយនោះ ធ្វើឱ្យមានការយឺតយ៉ាវក្នុងការបញ្ចប់នីតិវិធីនៃបណ្តឹង។[107] ម្យ៉ាងវិញទៀត ចំពោះមធ្យោបាយតទល់ ឬ ការពារខ្លួនដែលមានអត្ថន័យមិនច្បាស់លាស់ក្នុងករណីដែលភាគីមិនបានធ្វើការបំភ្លឺចាំបាច់ មិនបង្ហាញខ្លួនតាមកាលបរិច្ឆេទដែលកោះហៅឱ្យមកបំភ្លឺទេ តុលាការក៏អាចលើកចោលនូវមធ្យោបាយតទល់ ឬ ការពារខ្លួននោះបានដែរ។[108]

[105] មាត្រា ៩២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[106] មាត្រា ១០៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[107] មាត្រា ៩៤ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[108] មាត្រា ៩៤ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

### ២.៤.៦. ការកំណត់ចំណុចវិវាទ និងការរៀបចំភស្តុតាង

នៅក្នុងនីតិវិធីត្រៀមសម្រាប់ទាញហេតុផល នៅពេលណាភាគីបានដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនរួចហើយ បន្ទាប់មកតុលាការត្រូវអនុវត្តសិទ្ធិឱ្យបំភ្លឺដើម្បីកំណត់ឱ្យបានជាក់លាក់នូវចំណុចវិវាទពិតប្រាកដនៃរឿងក្តី និងរៀបចំភស្តុតាងចាំបាច់ដែលត្រូវធ្វើការពិនិត្យនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ស្តីពីចំណុចវិវាទនេះ។

ជាទូទៅចំណុចវិវាទរវាងភាគី គឺជាអង្គហេតុ ដូចនេះតុលាការត្រូវពិនិត្យថាអង្គហេតុណាដែលមានវិវាទ។ ពេលដែលមានការអះអាងអំពីអត្ថិភាពនៃអង្គហេតុកំណត់ដោយភាគីណាម្ខាង ក្រមនីតិវិធីរដ្ឋប្បវេណីបានបែងចែងតាមឥរិយាបថរបស់ភាគីម្ខាងទៀត ជាបួនប្រភេទ។ ប្រភេទទី ១ គឺករណីដែលមានសេចក្តីថ្លែងការណ៍បដិសេធនូវអត្ថិភាពនៃអង្គហេតុនោះ ហៅថា “ការបដិសេធ”។ ប្រភេទទី ២ គឺករណីដែលមានសេចក្តីថ្លែងការណ៍ទទួលស្គាល់នូវអត្ថិភាពនៃអង្គហេតុនេះ ហៅថា “ការសារភាព”។[109] ចំពោះប្រភេទទី ៣ គឺករណីដែលមានសេចក្តីថ្លែងការណ៍ថា មិនបានដឹងអំពីអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុនោះទេ ហៅថា “សេចក្តីថ្លែងការណ៍មិនបានដឹង”។ រីឯប្រភេទទី ៤ គឺមិនឆ្លើយអ្វីទាំងអស់។ ក្នុងចំណោមប្រភេទទាំងនេះ ប្រភេទទី ១ អង្គហេតុនោះគឺជាចំណុចវិវាទ ហើយប្រភេទទី ២ អង្គហេតុនោះមិនមានវិវាទទេ។ ចំណែកឯ ពីរប្រភេទទៀតក្រៅពីនេះ ចំពោះករណីថ្លែងការណ៍ថាមិនបានដឹង ក្រមនីតិវិធីរដ្ឋប្បវេណីបានសន្មតថា បានតវ៉ាអំពីអង្គហេតុនេះ។[110] ហើយចំពោះករណីមិនឆ្លើយអ្វីទាំងអស់វិញ ត្រូវចាត់ទុកថាភាគីបានសារភាពអំពីអង្គហេតុនោះ លើកលែងតែករណីដែលភាគីនោះមានឆន្ទៈតវ៉ាចំពោះអង្គហេតុនោះ តាមរយៈឥរិយាបថទាំងមូល។[111] ហេតុនេះហើយអង្គហេតុដែលភាគីបានឆ្លើយថាមិនបានដឹង គឺជាចំណុចវិវាទ ដូច្នេះបើសិនជាមិនបានឆ្លើយអ្វីទេ ជាគោលការណ៍ត្រូវចាត់ទុកថាបានសារភាព ហើយអង្គហេតុនោះមិនមែនជាចំណុចវិវាទទេ។ តាមគោលការណ៍នៃការទាញហេតុផល អង្គហេតុដែលគ្មានវិវាទ (សារភាព ឬសន្មត់ថាសារភាព) មិនទាមទារចាំបាច់ឱ្យមានការបញ្ជាក់ដោយភស្តុតាងឡើយ។[112]

នៅពេលដែលតុលាការកំណត់បានច្បាស់ អំពីចំណុចវិវាទរួចហើយនោះ ត្រូវសម្រេចធ្វើការបញ្ជាក់ដោយភស្តុតាងស្តីពីចំណុចវិវាទទាំងនោះ។ ភស្តុតាងណាមួយដែលត្រូវបានពិនិត្យ អាស្រ័យដោយការស្នើសុំឱ្យពិនិត្យរបស់ភាគី លើកលែងករណីពិសេសដែលតុលាការពុំអាចសម្រេចថាត្រូវទទួលស្គាល់ ឬមិនទទួលស្គាល់

[109] មាត្រា ១២៣ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[110] មាត្រា ៩៦ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[111] មាត្រា ៩៦ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[112] មាត្រា ១២៣ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

នូវការអះអាងអំពីអង្គហេតុ ដោយភស្តុតាងដែលភាគីស្នើសុំឱ្យពិនិត្យ នោះតុលាការអាចធ្វើការពិនិត្យដោយឆន្ទានុសិទ្ធិបាន។[113]

### ២.៤.៧. សកម្មភាពបណ្តឹងនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការអាចធ្វើសកម្មភាពចាំបាច់នានា ដើម្បីរៀបចំការអះអាងរបស់ភាគី កំណត់ចំណុចវិវាទ និងរៀបចំភស្តុតាងដែលត្រូវពិនិត្យនៅពេលទាញហេតុផលដោយផ្ទាល់មាត់។ ប៉ុន្តែក៏មានការកម្រិតមួយចំនួនទៅលើសកម្មភាពដែលអាចអនុញ្ញាតឱ្យធ្វើបានដែរ ដោយសារថា នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលមិនបើកជាសាធារណៈ។

តុលាការអាចស្តាប់ពាក្យសុំ និងការអះអាងរបស់ភាគីទាំងសងខាង ហើយចេញដីកាសម្រេចទៅលើការស្នើសុំឱ្យពិនិត្យភស្តុតាង។ ឧទាហរណ៍៖ ដីកាសម្រេចទទួលយក ឬ មិនទទួលយកនូវភស្តុតាងដែលត្រូវបានស្នើសុំឱ្យពិនិត្យ ដីកាសម្រេចបង្គាប់ឱ្យធ្វើកោសល្យវិច័យ បង្គាប់ឱ្យផ្តល់ឯកសារ ព្រមទាំងដីកាសម្រេចផ្សេងទៀត ដែលក្រមនីតិវិធីរដ្ឋប្បវេណី អនុញ្ញាតឱ្យធ្វើក្រៅពីកាលបរិច្ឆេទ នៃការទាញហេតុផលដោយផ្ទាល់មាត់។

#### ២.៤.៧.១. ការបន្ថែម ឬ ការផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹង

#### ក. អត្ថន័យ នៃការបន្ថែម ឬ ការផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹង

ការបន្ថែម ឬ ការផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹង គឺជាការផ្លាស់ប្តូរនូវខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ ឬ អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ ដែលបានសរសេរនៅក្នុងពាក្យបណ្តឹងដោយដើមចោទក្រោយពេលដាក់ពាក្យបណ្តឹង។ ហើយតាមរយៈការផ្លាស់ប្តូរនេះត្រូវផ្លាស់ប្តូរសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលកម្មវត្ថុនៃបណ្តឹង ឬ ត្រូវផ្លាស់ប្តូរនូវទំហំនៃការវិនិច្ឆ័យ និងចេញសាលក្រមអំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តនោះ។[114]

ការបន្ថែមនូវការទាមទារ មានន័យថា ដើមចោទរក្សាទុកការទាមទារដើម ហើយបន្ថែមនូវការទាមទារថ្មី។ ឧទាហរណ៍ទី១៖ ក្នុងពាក្យបណ្តឹងដើមចោទទាមទារឱ្យចុងចម្លើយ សងប្រាក់កម្ចី ចំនួន ២០,០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ក្រោយមកដើមចោទបន្ថែមការទាមទារថ្មីដោយឱ្យចុងចម្លើយសងការប្រាក់ផងដែរ។ ឧទាហរណ៍ទី២៖ ក្នុងបណ្តឹងទាមទារឱ្យចេញពីផ្ទះ ដោយសារមិនបង់ថ្លៃឈ្នួល ដើមចោទបន្ថែមការទាមទារប្រាក់សំណងការខូចខាតស្មើនឹងថ្លៃឈ្នួលរហូតដល់ពេលអ្នកជួលចេញពីផ្ទះនោះ។

[113] មាត្រា ១២៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[114] មាត្រា ៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

ការផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹង គឺដើមចោទដកការទាមទារដើម ហើយដាក់ការទាមទារថ្មី។ ឧទាហរណ៍ទី១៖ ដើមចោទសុំឱ្យតុលាការ ចេញសាលក្រមបង្គាប់ឱ្យចុងចម្លើយសងប្រាក់កម្ចី ២០,០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ក្រោយមកផ្លាស់ប្តូរការទាមទារ ដោយបន្ថយត្រឹមតែ ១០,០០០ (មួយម៉ឺន) ដុល្លារអាមេរិក ឬ ដំឡើងទៅ ៣០,០០០ (បីម៉ឺន) ដុល្លារអាមេរិក ប៉ុន្តែក្នុងករណីនេះ ពុំមានការផ្លាស់ប្តូរសិទ្ធិដែលជាកម្មវត្ថុនៃបណ្តឹងទេ តែជាការផ្លាស់ប្តូរទំហំនៃការវិនិច្ឆ័យ និងចេញសាលក្រម។ ឧទាហរណ៍ទី២៖ ក្នុងបណ្តឹងទាមទារចេញពីផ្ទះដោយសារមិនបង់ថ្លៃឈ្នួល ប្រសិនបើ មានអគ្គីភ័យឆេះផ្ទះអស់ដោយមានកំហុស របស់ចុងចម្លើយនៅពេលដែលតុលាការកំពុងចាត់ការរឿងក្តីនោះ ដើមចោទផ្លាស់ប្តូរការទាមទាររបស់ខ្លួនទាំងស្រុងទៅការទាមទារសំណងការខូចខាតដោយសារការបាត់បង់ផ្ទះ។[115]

## ខ. លក្ខខណ្ឌនៃការបន្ថែម ឬ ផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹង

ការបន្ថែម ឬ ការផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹងអាចធ្វើទៅបាន លុះត្រាតែស្របទៅនឹងលក្ខខណ្ឌដូចខាងក្រោម៖

### ខ១. ចាំបាច់ស្របលក្ខខណ្ឌនៃការរួមបញ្ចូលនូវការទាមទារ

ករណីរួមបញ្ចូលដោយបន្ថែមនូវការទាមទារ ក៏ដូចជាករណីផ្លាស់ប្តូរនូវការទាមទារដែរ ទាំងការទាមទារថ្មីទាំងការទាមទារដើម ត្រូវបានវិនិច្ឆ័យដោយនីតិវិធីបណ្តឹងដូចគ្នា ហេតុដូច្នេះ មិនអាចអនុញ្ញាតឱ្យធ្វើការបន្ថែម ឬ ផ្លាស់ប្តូរបណ្តឹងបានទេ ប្រសិនបើ ការទាមទារទាំងនោះមិនមែនត្រូវធ្វើការវិនិច្ឆ័យ និងចេញសាលក្រមដោយនីតិវិធីប្រភេទដូចគ្នា។[116]

### ខ២.ចាំបាច់ត្រូវដាក់ការទាមទារនៅមុនការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់

ចាំបាច់ត្រូវធ្វើនៅមុនពេលការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៃការវិនិច្ឆ័យទៅលើអង្គហេតុការទាមទារថ្មីចាំបាច់ត្រូវធ្វើការវិនិច្ឆ័យស្តីពីអង្គហេតុថ្មីទៀត ហេតុនេះហើយការបន្ថែម ឬ ការផ្លាស់ប្តូរបណ្តឹងអាចអនុញ្ញាតឱ្យធ្វើបាន តែនៅពេលដែលបណ្តឹងនោះ កំពុងត្រូវបានចាត់ការក្នុងការវិនិច្ឆ័យទៅលើអង្គហេតុ។ ទោះបីជាការវិនិច្ឆ័យនៃការជំនុំជម្រះលើកទី១ ត្រូវបានបញ្ចប់ក៏ដោយ នៅក្នុងការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ក៏អាចបន្ថែម ឬ ផ្លាស់ប្តូរបណ្តឹងបានដែរ។

[115] ហេង បូរ៉ា មេធាវី, សៀវភៅមេរៀន នីតិវិធីរដ្ឋប្បវេណី, ទំព័រទី ៥៥-៥៦, ឆ្នាំសិក្សា២០២៣-២០២៤។
[116] មាត្រា ៧៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

ខ៣. មិនត្រូវមានការប្តូរនូវមូលដ្ឋាននៃការទាមទារ[117]

ដើម្បីអនុញ្ញាតឱ្យបន្ថែម ឬ ផ្លាស់ប្តូរបណ្តឹងការទាមទារថ្មីដែលកើតឡើងដោយទំនាស់តែមួយ ឬ ទំនាស់តគ្នា ហើយថែមទាំងមានចំណុចវិវាទសំខាន់ៗ ហេតុនេះហើយចាំបាច់អាចប្រើនូវឯកសារបណ្តឹង និងធនធានភស្តុតាងដែលមានមុនពេលបន្ថែម ឬ ផ្លាស់ប្តូរនោះ។

ឧទាហរណ៍៖ ដើមចោទទាមទារឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យចុងចម្លើយបង់ប្រាក់កម្ចីចំនួន ២០,០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ក្រោយមកដើមចោទ បន្ថែមការទាមទារដោយសុំឱ្យចេញសាលក្រមដែលខ្លឹមសារថាបង្គាប់ឱ្យចុងចម្លើយបង់ការប្រាក់។

ឧទាហរណ៍៖ ដើមចោទទាមទារឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ចំនួន ២០,០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ប៉ុន្តែក្រោយមកដើមចោទផ្លាស់ប្តូរកម្មវត្ថុថ្មីដោយទាមទារឱ្យចេញសាលក្រមដែលខ្លឹមសារថាបង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ ១០,០០០ (មួយម៉ឺន) ដុល្លារអាមេរិកវិញ។

ឧទាហរណ៍៖ ក្នុងបណ្តឹងដើម ដើមចោទទាមទារឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ចំនួន ២០,០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ហើយផ្លាស់ប្តូរការទាមទារ ដោយឱ្យចេញសាលក្រមដែលខ្លឹមសារថាបង្គាប់ចុងចម្លើយបង់ប្រាក់ ២៥,០០០ (ពីរម៉ឺន ប្រាំពាន់) ដុល្លារអាមេរិកវិញ។

ខ៤. មិនត្រូវធ្វើឱ្យមានការយឺតយ៉ាវខ្លាំងដល់នីតិវិធី

ករណីដែលការទាមទារពីដើមអាចត្រូវបានបញ្ចប់ការវិនិច្ឆ័យភ្លាមៗបានតែចាំបាច់មានការវិនិច្ឆ័យឱ្យសមស្របចំពោះការទាមទារថ្មី។ តុលាការអាចមិនអនុញ្ញាតឱ្យបន្ថែម ឬ ផ្លាស់ប្តូរបាន ដោយយកមូលហេតុថាការបន្ថែម ឬ ការផ្លាស់ប្តូរនោះនឹងធ្វើឱ្យមានការយឺតយ៉ាវខ្លាំងដល់នីតិវិធីបណ្តឹង។

## គ. ការចាត់ចែងអំពីការបន្ថែម ឬ ការផ្លាស់ប្តូរបណ្តឹង

ការបន្ថែម ឬ ការផ្លាស់ប្តូរបណ្តឹងត្រូវធ្វើជាលាយលក្ខណ៍អក្សរ។[118] នេះគឺដោយសារតែជាសារធាតុ ការបន្ថែម ឬ ការផ្លាស់ប្តូរបណ្តឹង គឺដូចជាការដាក់ពាក្យបណ្តឹងថ្មីដែរ។ ក្រឡាបញ្ជីត្រូវធ្វើការបញ្ជូនឯកសារនេះទៅភាគីម្ខាងទៀត។[119] ប្រសិនបើការបន្ថែម ឬ ការផ្លាស់ប្តូរបណ្តឹងមានកង្វះនូវលក្ខខណ្ឌនៃការបន្ថែម ឬ ការផ្លាស់ប្តូរ តុលាការត្រូវចេញដីកាសម្រេចមិនអនុញ្ញាតឱ្យបន្ថែម ឬ ផ្លាស់ប្តូរបណ្តឹងតាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិរបស់

[117] មាត្រា ៨៤ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[118] មាត្រា ៨៤ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[119] មាត្រា ៨៤ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

ខ្លួន។[120] ប្រសិនបើយល់ឃើញថាការបន្ថែម ឬ ការផ្លាស់ប្តូរបណ្តឹងនោះស្របលក្ខខណ្ឌតុលាការត្រូវធ្វើការវិនិច្ឆ័យការទាមទារថ្មីនេះ ហើយចេញសាលក្រម។

ក្នុងករណីដែលការផ្លាស់ប្តូរនូវការទាមទារនៃបណ្តឹង ប្រសិនបើចុងចម្លើយបានឆ្លើយតបចំពោះអង្គសេចក្តីរហូតដល់ពេលមានការផ្លាស់ប្តូរ នោះអានុភាពនៃការដកការទាមទារដើមមិនកើតមានឡើងទេ ប្រសិនបើចុងចម្លើយមិនយល់ព្រម។ ហេតុដូច្នេះហើយ តុលាការត្រូវធ្វើការវិនិច្ឆ័យ និងចេញសាលក្រមចំពោះការទាមទារទាំងដើមទាំងថ្មីដោយចាត់ទុកថាជាការបន្ថែមនូវការទាមទារ។[121]

**២.៤.៧.២. បណ្តឹងតប**

បណ្តឹងតប គឺជាបណ្តឹងដែលចុងចម្លើយបានធ្វើឡើងចំពោះដើមចោទនៅក្នុងនីតិវិធីនៃបណ្តឹងនៅពេលបណ្តឹងដែលដើមចោទធ្វើឡើងកំពុងតែត្រូវបានចាត់ការ។ ចំពោះបណ្តឹងដែលដាក់ដោយដើមចោទ ហើយកំពុងតែត្រូវបានចាត់ការនោះ ត្រូវហៅថាបណ្តឹងដើម។

បណ្តឹងតប គឺជាបណ្តឹងថ្មីដែលធ្វើដោយចុងចម្លើយនៃបណ្តឹងដើម (ដើមចោទនៃបណ្តឹងតប) ចំពោះដើមចោទនៃបណ្តឹងដើម (ចុងចម្លើយនៃបណ្តឹងតប) ហើយមិនមែនជាមធ្យោបាយការពារខ្លួន ចំពោះបណ្តឹងដើមចោទទេ។

**ក. លក្ខខណ្ឌនៃបណ្តឹងតប**

ក១. ការទាមទារនៃបណ្តឹងតប ចាំបាច់ត្រូវជាការទាមទារ ដែលត្រូវធ្វើការវិនិច្ឆ័យ និងចេញសាលក្រម ដោយនីតិវិធីបណ្តឹងប្រភេទដូចគ្នានឹងការទាមទារនៃបណ្តឹងដើម ហើយការប្តឹងតបមិនត្រូវបានហាមឃាត់។ ការទាមទារនៃបណ្តឹងតប និងការទាមទារនៃបណ្តឹងដើម តុលាការត្រូវធ្វើការវិនិច្ឆ័យ និងចេញសាលក្រមដោយនីតិវិធីដូចគ្នា ហេតុនេះហើយចាំបាច់ត្រូវមានលក្ខខណ្ឌទូទៅនៃការរួមបញ្ចូលនូវការទាមទារ។ ប៉ុន្តែប្រសិនបើ ច្បាប់បានចែងពិសេសហាមមិនឱ្យធ្វើបណ្តឹងតប នោះមិនអនុញ្ញាតឱ្យធ្វើបណ្តឹងតបឡើយ។[122]

ក២. លុះត្រាតែ បណ្តឹងដើមកំពុងត្រូវបានចាត់ការ ហើយត្រូវស្ថិតនៅមុនពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៃការវិនិច្ឆ័យទៅលើអង្គហេតុ។[123]

[120] មាត្រា ៨៤ កថាខណ្ឌទី ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[121] សេចក្តីពន្យល់ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[122] មាត្រា ២២៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[123] មាត្រា ៨៦ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

ទោះបីជា ក្រោយការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៃការជំនុំជម្រះលើកទី១ ក៏ដោយ ក៏ចុងចម្លើយអាចប្ដឹងតបបានដែរ បើបណ្ដឹងឧទ្ធរណ៍ត្រូវបានដាក់ហើយកំពុងត្រូវបានចាត់ការ ដោយតុលាការនៃបណ្ដឹងឧទ្ធរណ៍។ ប៉ុន្តែ ដើម្បីដាក់បណ្ដឹងតប នៅក្នុងការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ចាំបាច់ត្រូវមានការយល់ព្រមពីដើមចោទដែលជាភាគីម្ខាងទៀត។[124]

ប្រសិនបើ ដើមចោទមិនបានតវ៉ា ហើយបានទាញហេតុផលលើអង្គសេចក្ដី នៃបណ្ដឹងតបត្រូវចាត់ទុកថាបានយល់ព្រមអំពីការដាក់បណ្ដឹងតបដោយមិនចាំបាច់មានការបង្ហាញនូវឆន្ទៈយល់ព្រមច្បាស់លាស់ទេ។[125]

ក៣. ការទាមទារនៃបណ្ដឹងតបចាំបាច់ត្រូវមានទំនាក់ទំនងនឹងការទាមទារនៃបណ្ដឹងដើម ឬ មានទំនាក់ទំនងនឹងមធ្យោបាយការពារខ្លួនចំពោះការទាមទារនៃបណ្ដឹងដើម។[126]

បណ្ដឹងតប គឺជាពាក្យសុំឱ្យតុលាការវិនិច្ឆ័យ និងចេញសាលក្រមចំពោះការទាមទារថ្មី នៅពេលបណ្ដឹងកំពុងត្រូវបានចាត់ការ ដូចការបន្ថែម ឬ ការផ្លាស់ប្ដូរការទាមទារ។ ហេតុនេះហើយ លក្ខខណ្ឌនៃបណ្ដឹងតបនេះ គឺត្រូវបានកំណត់ ដូចគ្នានឹងលក្ខខណ្ឌនៃការបន្ថែម ឬ ផ្លាស់ប្ដូរបណ្ដឹងដោយដើមចោទដែរ។ មានន័យថា មិនចាំបាច់ទទួលស្គាល់រហូតដល់ការទាមទារដែលគ្មានទាក់ទងនឹងការទាមទារនៃបណ្ដឹងដើមចោទ។

ក៤. ការទាមទារនៃបណ្ដឹងតប មិនត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្ដាច់មុខ របស់តុលាការដទៃទៀត។[127]

ក៥. នីតិវិធីបណ្ដឹងមិនមានការយឺតយ៉ាវខ្លាំងដោយសារការដាក់បណ្ដឹងតប។ [128]
ឧទាហរណ៍ទី១៖ ក បានទាមទារឱ្យ ខ ចុះចេញពីផ្ទះរបស់ខ្លួន ដោយលើកសំអាងថាផុតអាណត្តិនៃកិច្ចសន្យាជួលហើយ ខ ប្ដឹងទាមទារឱ្យបន្តកិច្ចសន្យាជួល ដោយលើកហេតុផលថាកិច្ចសន្យាបានកំណត់ពីសិទ្ធិអាទិភាពរបស់ភាគីអ្នកសុំជួលក្នុងការបន្តកិច្ចសន្យាជាដើម។ ឧទាហរណ៍ទី ២៖ ក្នុងករណីដែលដើមបណ្ដឹងដាក់ពាក្យបណ្ដឹងទាមទារប្រាក់ដោយផ្អែកលើកិច្ចសន្យាលក់ រីឯចុងចម្លើយដាក់ពាក្យបណ្ដឹងទាមទារឱ្យប្រគល់នូវទំនិញដោយផ្អែកលើកិច្ចសន្យាលក់ដូចគ្នាដែរ។

## ខ. នីតិវិធីដាក់បណ្ដឹងតប និងការចាត់ការបណ្ដឹងតប

124 មាត្រា ២៧៦ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
125 មាត្រា ២៧៦ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
126 មាត្រា ៨៦ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
127 មាត្រា ៨៦ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
128 មាត្រា ៨៦ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

ចំពោះនីតិវិធីនៃការប្តឹងតប ត្រូវអនុវត្តតាមបញ្ញត្តិស្តីពីបណ្តឹងដើម។[129] ក្នុងករណីដែលមិនស្របនឹងលក្ខខណ្ឌ នៃបណ្តឹងតប តុលាការត្រូវបំបែកចែករឿងក្តីនោះ ហើយចាត់ចែងបណ្តឹងតបជាបណ្តឹងឯករាជ្យមួយ និងត្រូវធ្វើការវិនិច្ឆ័យផ្សេងពីគ្នា។ ក្នុងករណីដែលតុលាការផ្សេង មានសមត្ថកិច្ចផ្តាច់មុខ តុលាការត្រូវផ្ទេរបណ្តឹងតបនោះ ទៅតុលាការនោះ។

ក្នុងករណីដែល ស្របលក្ខខណ្ឌបណ្តឹងតប តុលាការត្រូវធ្វើការវិនិច្ឆ័យ និងចេញសាលក្រម អំពីបណ្តឹងដើម និងបណ្តឹងតបដោយនីតិវិធីដូចគ្នា។

### ២.៤.៧.៣. បណ្តឹងទាមទារការបញ្ជាក់ក្នុងដំណើរការពាក់កណ្តាលទី

### ក. អត្ថន័យនៃបណ្តឹងទាមទារការបញ្ជាក់ក្នុងដំណើរការពាក់កណ្តាលទី

បណ្តឹងទាមទារការបញ្ជាក់ក្នុងដំណើរការពាក់កណ្តាលទី គឺជាបណ្តឹងទាមទារឱ្យបញ្ជាក់ដែលត្រូវបានដាក់ដោយដើមចោទ ឬ ចុងចម្លើយនៅពេលបណ្តឹងកំពុងត្រូវបានចាត់ការដើម្បីទាមទារឱ្យតុលាការចេញសាលក្រម បញ្ជាក់នូវអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលផ្សេងពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃបណ្តឹងហើយដែលជាមូលដ្ឋាននៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃបណ្តឹងនោះ។[130]

ឧទាហរណ៍៖ ពេលដែលកំពុងតែធ្វើការវិនិច្ឆ័យបណ្តឹងទាមទារឱ្យប្រគល់វិញនូវវត្ថុ ដែលជាកម្មសិទ្ធិរបស់ដើមចោទ ប្រសិនបើ មានវិវាទថាតើដើមចោទជាកម្មសិទ្ធិករ នៃកម្មវត្ថុនោះឬទេ ពេលនោះដើមចោទបានធ្វើបណ្តឹងទាមទារ ការបញ្ជាក់កម្មសិទ្ធិ ឬចុងចម្លើយបានធ្វើបណ្តឹងទាមទារ ការបញ្ជាក់នូវអត្ថិភាពនៃកម្មសិទ្ធិរបស់ដើមចោទនេះ គឺជាករណី នៃបណ្តឹងទាមទារការបញ្ជាក់ក្នុងដំណើរការពាក់កណ្តាលទី។

បណ្តឹងនេះ គឺជាការបន្ថែមកម្មវត្ថុនៃបណ្តឹងមួយប្រភេទប្រសិនបើដើមចោទប្តឹង ហើយគឺជាបណ្តឹងតបមួយប្រភេទ ប្រសិនបើចុងចម្លើយប្តឹង។

### ខ.លក្ខខណ្ឌនៃបណ្តឹងទាមទារបញ្ជាក់ក្នុងដំណើរការពាក់កណ្តាលទី

ខ១. ទាល់តែបណ្តឹងកំពុងត្រូវបានចាត់ការក្នុងការជំនុំជម្រះលើអង្គហេតុ ហើយស្ថិតនៅមុនពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់។

[129] មាត្រា ៨៦ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[130] មាត្រា ៨៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

ខ២. ទាល់តែទាមទារឱ្យបញ្ជាក់នូវអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលជាមូលដ្ឋាននៃការវិនិច្ឆ័យអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃបណ្តឹង។[131]

ខ៣. ការទាមទារឱ្យបញ្ជាក់មិនត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខរបស់តុលាការដទៃទៀត។[132]

**គ. នីតិវិធីដាក់ពាក្យបណ្តឹង និងនីតិវិធីទាមទារការបញ្ជាក់ក្នុងដំណើរការពាក់កណ្តាលទី**

បណ្តឹងទាមទារបញ្ជាក់ក្នុងដំណើរការពាក់កណ្តាលទីត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរហើយក្រឡាបញ្ជីត្រូវធ្វើការបញ្ជូនលិខិតនោះទៅឱ្យភាគីម្ខាងទៀត។[133]

### ២.៤.៨. ការបំបែក និងការរួមបញ្ចូលរឿងក្តី

នៅពេលដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលកំពុងមានដំណើរការ តុលាការអាចបំបែកបណ្តឹងមួយភាគដោយដីកាសម្រេចដើម្បីធ្វើការវិនិច្ឆ័យផ្សេងគ្នាបាន ប្រសិនបើយល់ឃើញថាមានការចាំបាច់។ នេះគេហៅថា "ការបំបែករឿងក្តី"។[134] ទោះជាបានដាក់បណ្តឹងតែមួយក៏ដោយ ប្រសិនបើការទាមទារនោះមានខ្លឹមសារដែលមិនទាក់ទិនគ្នា ហើយការទាមទារម្ខាងចាំបាច់ត្រូវបញ្ចប់ការវិនិច្ឆ័យឱ្យបានលឿនការបំបែករឿងក្តីគឺជាការសមរម្យ។ ឧទាហរណ៍៖ បើសិនជាដើមបណ្តឹងបានទាមទារឱ្យចុងចម្លើយសងប្រាក់កម្ចី និងបង់ប្រាក់ថ្លៃលក់ទិញនៅក្នុងបណ្តឹងតែមួយ តុលាការអាចបំបែកការទាមទារឱ្យបង់ប្រាក់ថ្លៃលក់ទិញចេញ ហើយធ្វើការវិនិច្ឆ័យជារឿងក្តីផ្សេងគ្នាបាន។

ផ្ទុយទៅវិញ តុលាការអាចរួមបញ្ចូលរឿងក្តីច្រើនដែលកំពុងត្រូវបានចាត់ការផ្សេងៗគ្នាដោយតុលាការតែមួយដើម្បីធ្វើការវិនិច្ឆ័យសរុបដោយនីតិវិធីតែមួយបាន។ នេះគេហៅថា "ការរួមបញ្ចូលរឿងក្តី"។[135] ចំពោះរឿងក្តីផ្សេងៗគ្នាច្រើន តែមានខ្លឹមសារពាក់ព័ន្ធគ្នាដែលកំពុងត្រូវបានចាត់ការដាច់ៗគ្នាអាចមានករណីដែលរួមបញ្ចូលរឿងក្តីនោះទៅនឹងមានការសមស្របក្នុងការវិនិច្ឆ័យ។ ក្នុងន័យនេះគឺ តុលាការអាចបញ្ចូលរឿងក្តីច្រើនដែលកំពុងចាត់ការមកជារឿងក្តីតែមួយក៏បាន ប្រសិនបើរឿងនោះមានទំនាក់ទំនងនឹងគ្នាបើទោះបីរឿងក្តីទាំងនោះមានភាគីខុសគ្នាក៏ដោយ។[136]

---

131 មាត្រា ៨៥ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

132 មាត្រា ៨៥ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

133 មាត្រា ៨៤ កថាខណ្ឌទី ២ ទី៣ និងមាត្រា ៨៥ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

134 មាត្រា ៩៩ កថាខ័ណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

135 មាត្រា ៩៩ កថាខ័ណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

136 មាត្រា ៩៩ កថាខ័ណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

# ជំពូកទី ៣
# ការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

# ជំពូកទី ៣
# ការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅគ្រប់ដំណាក់កាលនៃនីតិវិធីរដ្ឋប្បវេណីទាំងអស់ មានពេលវេលាដែលត្រូវចាប់ផ្តើម និងបញ្ចប់ដែលយោងទៅតាមបទប្បញ្ញត្តិដែលមានចែងជាធរមាន។ ចំពោះនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលក៏មានពេលវេលាសមរម្យដែលត្រូវបញ្ចប់ (៣.១) ព្រមជាមួយគ្នានេះនៅពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលតុលាការក៏ត្រូវបំពេញសកម្មភាពចាំបាច់មួយចំនួន (៣.២) និងពេលបញ្ចប់ដំណាក់កាលនីតិវិធីត្រៀមត្រូវមានអានុភាព (៣.៣)។

## ៣.១. ពេលវេលាដែលត្រូវបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ពេលវេលានៃការបញ្ចប់ គឺប្រែប្រួលទៅតាមគោលបំណង នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។ មានន័យថា នៅពេលគោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវបានបំពេញ នោះនីតិវិធីនឹងត្រូវបញ្ចប់ (៣.១.១)។ ប៉ុន្តែមានករណីខ្លះទោះជាគោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលមិនទាន់បំពេញក៏ដោយក៏នីតិវិធីត្រូវតែបញ្ចប់ដែរ (៣.១.២)។

### ៣.១.១. គោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវបានបំពេញ

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបង្កើតឡើងដើម្បីធ្វើឱ្យមានភាពងាយស្រួល និងឆាប់រហ័សដល់នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការចេញសាលក្រមតាមរយៈការកំណត់ចំណុចវិវាទ ការអះអាងរបស់គូភាគី និងការរៀបចំភស្តុតាងឱ្យបានជាក់លាក់។ ហេតុដូចនេះនៅពេលដែលកំណត់ចំណុចវិវាទ ការអះអាងរបស់គូភាគី និងការរៀបចំភស្តុតាងឱ្យបានច្បាស់លាស់ហើយ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនឹងត្រូវបានបញ្ចប់។ ចំណែកឯ ការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលប៉ុន្មានលើកនោះ ច្បាប់មិនបានកំណត់ទេ សំខាន់ឱ្យតែតុលាការអាចបំពេញគោលបំណង។

### ៣.១.២. គោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលមិនទាន់បំពេញ

មានករណីមួយចំនួន ទោះជាគោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលមិនទាន់បំពេញក៏ដោយក៏នីតិវិធីត្រៀសម្រាប់ការទាញហេតុផលត្រូវបញ្ចប់ដែរ។ ដូចជាការអវត្តមានរបស់ភាគីនៅក្នុងដំណាក់កាលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ករណីភាគីអវត្តមាននោះនឹងធ្វើឱ្យនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវបញ្ចប់ទោះជាការអវត្តមាននោះ គឺអវត្តមានភាគីណាម្ខាង ឬ អវត្តមានភាគីទាំងសងខាងក៏ដោយ។ ការអវត្តមាននៃភាគី អាចជាដើមចោទ (៣.១.២.១) ឬ ជាចុងចម្លើយ (៣.១.២.២) ឬ អាចជាការអវត្តមានភាគីទាំងសងខាង (៣.១.២.៣)។

### ៣.១.២.១. ករណីអវត្តមានភាគីដើមចោទ

ប្រសិនបើដើមចោទអវត្តមាន ឬ មិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទលើកទី ១ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវសម្រេចច្រានចោលការទាមទាររបស់ដើមចោទដោយសាលក្រមកំបាំងមុខ។ [137] ដោយសារភាគីដើមចោទជាបុគ្គលដែលដាក់ពាក្យបណ្តឹងមកតុលាការ ដើម្បីទាមទារឱ្យតុលាការសម្រេចពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តរបស់ខ្លួន ដូច្នេះបើដើមចោទមិនមកបង្ហាញខ្លួនទេនោះបានន័យថាដើមចោទគ្មានឆន្ទៈក្នុងការទាមទារតាមនីតិវិធីនៃបណ្តឹងនោះទេ ដូច្នេះតុលាការអាចសម្រេចច្រានចោលការទាមទាររបស់ដើមចោទបាន។

### ៣.១.២.២. ករណីអវត្តមានភាគីចុងចម្លើយ

ប្រសិនបើភាគីចុងចម្លើយអវត្តមាន ឬ មិនបង្ហាញខ្លួននៅកាលបរិច្ឆេទលើកទី ១ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវបញ្ចប់នីតិវិធីត្រៀមភ្លាមៗ ហើយកំណត់នូវកាលបរិច្ឆេទលើកទី ១ នៃការទាញហេតុផលដោយផ្ទាល់មាត់។[138] ក្នុងករណីនេះ អាចមានករណីដែលការទាមទាររបស់ដើមចោទមិនសមហេតុផលសោះក្នុងការអះអាងឯកឯង តុលាការមិនអាចចេញសាលក្រមកំបាំងមុខភ្លាមៗបានទេ។ម្យ៉ាងទៀតតុលាការក៏មិនអាចចេញសាលក្រមដែលទទួលស្គាល់ការទាមទារ ដោយមិនធ្វើទៅតាមការទាញហេតុផលដោយផ្ទាល់មាត់បានដែរ។ ហេតុនេះតុលាការត្រូវកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់វិញ។[139]

### ៣.១.២.៣. ករណីអវត្តមានភាគីទាំងសងខាង

ករណីដែលភាគីទាំងសងខាងអវត្តមាន ឬ មិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង ហើយមិនបានដាក់ពាក្យសុំឱ្យតុលាការកំណត់កាលបរិច្ឆេទជាថ្មីក្នុងអំឡុងពេល ១ (មួយ) ខែ នោះត្រូវចាត់ទុកថាភាគីដើមចោទបានដកពាក្យបណ្តឹង។ ហើយក៏ត្រូវចាត់ទុកថាបានដកពាក្យបណ្តឹងផងដែរ ក្នុងករណីដែលភាគីទាំងសងខាងមិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ២ (ពីរ) ដងជាប់គ្នា។[140]

---

[137] មាត្រា ២០០ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[138] មាត្រា ២០១ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[139] សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧។

[140] មាត្រា ២១៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

## ៣.២. សកម្មភាពដែលត្រូវបំពេញនៅពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ពេលដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុត្រូវបានបញ្ចប់ តុលាការត្រូវបញ្ជាក់ពីអង្គហេតុដែលត្រូវបំភ្លឺជាមួយភាគី (៣.២.១) បន្ទាប់មកត្រូវធ្វើការកំណត់កាលបរិច្ឆេទលើកទី ១ នៅនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ (៣.២.២) តែម្តង។ នៅពេលបញ្ចប់នីតិវិធីត្រៀម គឺក្រឡាបញ្ជីត្រូវមានកំណត់ហេតុស្តីពី នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល (៣.២.៣)។

### ៣.២.១. ការបញ្ជាក់អំពីអង្គហេតុដែលត្រូវធ្វើការបំភ្លឺ

នៅពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយបានបញ្ចប់ការរៀបចំចំណុចវិវាទនៃរឿងក្តី និងភស្តុតាងហើយ នោះតុលាការត្រូវធ្វើការបញ្ជាក់ជាមួយភាគីនូវអង្គហេតុដែលនឹងត្រូវបំភ្លឺនៅពេលពិនិត្យភស្តុតាងនៅពេលក្រោយ។[141] ក្នុងន័យនេះ ភាគីត្រូវធ្វើការបញ្ជាក់ថាអង្គហេតុណាខ្លះជាចំណុចវិវាទដែលត្រូវជាកម្មវត្ថុនៃការពិនិត្យភស្តុតាងដោយការទទួលស្គាល់រួមគ្នារវាងភាគី និងតុលាការ ហើយចាំបាច់ត្រូវតែធ្វើការបញ្ជាក់ដោយខានពុំបានតាមរយៈការពិនិត្យភស្តុតាងជាសមូហវិធីនៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់។

### ៣.២.២. ការកំណត់កាលបរិច្ឆេទធ្វើការទាញហេតុផលដោយផ្ទាល់មាត់លើកទី ១

នៅពេលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានចប់សព្វគ្រប់អស់ហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ហើយត្រូវកោះហៅគូភាគីមកចូលរួម។[142]

ការកំណត់កាលបរិច្ឆេទទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវតែធានាថាគូភាគីអាចមានវត្តមានបាន ព្រោះនេះជាការគោរពនូវគោលការណ៍ចំពោះមុខ។[143] តុលាការត្រូវកំណត់កាលបរិច្ឆេទតាមពាក្យសុំ ឬកំណត់ដោយឆន្ទានុសិទ្ធិ។ ការផ្លាស់ប្តូរកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់មិនត្រូវបានអនុញ្ញាតទេ លើកលែងតែករណីដែលមានមូលហេតុមិនអាចជៀសវាងបាន។ ចំពោះការកោះហៅឱ្យគូភាគីចូលរួមតាមកាលបរិច្ឆេទ តុលាការអាចធ្វើតាមរយៈការជូនដំណឹង ឬ ដោយបញ្ជូនដីកាកោះក៏បាន។[144]

[141] មាត្រា ១០៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[142] មាត្រា ១១៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[143] មាត្រា ១១៥ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[144] មាត្រា ១០៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

### ៣.២.៣. កំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មានសកម្មភាពជាច្រើនដែលត្រូវធ្វើដោយចៅក្រម ភាគី ឬ អ្នកតំណាងដោយអាណត្តិ ហើយសកម្មភាពនេះមិនអាចបញ្ជាក់បានទេ ប្រសិនបើពុំមានអ្នកកត់ត្រា ដូចនេះ តុលាការត្រូវឱ្យក្រឡាបញ្ជីកត់ត្រា (ធ្វើកំណត់ហេតុ) នូវនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនៅគ្រប់កាលបរិច្ឆេទ។[145] មួយវិញទៀត កំណត់ហេតុនេះមានសារៈសំខាន់សម្រាប់តុលាការជាន់ខ្ពស់ក្នុងការពិនិត្យលើចំណាត់ការរបស់តុលាការដែលបានធ្វើកំណត់ហេតុនោះ។

#### ៣.២.៣.១. ចំណុចជារូបមន្តនៃកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ទម្រង់នៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវកត់ត្រានូវចំណុចដូចតទៅ៖

- សញ្ញាណនៃរឿងក្តី
- ឈ្មោះចៅក្រម និងក្រឡាបញ្ជី
- ឈ្មោះភាគី អ្នកតំណាង អ្នកជំនួយការ និងអ្នកបកប្រែដែលបានបង្ហាញ
- ពេលវេលា និងទីកន្លែង

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ និងក្រឡាបញ្ជីត្រូវបានចុះហត្ថលេខាលើកំណត់ហេតុពុំនោះទេកំណត់ហេតុនេះនឹងរងនូវមោឃៈ។[146]

#### ៣.២.៣.២. ចំណុចសារធាតុនៃកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងកំណត់ហេតុស្តីពី នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវកត់នូវសេចក្តីសង្ខេបអំពីសកម្មភាពដែលបានធ្វើឡើងនៅកាលបរិច្ឆេទនីមួយៗ ហើយជាពិសេសត្រូវបានកត់ត្រាឱ្យបានច្បាស់លាស់នូវចំណុចដូចខាងក្រោមនេះ៖

- ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និងចម្លើយតបរបស់ចុងចម្លើយចំពោះការទាមទារនោះ។
- ខ្លឹមសារនៃអង្គហេតុដែលបានអះអាង និងការស្នើសុំឱ្យពិនិត្យភស្តុតាង។

[145] មាត្រា ១០៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[146] មាត្រា ១១០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

- ការទទួលស្គាល់ ឬ មិនទទួលស្គាល់របស់ភាគី ចំពោះអង្គហេតុដែលបានអះអាងដោយភាគីម្ខាងទៀត និងការទទួលស្គាល់ ឬ មិនទទួលស្គាល់ចំពោះភាពត្រឹមត្រូវនៃឯកសារ។
- ការដកពាក្យបណ្ដឹង ការផ្សះផ្សា ការលះបង់ការទាមទារ និងការទទួលស្គាល់ការទាមទារ។
- ចំណុចដែលតុលាការបានបង្គាប់ឱ្យកត់ត្រា និងចំណុចដែលតុលាការអនុញ្ញាតឱ្យកត់ត្រាតាមការទាមទាររបស់ភាគី។
- ការសម្រេចសេចក្ដីដែលបានធ្វើឡើងនៅកាលបរិច្ឆេទនោះដោយមិនធ្វើជាលាយលក្ខណ៍អក្សរ។

#### ៣.២.៣.៣. ការប្ដឹងតវ៉ាចំពោះសេចក្ដីកត់ត្រានៃកំណត់ហេតុស្ដីពី នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងករណីដែលភាគី ឬ អ្នកដទៃទៀតដែលពាក់ព័ន្ធប្ដឹងតវ៉ាចំពោះសេចក្ដីកត់ត្រានៅក្នុងកំណត់ហេតុស្ដីពី នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នោះត្រូវកត់ត្រានូវសេចក្ដីប្ដឹងតវ៉ានៅក្នុងកំណត់ហេតុនោះ។ [147] មានន័យថា នៅពេលមានការតវ៉ាអំពីកំណត់ហេតុ ប្រសិនបើក្រឡាបញ្ជីយល់ឃើញថាការតវ៉ានេះត្រឹមត្រូវ ឬ ចៅក្រមយល់ឃើញថាការតវ៉ានេះត្រឹមត្រូវហើយបង្គាប់ឱ្យក្រឡាបញ្ជីកែតម្រូវ នោះក្រឡាបញ្ជីត្រូវតែកែតម្រូវ បើយល់ឃើញថាការតវ៉ានេះមិនត្រឹមត្រូវ នោះក្រឡាបញ្ជីត្រូវកត់សេចក្ដីតវ៉ានោះនៅក្នុងកំណត់ហេតុ។[148]

### ៣.៣. អានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅពេលដែលបានបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ភាគីមិនអាចដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនថ្មីទៀតបានទេ។[149] ដោយហេតុថាបើតុលាការអនុញ្ញាតឱ្យដាក់មធ្យោបាយតទល់ ឬ ការពារខ្លួននៅពេលដែលបានបញ្ចប់នីតិវិធីត្រៀមរួចហើយនោះ អាចបណ្ដាលឱ្យការកំណត់នូវចំណុចវិវាទ ការរៀបចំនូវការអះអាងរបស់ដើមបណ្ដឹង ហើយការកំណត់នូវចំណុចដែលត្រូវពិនិត្យភស្តុតាងនឹងអត់មានន័យទៅវិញ នេះបើគិតតាមគោលការណ៍នៃការដាក់ឯកសារឱ្យស្របពេលវេលា។ ភាគីត្រូវដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។ អានុភាពនេះក៏នឹងមានដូចគ្នាទៅលើការជំនុំជម្រះនៃបណ្ដឹងឧទ្ធរណ៍ផងដែរ។[150]

ប៉ុន្តែក្នុងករណីជាចំណុចដែលតុលាការត្រូវធ្វើការស្រាវជ្រាវដោយឆន្ទានុសិទ្ធិជាអាទិ៍ ឬ ក្នុងករណីកុំឱ្យនីតិវិធីបណ្ដឹងមានការយឺតយ៉ាវខ្លាំងនោះតុលាការអាចអនុញ្ញាតឱ្យភាគីដាក់មធ្យាបាយតទល់បាន។

[147] មាត្រា ១១២ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[148] មាត្រា ១១២ នៃសេចក្ដីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧។
[149] មាត្រា ១០៨ វាក្យខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។
[150] មាត្រា ២៧៤ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

ឧទាហរណ៍៖ ឯកសារដែលភាគីបានយកមកជាមួយនៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ ករណីដែលបាននាំសាក្សីមកសាលសវនាការជាដើម ដែលជាករណីដែលអាចធ្វើការស្នើសុំដាក់ភស្តុតាង ដើម្បីឱ្យពិនិត្យភ្លាមៗបានជាអាទិ៍ ឬ ក្នុងករណីដែលបានបំភ្លឺថាការមិនអាចស្នើដាក់ឯកសារមុនការបញ្ចប់នីតិវិធីនោះ មិនមែនកើតឡើងដោយសារកំហុសធ្ងន់ធ្ងររបស់ភាគីទេណាមួយនោះឡើយ។ ឧទាហរណ៍៖ ករណីដែលបានអះអាងអំពីអង្គហេតុដែលកើតមានឡើងក្រោយនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ករណីដែលបានស្នើដាក់ភស្តុតាងដែលទើបនឹងរកឃើញថ្មីជាដើម គឺអាចអនុញ្ញាតឱ្យស្នើដាក់ក្រោយបាន។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវ និងចេញជាអត្ថបទសារណាដែលផ្តោតអំពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលរួចមក យើងបានឃើញថានីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះជាដំណាក់កាលដ៏សំខាន់បន្ទាប់ពីការដាក់ពាក្យបណ្តឹង។ ក្នុងនោះមុនឈានដល់ការបកស្រាយទៅលើប្រធានបទឱ្យបានស៊ីជម្រៅក៏មានការបង្ហាញពីបញ្ហាដែលប្រជាពលរដ្ឋបានជួបប្រទះជាប្រចាំដែលនោះសំដៅទៅលើវិវាទរដ្ឋប្បវេណី។វិវាទរដ្ឋប្បវេណីគ្របដណ្តប់លើវិវាទទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងទំនាក់ទំនងទ្រព្យសម្បត្តិ និងទំនាក់ទំនងញាតិជាអាទិ៍។ នៅពេលដែលមានវិវាទរដ្ឋប្បវេណីកើតឡើងគូវិវាទអាចដោះស្រាយនៅក្រៅប្រព័ន្ធតុលាការបាន ដែលមានវិធីដោះស្រាយដូចជា ការចរចា សន្ធានកម្ម និងមជ្ឈត្តការ។ ប៉ុន្តែប្រសិនបើមានការដោះស្រាយនៅក្រៅប្រព័ន្ធតុលាការមិនបាន រហូតដល់គូវិវាទសម្រេចចិត្តដាក់ពាក្យបណ្តឹងទៅតុលាការ នោះតុលាការត្រូវមានកាតព្វកិច្ចស្វែងរកភាពត្រឹមត្រូវយុត្តិធម៌ជូនភាគី។ ក្នុងគោលបំណងស្វែងរកភាពច្បាស់លាស់ត្រឹមត្រូវ និងយុត្តិធម៌ជូនគូភាគីនេះហើយ បានយើងសង្កេតឃើញថានីតិវិធីត្រៀមសម្រាប់ការទាញហេតុផលមានសារៈសំខាន់ និងភាពចាំបាច់យ៉ាងខ្លាំង។ ដោយហេតុថា នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺតុលាការត្រូវរៀបចំសេចក្តីអះអាងរបស់ភាគី បំភ្លឺនូវចំណុចវិវាទនៃរឿងក្តីដែលគូភាគីយល់មិនស្របគ្នា និងរៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនៃរឿងក្តីនោះ។ ការធ្វើបែបនេះគឺក្នុងគោលបំណងសំខាន់ៗដែលរួមមានដូចជា ដើម្បីបង្រួមអង្គហេតុ រៀបចំចំណុចវិវាទ និងការដាក់ភស្តុតាងដើម្បីធ្វើការវិនិច្ឆ័យរឿងក្តីនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់បានល្អិតល្អន់ មុនពេលតុលាការចេញសាលក្រមមួយដែលប្រកបដោយភាពយុត្តិធម៌ជូនគូភាគី។ តាមរយៈនេះភាគីអាចដាក់មធ្យោបាយតទល់ ឬ មធ្យោបាយការពារខ្លួនជូនតុលាការពិនិត្យ។ ចំពោះការដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនដោយចេតនាទុច្ចរិត ឬ មិនស្មោះត្រង់របស់ភាគី នៅពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលតែងតែកើតមានជាញឹកញាប់ ដែលភាគីណាមួយមិនគោរពគោលការណ៍ស្មោះត្រង់ ឬ សុចរិត ហើយបានបង្កឱ្យមានការខូចខាតធ្ងន់ធ្ងរដល់ភាគីម្ខាងទៀត។ សកម្មភាពទាំងនោះបានបង្កឱ្យភាគីម្ខាងទៀតមិនអាចមានឱកាសសម្រាប់តទល់ ឬ ការពារខ្លួន ដែលក្នុងករណីនេះសិទ្ធិនៃការដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនត្រូវបានទទួលស្គាល់ចំពោះភាគីដែលសុចរិត ទោះបីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវបានបញ្ចប់ហើយក៏ដោយ។

បន្ថែមពីនេះ ដើម្បីឈានដល់ការទាញហេតុផលដោយផ្ទាល់មាត់ឱ្យប្រព្រឹត្តទៅមានភាពរលូន និងល្អប្រសើរនោះត្រូវធ្វើយ៉ាងណាឱ្យនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលមានភាពច្បាស់លាស់ និងគោរពតាមបទប្បញ្ញត្តិច្បាប់ដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ ជាធរមាន។ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក៏ជាមូលដ្ឋានដែលឱ្យតុលាការចេញសាលក្រមឆ្លើយតបជាមួយនឹងការអះអាងរបស់ភាគីផងដែរ។

ប្រសិនបើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដំណើរការដោយមិនមានភាពច្បាស់លាស់ទេ តុលាការក៏មិនអាចបន្តនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ដោយពិនិត្យភស្តុតាងជាសមូហវិធី ហើយត្រូវបង្វិលនីតិវិធីត្រឡប់ទៅនីតិវិធីត្រៀមសម្រាប់ទាញហេតុផលឡើងវិញដើម្បីផ្តល់ភាពយុត្តិធម៌ជូនភាគី ហើយការធ្វើបែបនេះគឺបណ្តាលឱ្យនីតិវិធីយឺតយ៉ាវ ដូចនេះទាមទារឱ្យតុលាការត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងដំណាក់កាលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើម្បីស្វែករកចំណុចស្នូលនៃវិវាទ។

ជាការពិតណាស់ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលភាគីត្រូវគោរពនូវគោលការណ៍សំខាន់ៗ ដូចជា គោលការណ៍ចំពោះមុខ គោលការណ៍យុត្តិធម៌ និងឆាប់រហ័ស គោលការណ៍អសាធារណៈ គោលការណ៍សិទ្ធិចាត់ចែងរបស់ភាគី និងគោលការណ៍នៃការប្រើប្រាស់សិទ្ធិបំភ្លឺ ដូចនេះវត្តមានរបស់គូភាគីគឺជាកត្តាសំខាន់ដើម្បីឱ្យកិច្ចនីតិវិធីប្រព្រឹត្តទៅដោយពេញលេញ។ នីតិវិធីនេះត្រូវបានដឹកនាំដោយតុលាការ ចំណែកឯភាគីជាអ្នកធ្វើសកម្មភាពទៅតាមការបង្គាប់ ឬ ការអនុញ្ញាតរបស់តុលាការ។

សរុបសេចក្តីមក នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺត្រូវរៀបចំមុននីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ហើយនីតិវិធីនេះមានគោលបំណងសំខាន់គឺកំណត់ឱ្យបានច្បាស់នូវចំណុចវិវាទដែលកើតមាននៅក្នុងរឿងក្តី ជាចំណុចដែលគូភាគីមិនយល់ស្របគ្នា ដើម្បីយកចំណុចវិវាទនេះទៅដោះស្រាយនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ដែលជាដំណាក់កាលក្នុងការចេញសាលក្រម។ បន្ទាប់ពីបានធ្វើការបកស្រាយដូចខាងលើ សង្កេតឃើញថានីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជានីតិវិធីដ៏សំខាន់ ដែលមិនអាចខ្វះបាននៅក្នុងនីតិវិធីនៃបណ្តឹងពីព្រោះថារាល់ការកំណត់ឱ្យបាននូវចំណុចវិវាទនៃរឿងក្តី ជាចំណុចចាំបាច់នៅក្នុងការដោះស្រាយបណ្តឹង រហូតដល់ការសម្រេចសេចក្តីតាមរយៈសាលក្រម។

# អនុសាសន៍

# អនុសាសន៍

នៅក្នុងជីវភាពរស់នៅជាប្រចាំថ្ងៃរបស់មនុស្ស នៅក្នុងសកលលោកបច្ចុប្បន្នបានជួបប្រទះនូវបញ្ហាជាច្រើនដែលអាចជាបញ្ហារវាងរដ្ឋ និងរដ្ឋ រដ្ឋ និងបុគ្គលឯកជន ហើយកាន់តែមានច្រើនចំពោះបញ្ហាជម្លោះរវាងបុគ្គលឯកជន និងបុគ្គលឯកជន។ នៅក្នុងនោះព្រះរាជាណាចក្រកម្ពុជាក៏ស្ថិតនៅក្នុងបរិបទនេះដែរ បើទោះបីជាប្រទេសកម្ពុជាបានទទួលនូវសុខសន្តិភាពប្រសើរឡើងក៏ដោយ ក៏កត្តាដែលមានជម្លោះរវាងបុគ្គលឯកជន និងបុគ្គលឯកជនកើតមានជារៀងរាល់ថ្ងៃ។ នៅក្នុងរឿងក្ដីជម្លោះនីមួយៗ គឺពិតជាមានភាពស្មុគស្មាញណាស់ ដែលតម្រូវឱ្យតុលាការយកចិត្តទុកដាក់ក្នុងការដោះស្រាយរឿងក្ដី ដើម្បីឱ្យគូភាគីទទួលបានភាពយុត្តិធម៌ ព្រមជាមួយគ្នានេះផងដែរ ពេលវេលានៃការដោះស្រាយក៏ជាចំណុចសំខាន់មួយដែរ ក្នុងការដែលត្រូវបញ្ចប់រឿងក្ដីនោះដោយមានភាពយុត្តិធម៌ ព្រោះការដែលដោះស្រាយរឿងក្ដីដោយអូសបន្លាយពេលវេលាទុកចោលយូរនោះស្មើនឹងគ្មានភាពយុត្តិធម៌រួចទៅហើយ (Justice denied, justice delayed) នេះបើយោងតាមប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម កើត រិទ្ធ** ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ដើម្បីរក្សាជំនឿចិត្ត និងសេចក្ដីទុកចិត្តរបស់ប្រជាពលរដ្ឋខ្មែរមកលើប្រព័ន្ធច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា កម្ពុជាបានចងក្រងប្រព័ន្ធច្បាប់ជាច្រើន ជាពិសេសនៅក្នុងរឿងក្ដីរដ្ឋប្បវេណី គឺមានក្រមរដ្ឋប្បវេណីដែលជាក្រមសារធាតុ រួមទាំងក្រមនីតិវិធីរដ្ឋប្បវេណីសម្រាប់គ្រប់គ្រង និងដោះស្រាយរាល់វិវាទដែលបានកើតឡើង។ ក្រោយពីបានសិក្សាស្រាវជ្រាវលើប្រធានបទមួយនេះ នាងខ្ញុំទាំងពីររូបយល់ឃើញថាចំពោះទ្រឹស្ដីមានការបញ្ញត្តច្បាស់លាស់គិតគូរបានយ៉ាងល្អប្រសើរចំពោះភាគីទាំងអស់នៅក្នុងរឿងក្ដីដែលមានទាំង ដើមចោទ ចុងចម្លើយ សាក្សី ឬ បុគ្គលដែលពាក់ព័ន្ធផ្សេងទៀត។

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ នាងខ្ញុំទាំងពីរ យល់ឃើញថាក្រមនីតិរដ្ឋប្បវេណីបានចែងយ៉ាងល្អិតល្អន់ ដោយមិនមានកំណត់ចំនួនដងនៃការរៀបចំនីតិវិធីនេះទេ ប៉ុន្តែការធ្វើទៅប៉ុន្មានដងនេះជាឆន្ទានុសិទ្ធិរបស់តុលាការ លុះត្រាតែតុលាការយល់ឃើញថាអាចកំណត់នូវចំណុចវិវាទបានហើយ ទើបកិច្ចនីតិវិធីនេះត្រូវបានបញ្ចប់។ នេះសបញ្ជាក់ឱ្យឃើញយ៉ាងច្បាស់ថា ក្រមនីតិវិធីរដ្ឋប្បវេណីពិតជាបានគិតគូរគ្រប់ជ្រុងជ្រោយ ព្រោះប្រភេទ និងទំហំនៃរឿងក្ដីពិតជាមិនដូចគ្នាទេ ហើយការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដើម្បីកំណត់បាននូវចំណុចវិវាទនេះក៏ប្រើរយៈពេលមិនដូចគ្នាដែរ។ ប្រសិនបើរឿងក្ដីនោះជាប្រភេទរឿងក្ដីដែលមិនសូវមានភាពស្មុគស្មាញ នោះនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនឹងបញ្ចប់ទៅដោយប្រើរយៈពេលខ្លី ព្រោះការស្វែងរកចំណុចវិវាទក៏នឹងមិនស្មុគស្មាញដែរ ប៉ុន្តែផ្ទុយមកវិញប្រសិនបើរឿងក្ដីនោះជាប្រភេទរឿងក្ដីដែលស្មុគស្មាញ នោះនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនឹងត្រូវធ្វើច្រើនដង ដែលវា

នឹងចំណាយពេលវេលាយូរព្រោះចំណុចវិវាទបានកប់ជ្រៅដែលទាមទារឱ្យតុលាការប្រើពេលជីកកកាយនូវចំណុចដែលគូភាគីមិនយល់ស្របគ្នានោះ។

ទោះជាយ៉ាងណាសម្រាប់ការអនុវត្តជាក់ស្តែងពិតជាជួបនូវបញ្ហាជាច្រើន ព្រោះការអនុវត្តជាក់ស្តែងមិនដូចអ្វីដែលច្បាប់បានកំណត់មកទាំងស្រុងនោះទេ។ ឧទាហរណ៍៖ នៅក្នុងច្បាប់បានចែងថាគូភាគីត្រូវចូលបង្ហាញខ្លួនក្នុងរយៈពេលកំណត់ណាមួយ ប៉ុន្តែទិដ្ឋភាពជាក់ស្តែងចំពោះរឿងក្តីមួយចំនួនការសហការរបស់ភាគីជាមួយតុលាការមិនបានរលូននោះទេ ជាពិសេសភាគីចុងចម្លើយ។ ទោះជាយ៉ាងណាក៏ដោយ ក៏យើងមើលឃើញជាក់ស្តែងថាតុលាការពិតជាខិតខំប្រឹងប្រែងស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋ ទោះបីជាពេលខ្លះខ្វះការសហការពីសំណាក់គូភាគីនៃរឿងវិវាទ និងពេលខ្លះរឿងក្តីមានការស្មុគស្មាញយ៉ាងណាក៏ដោយ។ ជាចុងក្រោយក្នុងនាមនាងខ្ញុំទាំងពីររូបជា និស្សិតច្បាប់ដែលបានបញ្ចប់ការសិក្សាតាមរយៈសារណាមួយនេះ នាងខ្ញុំទាំងពីរសូមសម្តែងនូវអារម្មណ៍កោតសរសើរក្រៃលែងចំពោះប្រព័ន្ធច្បាប់កម្ពុជាដែលបានយកចិត្តទុកដាក់មើលឃើញគ្រប់ការលំបាករបស់ប្រជាពលរដ្ឋដែលមានវិវាទ និងបានផ្តល់ជាទីទំនុកចិត្តដល់ប្រជាពលរដ្ឋក្នុងការស្វែងរកយុត្តិធម៌៕

# ឯកសារយោង

# ឯកសារយោង

- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

- ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

- ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

- សេចក្តីពន្យល់ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

- សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

- ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦

- ព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ចុះថ្ងៃទី ២៩ ខែកុម្ភៈ ឆ្នាំ ២០០៦

- អនុក្រឹត្យលេខ ៤៧ អនក្រ.បក ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០០២

- ប្រកាសអន្តរក្រសួងរបស់ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃលេខ ៨៥ ឆ្នាំ២០០៦

- ក្រុមការងារនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ខែធ្នូ ឆ្នាំ២០១៤

- គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់, សន្ទានុក្រមនីតិវិធីរដ្ឋប្បវេណី ដកស្រង់ពីសន្ទានុក្រមច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែកនីតិរដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី, បោះពុម្ពលើកទី ១ ឆ្នាំ២០០៧

- ជួប បិតបេរឫទ្ធិ អត្ថបទ "វិវាទរដ្ឋប្បវេណី" ឆ្នាំ២០១៦

- ប៉ោ ហ៊ុយ មេធាវី, ព្រឹត្តិបត្រមេធាវីលេខ ២០ "នីតិវិធីជំនុំជម្រះលើកទី ១" ខែមករា-មីនា ឆ្នាំ២០១៩

- យឹម សារី ការវិភាគ "ក្រមនីតិវិធីរដ្ឋប្បវេណីក្នុងនីតិវិធីបណ្តឹង" ឆ្នាំសិក្សា២០២២-២០២៣

- សាន់ ជួយ សាស្ត្រាចារ្យនីតិសាស្ត្រ កម្រងឯកសារ "នីតិវិធីរដ្ឋប្បវេណី" ឆ្នាំ២០១៥

- ហ៊ី សោភា សាស្ត្រាចារ្យនីតិសាស្ត្រ សៀវភៅសិក្សា "នីតិវិធីរដ្ឋប្បវេណី" ឆ្នាំ២០១៦

- ហេង ប៉ូរ៉ា មេធាវី សៀវភៅសិក្សា "នីតិវិធីរដ្ឋប្បវេណី" ឆ្នាំសិក្សា២០២៣-២០២៤

- freshnewsasia.com, បានចូលមើលនៅម៉ោង ១៤:៥៤ នាទីថ្ងៃ, ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៤

- ncac.org.kh, បានចូលមើលនៅម៉ោង ១:២៦ នាទីព្រឹក, ថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៤

# ឧបសម្ព័ន្ធ

## បញ្ជីឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី ១** ៖ ពាក្យស្នើសុំជូនពិនិត្យភស្តុតាង

**ឧបសម្ព័ន្ធទី ២** ៖ កំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

**ឧបសម្ព័ន្ធទី ៣** ៖ ដីកាសម្រេចបណ្តឹងតវ៉ា និងការចូលរួមជួយអន្តរាគមន៍

**ឧបសម្ព័ន្ធទី ៤** ៖ លិខិតបញ្ជាក់ស្ថាពរកំណត់ហេតុសះជា

**ឧបសម្ព័ន្ធទី ៥** ៖ ដីកាសម្រេចការស្នើសុំឱ្យពិនិត្យភស្តុតាង

**ឧបសម្ព័ន្ធទី ៦** ៖ ដីកាសម្រេចបង្គាប់ឱ្យកែតម្រូវចំណុចខ្វះចំពោះពាក្យបណ្តឹង

**ឧបសម្ព័ន្ធទី ៧** ៖ លិខិតអញ្ជើញមេធាវី

**ឧបសម្ព័ន្ធទី ៨** ៖ ដីកាកោះ

**ឧបសម្ព័ន្ធទី ៩** ៖ ដីកាសម្រេចបង្គាប់ឱ្យបង់ប្រាក់ពន្ធដាក់ពាក្យសុំ

**ឧបសម្ព័ន្ធទី ១០** ៖ ដីកាសម្រេចបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ

**ឧបសម្ព័ន្ធទី ១១** ៖ បង្កាន់ដៃទទួលប្រាក់

# ឧបសម្ព័ន្ធទី ១

ពាក្យស្នើសុំគំរូ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យស្នើសុំជូនពិនិត្យភស្តុតាង

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ កកក អាយុ.....ឆ្នាំ អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ..... ផ្លូវលេខ..... ភូមិ........ សង្កាត់.......... ខណ្ឌ......... រាជធានីភ្នំពេញ/ខេត្ត............

**សូមគោរពជូន**

**លោក**.......................**ចៅក្រមជំនុំជម្រះរាជធានីភ្នំពេញ/ខេត្ត**..............

**កម្មវត្ថុ៖** ស្នើសុំជូនពិនិត្យភស្តុតាង ។

**យោង៖** សំណុំរឿងរដ្ឋប្បវេណីលេខ...........ចុះថ្ងៃទី....ខែ....ឆ្នាំ...របស់សាលាដំបូងរាជធានី/ខេត្ត......។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមជូនភស្តុតាងជាឯកសារថតចម្លង និងសាក្សីដូចមានខាងក្រោម ៖

**ក. ឯកសារថតចម្លង**

១.........................................................................................( ចំនួន០១ច្បាប់ )

២.........................................................................................( ចំនួន០១ច្បាប់ )

**ខ. សាក្សី**

១. ឈ្មោះ...........អាយុ......ភេទ...... មុខរបរ..............ទីលំនៅបច្ចុប្បន្នផ្ទះលេខ ..... ផ្លូវលេខ..... ភូមិ........ សង្កាត់.......... ខណ្ឌ......... រាជធានីភ្នំពេញ/ខេត្ត............

២. ឈ្មោះ............អាយុ......ភេទ...... មុខរបរ............ទីលំនៅបច្ចុប្បន្នផ្ទះលេខ ..... ផ្លូវលេខ..... ភូមិ........ សង្កាត់.......... ខណ្ឌ......... រាជធានីភ្នំពេញ/ខេត្ត............

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **លោកចៅក្រម** មេត្តាទទួលពិនិត្យនូវពាក្យជូនពិនិត្យភស្តុតាងរបស់ខ្ញុំបាទ/នាងខ្ញុំតាមច្បាប់ ដោយក្តីអនុគ្រោះ ។

សូម **លោកចៅក្រម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ ។

ថ្ងៃ................ កើត/រោច ខែ............ ឆ្នាំ....... ............ស័ក ព.ស. ២៥៦......

រាជធានីភ្នំពេញ ថ្ងៃទី........... ខែ.................. ឆ្នាំ២០..........

**ស្នាមមេដៃស្តាំ**

# ឧបសម្ព័ន្ធទី ២

| រូបសញ្ញាសាលាដំបូងរាជធានី/ខេត្ត... | ព្រះរាជាណាចក្រកម្ពុជា<br>ជាតិ សាសនា ព្រះមហាក្សត្រ | នីតិវិធីត្រៀម...គំរូ |
|---|---|---|

## កំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ទាញហេតុផល

រឿងក្ដីរដ្ឋប្បវេណីលេខ ៖ .......ចុះថ្ងៃទី.......ខែ.......ឆ្នាំ.................
សញ្ញាណនៃរឿងក្ដី ៖ ប្ដឹងសុំចេញសាលក្រម.......................
កាលបរិច្ឆេទ ៖ ថ្ងៃទី.......ខែ..........ឆ្នាំ............
ទីកន្លែង ៖ សាលាដំបូងរាជធានី/ខេត្ត............
ចៅក្រម ៖ លោក...........................
ក្រឡាបញ្ជី ៖ លោក...........................

**ក. គូភាគីដែលបានបង្ហាញខ្លួន**

ដើមចោទ៖

ឈ្មោះ កកក ភេទប្រុស អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ... ផ្លូវលេខ..... ភូមិ...... សង្កាត់...... ខណ្ឌ......... រាជធានីភ្នំពេញ/ខេត្ត............

អ្នកតំណាងដោយអាណត្តិលោកមេធាវី ............... (ប្រសិនបើមានមេធាវីតំណាងដោយអាណត្តិឲ្យ)

ចុងចម្លើយ៖

ឈ្មោះ កកក ភេទប្រុស អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ... ផ្លូវលេខ... ភូមិ........ សង្កាត់...... ខណ្ឌ......... រាជធានីភ្នំពេញ/ខេត្ត............

អ្នកតំណាងដោយអាណត្តិលោកមេធាវី .............. (ប្រសិនបើមានមេធាវីតំណាងដោយអាណត្តិឲ្យ)

កម្មវត្ថុបណ្ដឹង: ប្ដឹងសុំឱ្យតុលាការចេញសាលក្រមសម្រេច៖

១. បង្គាប់ឱ្យចុងចម្លើយឈ្មោះ ............
២. បង្គាប់ឱ្យចុងចម្លើយឈ្មោះ ....................
៣. ...............
៤. ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

**ខ. ការអះអាងរបស់គូភាគី**

+ ដើមចោទបានធ្វើសេចក្ដីថ្លែងការណ៍ថា៖.........................................................................................
..........................................................................................................................................
.........................................................................................................................................។

+ ចុងចម្លើយបានធ្វើសេចក្ដីថ្លែងការណ៍ថា៖.......................................................................................
..........................................................................................................................................
.........................................................................................................................................។

+ ដើមចោទបានធ្វើសេចក្ដីថ្លែងការណ៍តបថា៖....................................................................................
..........................................................................................................................................
.........................................................................................................................................។

+ ចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍តបថា៖...........................................................................

..........................................................................................................................................................

..........................................................................................................................................................។

**ឝ. ចំណុចវិវាទ**

១. តើការទាមទារ............................................របស់ដើមចោទមានភាពត្រឹមត្រូវ និងមូលដ្ឋានដែលអាចឱ្យតុលាការពិចារណា និងសម្រេចដែរឬទេ?

២. តើ..................................................................................... ?

៣. តើ..................................................................................... ?

+តុលាការសម្រេចកំណត់ឱ្យភាគីដាក់ភស្តុតាងមិនឱ្យហួសថ្ងៃទី...........ខែ...........ឆ្នាំ......... វេលាម៉ោង ៥ និង ០០ នាទីល្ងាច ។

ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍ចប់សព្វគ្រប់។
តុលាការសម្រេចបញ្ចប់កំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ទាញហេតុផលនៅថ្ងៃនេះ។
បញ្ចប់កំណត់ហេតុនៅម៉ោង...............នាទី ថ្ងៃខែឆ្នាំ ដដែល។

**ស្នាមមេដៃស្តាំរបស់ដើមចោទ** | **ស្នាមមេដៃស្តាំរបស់ចុងចម្លើយ**

**ក្រឡាបញ្ជី** | **ចៅក្រម**

## ឧបសម្ព័ន្ធទី ៣

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

## ដីកាសម្រេចបណ្តឹងតវ៉ា និងការចូលរួមជួយអន្តរាគមន៍

យើង........................................ក្រុមប្រឹក្សាជំនុំជម្រះ នៃសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញមាត្រា ៤៥ និងមាត្រា ៤៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦។ បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ...........ចុះថ្ងៃទី...........ខែ..............ឆ្នាំ...................របស់សាលាដំបូងរាជធានីភ្នំពេញ។

រវាងដើមចោទឈ្មោះ...............................ភេទ............អាយុ............ឆ្នាំ មុខរបររកស៊ី.................. មានទីលំនៅសព្វថ្ងៃផ្ទះលេខ..............ផ្លូវលេខ............ក្រុម............ភូមិ............ឃុំ/សង្កាត់........................ ស្រុក/ខណ្ឌ.........................ខេត្ត/ក្រុង.....................ប្តី/ប្រពន្ធឈ្មោះ.....................មានកូន...........នាក់។

និងចុងចម្លើយឈ្មោះ...............................ភេទ............អាយុ............ឆ្នាំ មុខរបររកស៊ី................ ដែលមានកម្មវត្ថុបណ្តឹង៖..................................................................................................

បានឃើញពាក្យបណ្តឹងតវ៉ា និងការចូលរួមជួយអន្តរាគមន៍ចុះថ្ងៃទី.............របស់ឈ្មោះ.................. អាយុ............ឆ្នាំ មានទីលំនៅសព្វថ្ងៃផ្ទះលេខ..................ផ្លូវលេខ..........................ក្រុម................. ភូមិ ...................ឃុំ/សង្កាត់.....................ស្រុក/ខណ្ឌ.......................ខេត្ត/ក្រុង.....................ដែលចូលរួមជាភាគី..........................។

សំអាង

ពាក្យបណ្តឹងតវ៉ា និងចូលរួមអន្តរាគមន៍ មានមូលហេតុសមស្រប តាមផ្លូវច្បាប់ ឬផ្ទុយច្បាប់................ ......................................................................................................................................

### ហេតុដូច្នេះសម្រេច

មិនអនុញ្ញាតឱ្យឈ្មោះ.........................ចូលរួមជួយអន្តរគមន៍ជាភាគី...................នៅក្នុងសំណុំរឿងខាងលើ តាមច្បាប់តទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី............ខែ..........ឆ្នាំ...............

## ឧបសម្ព័ន្ធទី ៤

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

## លិខិតបញ្ជាក់ស្ថាពរលើកំណត់ហេតុសះជា

យើង..................................ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្ដាល។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ .................. ចុះថ្ងៃទី..........ខែ..............ឆ្នាំ................របស់សាលាដំបូងខេត្តកណ្ដាល។

បានឃើញកំណត់ហេតុសះជាចុះថ្ងៃទី...........ខែ...........ឆ្នាំ.............របស់សាលាដំបូងខេត្តកណ្ដាល

យោងពាក្យស្នើសុំបញ្ជាក់ស្ថាពរលើកំណត់ហេតុសះជា ចុះថ្ងៃទី...........ខែ.............ឆ្នាំ............ របស់ឈ្មោះ................................អត្តលេខ.....................ជាសមាជិកគណៈមេធាវីនៃព្រះរាជណាចក្រកម្ពុជាមានការិយាល័យផ្ទះលេខ................ផ្លូវ............ឃុំ/សង្កាត់.........................ស្រុក/ខណ្ឌ.....................រាជធានី/ខេត្ត.........................ជាមេធាវីតំណាងដោយអាណត្តិឱ្យឈ្មោះ....................................។

សូមបញ្ជាក់ថាកំណត់ហេតុសះជា ចុះថ្ងៃទី.............ខែ..................ឆ្នាំ.................របស់សាលាដំបូងខេត្តកណ្ដាល បានចូលជាស្ថាពរចាប់ពីថ្ងៃទី................ខែ.................ឆ្នាំ..................ដោយគូភាគីពុំបានចូលមកប្ដឹងទាស់ ឬប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ទេ។

យើងចេញលិខិតបញ្ជាក់នេះ ដើម្បីអនុញ្ញាតឱ្យដាក់កំណត់ហេតុសះជានេះ សម្រាប់គូភាគីសុំយកទៅអនុវត្តតាមច្បាប់។

ខេត្តកណ្ដាល, ថ្ងៃទី............ខែ.............ឆ្នាំ.............

**ក្រឡាបញ្ជីសវនាការ**

**ឧបសម្ព័ន្ធទី ៥**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

# ដីកាសម្រេចការស្នើសុំឱ្យពិនិត្យភស្តុតាង

យើង..........................ក្រុមប្រឹក្សាជំនុំជម្រះ នៃសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញមាត្រា ១០៦ មាត្រា ១២៤ និងមាត្រា ១២៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី................ខែ........................ឆ្នាំ.......................

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ.....................ចុះថ្ងៃទី............ខែ...............ឆ្នាំ..................

រវាងដើមចោទឈ្មោះ..........................ភេទ...........អាយុ..............ឆ្នាំ មុខរបររកស៊ី...................
មានទីលំនៅសព្វថ្ងៃផ្ទះលេខ................ ផ្លូវលេខ...........ក្រុម..........ភូមិ.............ឃុំ/សង្កាត់..................
ស្រុក/ខណ្ឌ....................ខេត្ត/ក្រុង.......................ប្ដី/ប្រពន្ធឈ្មោះ......................មានកូន.............នាក់។

និងចុងចម្លើយឈ្មោះ ..........................ភេទ..........អាយុ..........ឆ្នាំ មុខរបររកស៊ី........................
មានទីលំនៅសព្វថ្ងៃផ្ទះលេខ................ ផ្លូវលេខ...........ក្រុម..........ភូមិ.............ឃុំ/សង្កាត់..................
ស្រុក/ខណ្ឌ....................ខេត្ត/ក្រុង.......................ប្ដី/ប្រពន្ធឈ្មោះ......................មានកូន.............នាក់។

ដែលមានកម្មវត្ថុបណ្ដឹង៖...................................................................................................

បានឃើញពាក្យសុំឱ្យពិនិត្យភស្តុតាង ចុះថ្ងៃទី.......ខែ.........ឆ្នាំ............របស់ឈ្មោះ......................
ជាដើមចោទ/ចុងចម្លើយ។

សំអាងហេតុ

.........................................................................................................................................

**ហេតុដូច្នេះសម្រេច**

ទទួលយក ឬមិនទទួលយកភស្តុតាង។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី............ខែ............ឆ្នាំ................

**ចៅក្រម, ក្រុមប្រឹក្សាជំនុំជម្រះ**

## ឧបសម្ព័ន្ធទី ៦

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

## ដីកាសម្រេចបង្គាប់ឱ្យកែតម្រូវចំណុចខ្វះខាតចំពោះពាក្យបណ្តឹង

យើង.........................ក្រុមប្រឹក្សាជំនុំជម្រះនៃសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញមាត្រា ៧៥ និងមាត្រា ៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ..............ចុះថ្ងៃទី.........ខែ...........ឆ្នាំ..............របស់សាលាដំបូងរាជធានីភ្នំពេញ។

រវាងដើមចោទឈ្មោះ..........................ភេទ...........អាយុ..............ឆ្នាំ មុខរបររកស៊ី...................
មានទីលំនៅសព្វថ្ងៃផ្ទះលេខ................ ផ្លូវលេខ...........ក្រុម..........ភូមិ.............ឃុំ/សង្កាត់..................
ស្រុក/ខណ្ឌ....................ខេត្ត/ក្រុង......................ប្តី/ប្រពន្ធឈ្មោះ.....................មានកូន............នាក់។

និងចុងចម្លើយឈ្មោះ ..........................ភេទ.........អាយុ..........ឆ្នាំ មុខរបររកស៊ី........................
មានទីលំនៅសព្វថ្ងៃផ្ទះលេខ................ ផ្លូវលេខ...........ក្រុម..........ភូមិ.............ឃុំ/សង្កាត់..................
ស្រុក/ខណ្ឌ....................ខេត្ត/ក្រុង......................ប្តី/ប្រពន្ធឈ្មោះ.....................មានកូន............នាក់។

ដែលមានកម្មវត្ថុបណ្តឹង៖..........................................................................................................

បានឃើញពាក្យសុំឱ្យជួយសង្គ្រោះរបស់ឈ្មោះ................................អាយុ...........ចុះថ្ងៃទី............
ខែ...........ឆ្នាំ...............ដែលសុំពន្យាពេល អនុគ្រោះមិនបាច់បង់ប្រាក់ប្រដាប់ក្តី តុលាការ។

សំអាងហេតុ

..................................................................................................................................................

### ជម្រាបមក

លោក/លោកស្រី...............................ជាដើមចោទឱ្យធ្វើការកែតម្រូវត្រង់ ចំណុចខាងលើ ឬពេលសមរម្យ.................ជាកំណត់ចាប់ថ្ងៃទី...........ខែ..........ឆ្នាំ...............ដែលបានទទួលដំណឹងសម្រេចនេះ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី..........ខែ.............ឆ្នាំ.................

**ចៅក្រម, ក្រុមប្រឹក្សាជំនុំជម្រះ**

# ឧបសម្ព័ន្ធទី ៧

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណី

## លិខិតអញ្ជើញមេធាវី

លេខ ចុះថ្ងៃទី ២០២៣ យើង ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

បានឃើញ លិខិតតំណាងដោយអាណត្តិចុះថ្ងៃទី ខែ ឆ្នាំ២០២៣ របស់លោកមេធាវី ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ ។

អញ្ជើញលោក ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ មានការិយាល័យផ្ទះលេខ ផ្លូវ ភូមិ សង្កាត់ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

ឱ្យចូលមកកាន់សាលាដំបូងរាជធានីភ្នំពេញ បន្ទប់ " ជាន់ទី នៅថ្ងៃទី. ..ខែ ឆ្នាំ២០២៤ វេលាម៉ោង ... និង នាទីព្រឹក/ល្ងាច។

ដើម្បី ចូលរួមក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ។

ពីដំណើររឿង ប្ដឹងរំលាយកិច្ចសន្យាលក់-ទិញ ។

សាមីខ្លួនត្រូវអញ្ជើញមកឱ្យទាន់ពេលវេលា និងយកលិខិតផ្សេងៗដែលទាក់ទិននិងរឿងខាងលើមកជាមួយផងប្រសិនបើមាន ។

ថ្ងៃ. ..ខែ ឆ្នាំរោង ឆស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី........ ខែ ឆ្នាំ២០២៤

ចៅក្រម

## ឧបសម្ព័ន្ធទី ៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

# ដីកាកោះ

យើង ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

អញ្ជើញឈ្មោះ កើតឆ្នាំ១៩៩៩ ជនជាតិខ្មែរ ជា ដើមចោទ មានអាសយដ្ឋានស្នាក់នៅផ្ទះលេខ

ភូមិ សង្កាត់ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

| | |
|---|---|
| សញ្ញាណរឿងក្តី និង ភាគី | -សំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែ ឆ្នាំ២០២៣<br>-ការទាមទាររបស់ដើមចោទ: ប្តឹងសុំឱ្យតុលាការចេញសាលក្រម៖ រំលាយកិច្ចសន្យាលក់-ទិញ ។ |
| កាលបរិច្ឆេទ<br>និងទីកន្លែងដែលបង្ហាញខ្លួន | ថ្ងៃទី. . ខែមិថុនា ឆ្នាំ២០២៤ វេលាម៉ោង . . និង នាទីព្រឹក/ល្ងាច<br>☑សាលាដំបូងរាជធានីភ្នំពេញ ☐បន្ទប់សវនាការ ☑បន្ទប់ " ជាន់ទី |
| ប្រភេទនៃកាលបរិច្ឆេទ<br>សំគាល់ដោយសញ្ញា ☑ | ☑នីតិវិធីត្រៀម / ☐ ទាញហេតុផលផ្ទាល់មាត់ / ☐ ប្រកាសសាលក្រម<br>............................................................................................ |
| ប្រភេទនៃឯកសារភ្ជាប់ជាមួយ<br>សំគាល់ដោយសញ្ញា ☑ | ☐ឯកសារស្តីពីចំណុចនៃការសាកសួរ<br>☐ ឯកសារស្តីពីចំណុចនៃការធ្វើកោសលវិច័យ |
| ទណ្ឌកម្មជាអាទិ៍<br>ក្នុងករណីដែលមិនបានបង្ហាខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវ | -បើដើមចោទមិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទលើកទី១ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ តុលាការត្រូវច្រានចោលការទាមទាររបស់ដើមចោទដោយសាលក្រមកំបាំងមុខ តាមមាត្រា ២០០ ក្រមនីតិវិធីរដ្ឋប្បវេណី ។<br>-បើចុងចម្លើយមិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទលើកទី១ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ តុលាការត្រូវបញ្ឈប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលភ្លាមៗ ហើយកំណត់នូវកាលបរិច្ឆេទលើកទី១ នៃការទាញហេតុផលដោយផ្ទាល់មាត់ តាមមាត្រា ២០១ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ។ |

សូមបង្ហាញខ្លួនដូចដែលបានចែងខាងលើនេះ ។

ថ្ងៃ ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៤

ចៅក្រម

# ឧបសម្ព័ន្ធទី ៩

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

## ដីកាសម្រេច
## បង្គាប់ឱ្យបង់ប្រាក់ពន្ធដាក់ពាក្យសុំ

លេខ

**យើង ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ**

**បានឃើញ** មាត្រា ៥៩ និងមាត្រា ៦១ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ *នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦*។

**បានឃើញ** សំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែ ឆ្នាំ២០២៣ របស់តុលាការដំបូងរាជធានីភ្នំពេញ។

**-ភាគីដើមចោទ** ឈ្មោះ ភេទ កើតឆ្នាំ១៩៩៩ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ផ្លូវ ភូមិ សង្កាត់ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

-អ្នកតំណាង ជាមេធាវីតំណាងតាមអាណត្តិ។

**-ចុងចម្លើយ** មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ផ្លូវលេខ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កម្មវត្ថុបណ្តឹង:** ប្តឹងសុំឱ្យតុលាការចេញសាលក្រម៖

១-សុំរំលាយកិច្ចសន្យាទិញ-លក់ ចុះថ្ងៃទី ខែ ឆ្នាំ២០២០ រវាងដើមចោទ និងចុងចម្លើយ។

២-បង្គាប់ឱ្យចុងចម្លើយសងប្រាក់ដើមចំនួន និងការប្រាក់តាមផ្លូវច្បាប់ ប្រគល់មកឱ្យដើមចោទ វិញ។

៣-ទាមទារឱ្យចុងចម្លើយ សងសំណងខូចខាត សេវាមេធាវី និងសេវាផ្សេងក្នុងដំណើរក្តី សរុបចំនួន ដុល្លារអាមេរិក។

៤-សុំអនុវត្តជាបណ្តោះអាសន្នចំពោះចំណុចទី២ ខាងលើ។

៥-ប្រាក់ប្រដាប់ក្តី និងពន្ធផ្សេងជាបន្ទុករបស់ចុងចម្លើយ។

### សំអាងហេតុ

១-**ដើមចោទ** ឈ្មោះ ភេទ កើតឆ្នាំ១៩៩៩ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ផ្លូវ ភូមិ សង្កាត់ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ប្តឹងសុំឱ្យតុលាការចេញសាលក្រម៖

ក-សុំរំលាយកិច្ចសន្យាទិញ-លក់ ចុះថ្ងៃទី ខែ ឆ្នាំ២០២០ រវាងដើមចោទ និងចុងចម្លើយ។

ខ-បង្គាប់ឱ្យចុងចម្លើយសងប្រាក់ដើមចំនួន និងការប្រាក់តាមផ្លូវច្បាប់ ប្រគល់មកឱ្យដើមចោទ វិញ។

គ-ទាមទារឱ្យចុងចម្លើយ សងសំណងខូចខាត សេវាមេធាវី និងសេវាផ្សេងក្នុងដំណើរក្តី សរុបចំនួន ដុល្លារអាមេរិក។

ឃ-សុំអនុវត្តជាបណ្តោះអាសន្នចំពោះចំណុចទី២ ខាងលើ។

ង-ប្រាក់ប្រដាប់ក្តី និងពន្ធផ្សេងជាបន្ទុករបស់ចុងចម្លើយ។

ពីចុងចម្លើយ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ផ្លូវលេខ ខណ្ឌចំការមន រាជធានីភ្នំពេញ មិនទាន់បានបង់ប្រាក់ពន្ធលើកម្មវត្ថុនៃបណ្តឹងទាមទារតាមច្បាប់កំណត់នៅឡើយ។

២-ដើម្បីឱ្យសាលាដំបូងរាជធានីភ្នំពេញ មានមូលដ្ឋានក្នុងការចំណាត់ការឱ្យបានត្រឹមត្រូវតាមនីតិវិធី គប្បីតម្រូវឱ្យដើមចោទឈ្មោះ ភេទ កើតឆ្នាំ១៩៨៦ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ផ្លូវ ភូមិ សង្កាត់ ខណ្ឌចំការមន រាជធានីភ្នំពេញ បង់ប្រាក់ពន្ធលើកម្មវត្ថុនៃបណ្តឹងទាមទារ៖

ក-សុំរំលាយកិច្ចសន្យាទិញ-លក់ ចុះថ្ងៃទី ខែ ឆ្នាំ២០២២ រវាងដើមចោទ និងចុងចម្លើយ។

ខ-បង្គាប់ឱ្យចុងចម្លើយសងប្រាក់ដើមចំនួន និងការប្រាក់តាមផ្លូវច្បាប់ ប្រគល់មកឱ្យដើមចោទ វិញ។

គ-ទាមទារឱ្យចុងចម្លើយ សងសំណងខូចខាត សេវាមេធាវី និងសេវាផ្សេងក្នុងដំណើរក្តី សរុបចំនួន ដុល្លារអាមេរិក។

ឃ-សុំអនុវត្តជាបណ្តោះអាសន្នចំពោះចំណុចទី២ ខាងលើ។

ង-ប្រាក់ប្រដាប់ក្តី និងពន្ធផ្សេងជាបន្ទុករបស់ចុងចម្លើយ។

## ហេតុដូច្នេះសម្រេច

១-បង្គាប់ឱ្យដើមចោទ ឈ្មោះ ភេទ កើតឆ្នាំ១៩៨៦ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ផ្លូវ ភូមិ សង្កាត់ ខណ្ឌចំការមន រាជធានីភ្នំពេញ បង់ប្រាក់ពន្ធលើពាក្យបណ្តឹងចុះថ្ងៃទី ខែ ឆ្នាំ២០២៣ ដែលមានកម្មវត្ថុ៖

ក-សុំរំលាយកិច្ចសន្យាទិញ-លក់ ចុះថ្ងៃទី ខែ ឆ្នាំ២០២២ រវាងដើមចោទ និងចុងចម្លើយ។

ខ-បង្គាប់ឱ្យចុងចម្លើយសងប្រាក់ដើមចំនួន ដុល្លារអាមេរិក និងការប្រាក់តាមផ្លូវច្បាប់ ប្រគល់មកឱ្យដើមចោទ វិញ។

គ-ទាមទារឱ្យចុងចម្លើយ សងសំណងខូចខាត សេវាមេធាវី និងសេវាផ្សេងក្នុងដំណើរក្តី សរុបចំនួន ដុល្លារអាមេរិក។

ឃ-សុំអនុវត្តជាបណ្តោះអាសន្នចំពោះចំណុចទី២ ខាងលើ។

ង-ប្រាក់ប្រដាប់ក្តី និងពន្ធផ្សេងជាបន្ទុករបស់ចុងចម្លើយ។

នៅសាលាដំបូងរាជធានីភ្នំពេញ ក្នុងអំឡុងពេល ០២(ពីរ)សប្តាហ៍ គិតពីថ្ងៃទទួលដំណឹងពីដីកាសម្រេចបង្គាប់ឱ្យបង់ប្រាក់ពន្ធដាក់ពាក្យសុំនេះ ដើម្បីតុលាការកាត់សេចក្តីតាមនីតិវិធី។

២-ក្នុងករណីមិនបានបង់ប្រាក់ពន្ធលើពាក្យបណ្តឹងដូចបានកំណត់ខាងលើនេះទេ តុលាការនឹងសម្រេចលើកពាក្យបណ្តឹងនេះចោលទៅតាមច្បាប់។

ថ្ងៃ ខែ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៣

**ចៅក្រម**

# ឧបសម្ព័ន្ធទី ១០

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

លេខ៖

## ដីកាសម្រេច
## បង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ

យើង ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

បានឃើញ មាត្រា ៦២ កថាខណ្ឌទី៣ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ *នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។*

បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែ ឆ្នាំ២០២៣ របស់សាលាដំបូងរាជធានីភ្នំពេញ។

-**រវាងដើមចោទ** ឈ្មោះ ភេទ កើតឆ្នាំ១៩៩៩ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ភូមិ សង្កាត់ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

-**និងសហចុងចម្លើយ** មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ផ្លូវលេខ ខណ្ឌចំការមន រាជធានីភ្នំពេញ។

**កម្មវត្ថុបណ្តឹង: ប្តឹងសុំរំលាយកិច្ចសន្យាលក់-ទិញ ។**

## សំណេះហេតុ

-ដើម្បីដំណើរការនីតិវិធីទៅតាមច្បាប់ ។

-ដើម្បីឱ្យសាលាដំបូងធ្វើការបញ្ជូនឯកសារ ឬសកម្មភាពផ្សេងៗទៀតតាមនីតិវិធីបណ្តឹងរដ្ឋប្បវេណី ។

## ហេតុដូច្នេះសម្រេច

-**បង្គាប់ឱ្យដើមចោទ** ឈ្មោះ បង់ប្រាក់ប្រដាប់ក្តីសាលាដំបូងក្រៅពីពន្ធចំនួន រៀល ឱ្យបានមុនថ្ងៃទី ខែ ឆ្នាំ២០២៣ ជាកំណត់ ដើម្បីឱ្យសាលាដំបូងជាត់ការរឿងក្តីនេះតាមច្បាប់ ។

ថ្ងៃ ខែ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី.......... ខែ ឆ្នាំ២០២៣

**ចៅក្រម**

## ឧបសម្ព័ន្ធទី ១១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**បង្កាន់ដៃទទួលប្រាក់** លេខ:..................

សំណុំរឿង [illegible] ...........លេខ:............ចុះថ្ងៃទី..., ខែ..... ឆ្នាំ២០២៣..

បានទទួលពីឈ្មោះ:............................................

មានទីលំនៅ [illegible] ............

ចំនួនទឹកប្រាក់ (ជាលេខ)..........................................

(ជាអក្សរ)..............................................

ពីដំណើរ [illegible] ..................

រាជធានីភ្នំពេញ,ថ្ងៃទី........ខែ....... ឆ្នាំ២០២៣..

ក្រឡាបញ្ជី